សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

*Cambodian Journalists Alliance Association*




# របាយការណ៍ស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា ឆ្នាំ២០២៣

កំណត់ត្រាប្រចាំឆ្នាំស្តីពីករណីយាយីប្រឆាំងអ្នកសារព័ត៌មាន

# មាតិកា

**I. សេចក្តីសង្ខេប** **១**

**II. សេចក្តីផ្តើម** **៥**

**III. វិធីសាស្រ្ត** **៦**

១. វិធីសាស្រ្ត និងការប្រមូលទិន្នន័យ ៧

២. វិសាលភាព និងដែនកំណត់ ៧

៣. ពាក្យគន្លឹះ ៨

**IV. ការរកឃើញសំខាន់ៗ** **៩**

១. និន្នាការនៃការយាយីលើអ្នកសារព័ត៌មានពីមួយឆ្នាំទៅមួយឆ្នាំ ១០

២. ទីតាំងនៃករណីយាយី ១១

ក. ការយាយីផ្នែកច្បាប់ ១២

ខ. ការយាយីផ្នែកឌីជីថល ២៩

គ. ការយាយីលើរាងកាយ ៣៣

ឃ. ការគំរាមកំហែង និងការរើសអើង ៣៥

**V. ករណីសិក្សា** **៤៣**

**VI. ស្ថានភាពទូទៅនៃវិស័យសារព័ត៌មាន** **៤៧**

**VII. ព័ត៌មានបច្ចុប្បន្នភាពសំខាន់ៗ** **៤៩**

**VIII. សេចក្តីសន្និដ្ឋាន និង អនុសាសន៍** **៥៣**

# I. សេចក្តីសង្ខេប

សេចក្តីសង្ខេបរបាយការណ៍ប្រចាំឆ្នាំរបស់ខេមបូចា ស្តីពីស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជា គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ ខេមបូចា ក្នុងការឃ្លាំមើល និងតស៊ូមតិ ដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។

អ្នកសារព័ត៌មានគួរតែមានសេរីភាពក្នុងការធ្វើការងាររបស់ពួកគេដោយផ្តល់ព័ត៌មានដល់សាធារណជនក្នុងការធ្វើការសម្រេចចិត្ត ដោយមិនភ័យខ្លាចការគំរាមកំហែងលើផ្នែករាងកាយ ឬការយាយីតាមផ្លូវច្បាប់ឡើយ និងធ្វើឱ្យអ្នកមានអំណាចទទួលខុសត្រូវ។

នៅក្នុងរបាយការណ៍នេះ យើងទទួលស្គាល់ថា អ្នកសារព័ត៌មានទូទាំងប្រទេសកម្ពុជា រួមទាំងអ្នកសារព័ត៌មានរបស់ខេមបូចាផងដែរ មានឆន្ទៈក្នុងការលះបង់សុវត្ថិភាពផ្ទាល់ខ្លួន ដើម្បីការងារ ខណៈជំរុញឱ្យភាគីពាក់ព័ន្ធបង្កើតបរិយាកាសប្រព័ន្ធផ្សព្វផ្សាយ ដែលមានសុវត្ថិភាពជាងមុនផងដែរ។

ក្នុងឆ្នាំ២០២៣ យើងបានកត់ត្រាករណីយាយីយ៉ាងហោចណាស់ ៣២ករណី ទៅលើអ្នកសារព័ត៌មានយ៉ាងតិច៥៩នាក់ (ក្នុងនោះអ្នកសារព័ត៌មានស្ត្រីចំនួន៦នាក់ ការបិទ VOD បានធ្វើឱ្យប៉ះពាល់ដល់អ្នកសារព័ត៌មានចំនួន ១៨នាក់ ក្នុងនោះរួមមានអ្នកសារព័ត៌មានស្ត្រី៤នាក់)។ បើទោះបីជាការកត់ត្រាករណីយាយីបានបង្ហាញពីការថយចុះ ៨,៦% បើធៀបនឹងឆ្នាំ ២០២២ ក៏ដោយ ប៉ុន្តែចំនួនអ្នកសារព័ត៌មានរងការយាយីបានមើលឃើញពីការកើនឡើង៩,៣%។

ក្នុងឆ្នាំ២០២២ ខេមបូចា បានកត់ត្រាករណីយាយីយ៉ាងហោចណាស់ ៣៥ករណីទៅលើអ្នកសារព័ត៌មានចំនួន៥៤នាក់ (ក្នុងនោះស្រី៨នាក់)។

ការយាយីក្នុងទម្រង់នៃចំណាត់ការផ្លូវច្បាប់ ឬការគំរាមកំហែងទៅលើអ្នកសារព័ត៌មានបានកើនឡើងពី ៧ករណីក្នុងឆ្នាំ២០២២ ដល់ ១៥ករណីក្នុងឆ្នាំ២០២៣ ដែលជានិន្នាការគួរឱ្យព្រួយបារម្ភមួយ ហើយយើងនឹងបន្តតាមដានយ៉ាងដិតដល់នៅពេលខាមុខបន្តទៀត។ យើងក៏កត់សម្គាល់ដែរថា យ៉ាងហោចណាស់មានអ្នកសារព័ត៌មាន ៤នាក់ត្រូវបានចាប់ដាក់ពន្ធនាគារ/ឃុំខ្លួនក្នុងឆ្នាំ២០២៣ បើធៀបនឹង៧នាក់ក្នុងឆ្នាំ២០២២។

ទោះបីយ៉ាងណាក៏ដោយ យើងក៏មានការប្រយ័ត្នប្រយែងផងដែរក្នុងការទាញសេចក្តីសន្និដ្ឋានពីតួលេខទាំងនេះ ព្រោះយើងកត់សម្គាល់ថា ការកត់ត្រានេះនៅតែមានការខ្វះចន្លោះ ដែលយើងមិនអាចកត់ត្រាបានគ្រប់ជ្រុងជ្រោយ ដោយសារករណីខ្លះត្រូវបានគេលាក់លៀមមិនលាតត្រដាង ហើយអ្នកសារព័ត៌មានខ្វះ ខ្លាចរអាមិនហ៊ានរាយការណ៍ ព្រោះខ្លាចមានការសងសឹកមកលើខ្លួន។

នៅថ្ងៃបោះឆ្នោតជាតិ ថ្ងៃទី២៣ ខែកក្កដា ខេមបូចា បានកត់ត្រាករណីយាយីទៅលើអ្នកសារព័ត៌មាន យ៉ាងហោចណាស់ ១០នាក់ ជាចំនួនដ៏គួរឱ្យភ្ញាក់ផ្អើលមួយដែលបានកើតឡើងតែក្នុងមួយថ្ងៃ។

ករណីនៃការវិវឌ្ឍដ៏គួរឱ្យព្រួយបារម្ភផ្សេងទៀតនោះ គឺការបិទវិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) កាលពីខែកុម្ភៈ។ វីអូឌី គឺជាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងប្រទេសកម្ពុជា ហើយការបិទ វីអូឌី បានធ្វើឱ្យប៉ះពាល់ដល់ បរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា និងធ្វើឱ្យសាធារណជនមិនអាចទទួលបាននូវព័ត៌មានចម្រុះដែលមានភាពឯករាជ្យ។

អាជ្ញាបណ្ណអង្គភាពប្រព័ន្ធផ្សព្វផ្សាយសរុបចំនួន៦ ត្រូវបានលុបចោលនៅឆ្នាំ ២០២៣ បើធៀបនឹងឆ្នាំ២០២២ មានចំនួនពីរករណី។ នៅក្នុងខែកញ្ញា សូម្បីតែខេមបូចា ក៏ត្រូវបានគំរាមកំហែងដោយចំណាត់ការផ្លូវច្បាប់ដោយក្រសួងកសិកម្ម

វត្ថុប្រមាញ់ និងនេសាទ ពីការដេកហូតអាជ្ញាបណ្ណផងដែរ បន្ទាប់ពីបានចុះផ្សាយអត្ថបទមួយ ដែលរាយការណ៍ពីការវាយដំទៅលើអ្នករិះគន់គោលនយោបាយរដ្ឋាភិបាលឥតសំចៃម្នាក់។

នៅខែវិច្ឆិកា ខេមបូចា បានចេញនូវរបាយការណ៍មួយស្តីពីការកើនឡើងនៃការព្រួយបារម្ភអំពីសុវត្ថិភាពអនឡាញ។ អ្នកសារព័ត៌មាននិងអ្នកនិយមប្រើអ៊ីនធឺណិតជាច្រើនមានការបារម្ភថា រដ្ឋាភិបាលនឹងប្រើប្រាស់ឧបករណ៍ច្បាប់ រួមមាន អនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ ដើម្បីឃ្លាំមើលការបញ្ចេញមតិ និងការគំរាមកំហែងពលរដ្ឋ។

ការភ័យខ្លាចទាំងនេះក៏កាន់តែកើនឡើង ដោយសាររដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការមួយ ដើម្បីតាមដានមតិសាធារណៈ និងលើកកម្ពស់រូបភាពវិជ្ជមានរបស់ប្រទេសកម្ពុជា។ អ្នកតស៊ូមតិបារម្ភថា វិធាននេះនឹងក្លាយជាឧបករណ៍មួយផ្សេងទៀត ដើម្បីតាមដានសកម្មភាពអនឡាញ និងត្រួតពិនិត្យទស្សនៈណា ដែលអ្នកកាន់អំណាចចាត់ទុកថា មានលក្ខណៈជំទាស់។

ជាមួយគ្នានេះដែរ ខេមបូចាក៏សូមអបអរសាទរចំពោះការដោះលែងអ្នកសារព័ត៌មានម្នាក់នៅខេត្តបាត់ដំបង ចេញពីពន្ធនាគារកាលពីខែកក្កដា ប៉ុន្តែក៏ជឿថា អ្នកសារព័ត៌មានរូបនេះមិនគួរជាប់ពន្ធនាគារនោះទេ។ អ្នកសារព័ត៌មានអនឡាញមកពីខេត្តបាត់ដំបងរូបនេះ ត្រូវបានចាប់ខ្លួនបន្ទាប់ពីលោករិះគន់រដ្ឋាភិបាលជាសាធារណៈចំពោះការប្រើប្រាស់វ៉ាក់សាំងចិនរបស់រដ្ឋាភិបាល ដើម្បីផ្តល់ឱ្យប្រជាជនប្រឆាំងនឹងជំងឺកូវីដ ១៩។

ការផ្តន្ទាទោសព្រហ្មទណ្ឌមិនគួរត្រូវគេធ្វើឡើងចំពោះអ្នកសារព័ត៌មានឡើយ លុះត្រាណាតែដំណោះស្រាយនៅក្នុងច្បាប់ស្តីពីរបបសារព័ត៌មានរបស់ប្រទេសកម្ពុជាត្រូវបានប្រើអស់។ ការគំរាមកំហែងចាប់ដាក់ពន្ធនាគារ និងការឃុំខ្លួន គឺជាយុទ្ធសាស្ត្រដ៏តឹងរឹង ដែលគេប្រើដើម្បីបំបិទសំឡេងអ្នកសារព័ត៌មាន និងជំរុញឱ្យអ្នកសារព័ត៌មានធ្វើរឹតត្បិតលើខ្លួនឯង។

ខេមបូចាបានចងក្រងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ដោយមានគោលបំណងលើកកម្ពស់វិស័យប្រព័ន្ធផ្សព្វផ្សាយឱ្យមានដំណើរការរលូន ដោយគ្មានការភ័យខ្លាច ការពិនិត្យចាប់កំហុស និងគ្រោះថ្នាក់។ អ្នកសារព័ត៌មាន មានសិទ្ធិបំពេញការងារក្នុងវិជ្ជាជីវៈដោយសេរី ដោយគ្មានហានិភ័យចំពោះសន្តិសុខ និងសុវត្ថិភាពរបស់ពួកគេ។

## ខាងក្រោមនេះជាអនុសាសន៍របស់ខេមបូចា ទៅកាន់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធ៖

រដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធគួរលើកកម្ពស់សេរីភាពសារព័ត៌មាន និងគោរពកាតព្វកិច្ចវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដូចជាភាពឯកជនរបស់ប្រភព ក៏ដូចជាបង្ហាញការ ប្តេជ្ញាចិត្តក្នុង ការបញ្ចប់ការយាយីលើអ្នកសារព័ត៌មាន។

១. បញ្ឈប់ការចោទប្រកាន់បទព្រហ្មទណ្ឌមកលើអ្នកសារព័ត៌មានទាក់ទងនឹងការងារសារព័ត៌មានរបស់ពួកគេ រួមទាំងអ្នកសារព័ត៌មានពលរដ្ឋ។

២. បញ្ចប់និទ្ទណ្ឌភាពដោយធ្វើការស៊ើបអង្កេត ផ្តន្ទាទោស និងដោះស្រាយ ករណីហិង្សាលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សជាបន្ទាន់។

៣. ផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងធនធានពេញទំហឹង ដល់អង្គភាព ដែលមានភារកិច្ច ស៊ើបអង្កេតឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន រួមទាំងការគាំទ្រ លើការស៊ើបអង្កេតបទឧក្រិដ្ឋ បែបនេះដោយ គិតអំពី យេនឌ័រ ផងដែរ។

៤. ទម្លាក់ចោលភ្លាមៗនូវការចោទប្រកាន់ ដែលតុលាការមិនទាន់សម្រេច ហើយពិនិត្យមើលឡើងវិញនូវការផ្តន្ទាទោស

អ្នកសារព័ត៌មានពីបទ ព្រហ្មទណ្ឌ និង ស៊ើបអង្កេត ករណីហិង្សា លើពួកគេ ។

៥. ពិនិត្យមើល ឡើងវិញភ្លាមៗនូវសេចក្តីសម្រេចកន្លងមក ដែលបានលុបអាជ្ញាបណ្ណព័ត៌មាន និងកំណែទម្រង់បទបញ្ញត្តិជុំវិញការផ្តល់អាជ្ញាបណ្ណព័ត៌មាន ដល់ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដូច្នេះអាជ្ញាបណ្ណព័ត៌មាន អាចត្រូវបានលុប ចោល តាមរយៈ ដីការសម្រេច របស់តុលាការតែប៉ុណ្ណោះ ។

៦. ក្នុងរយៈពេលពីរឆ្នាំខាងមុខត្រូវបង្កើត និងអនុវត្តកម្មវិធី បណ្តុះបណ្តាលសម្រាប់មន្ត្រី អនុវត្តច្បាប់ស្តីពីការគោរពសិទ្ធិអ្នកសារព័ត៌មានក្នុងការធ្វើសេចក្តីរាយការណ៍ និងកត់ត្រានៅពេលមានការតវ៉ា និងក្នុងព្រឹត្តិការណ៍សាធារណៈផ្សេងទៀត។

៧. អនុម័តច្បាប់ស្តីពីការផ្សព្វផ្សាយដើម្បីបង្កើតអាជ្ញាធរផ្សព្វផ្សាយឯករាជ្យមួយ និងបង្កើត បទបញ្ញត្តិច្បាស់លាស់ និងអព្យាក្រិតសម្រាប់ផ្តល់ អាជ្ញាបណ្ណផ្សព្វផ្សាយស្របតាមស្តង់ដារអន្តរជាតិ។

៨. អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលស្របតាមស្តង់ដារអន្តរជាតិត្រឹម ដំណាច់ ឆ្នាំ២០២៤។

៩. ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីឱ្យស្របតាមស្តង់ដារសេរីភាពនៃការបញ្ចេញមតិអន្តរជាតិរួមទាំងការលុបចោល ឬកែប្រែបទញុះញង់ (មាត្រា ៤៩៤, ៤៩៥) និងលុបចោលបទ ប្រមាថចំពោះ អង្គព្រះមហាក្សត្រ (មាត្រា ៤៣៧-ស្ទួន) បទ បរិហារកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥) និងបទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧) ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មានដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ បង្កើតបទបញ្ញត្តិ ច្បាស់លាស់ជុំវិញការទទួលស្គាល់ស្ថាប័នសារព័ត៌មាន និងការចុះបញ្ជី ស្ថាប័នសារព័ត៌មាន និងមិនចាំបាច់តម្រូវឱ្យប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញសុំអាជ្ញាបណ្ណ ។

១០. លុបចោលប្រកាសរបស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឱ្យរដ្ឋាភិបាល លុបអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយដោយ មិនបាច់ឆ្លងកាត់នីតិវិធីតុលាការ ដែលបានរំលោភលើគោលការណ៍សេរីភាពសារព័ត៌មាន និង មាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

១១. លុបចោលប្រកាសអន្តរក្រសួងលេខ១៧០ ដែលត្រូវបានប្រើដើម្បីលុបអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយដោយមិន ចាំបាច់មានសេចក្តីសម្រេចរបស់តុលាការ ក៏ដូចជាផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការបញ្ជាទៅ ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ឱ្យបិទគេហទំព័រ និងលុបចោល អនុក្រឹត្យស្តីពីការចុះ បញ្ជីឈ្មោះដែន ការចុះឈ្មោះស៊ីមកាត និងច្រកទ្វារអ៊ីនធឺណិតជាតិ ។

១២. កំណត់អំណាចរបស់អាជ្ញាធរឱ្យបានច្បាស់លាស់ថា តើនៅពេលណាអាចតាមដាន និងបិទគេហទំព័រអ៊ីនធឺណិតបានដោយគ្មានដីកាបង្គាប់ពីតុលាការ និងកែសម្រួលច្បាប់ស្តីពី ទូរគមនាគមន៍ឱ្យស្របតាមស្តង់ដារអន្តរជាតិ។

១៣. រៀបចំការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ស្តីពីសេចក្តីព្រាងច្បាប់ដែលប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ ដើម្បីអនុញ្ញាតឱ្យសង្គមស៊ីវិលផ្តល់ធាតុចូល និងធានាឱ្យស្របជាមួយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ រួមទាំងសេចក្តីព្រាងច្បាប់ទាក់ ទងនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សន្តិសុខតាមអ៊ីនធឺណិត និងការការពារទិន្នន័យផ្ទាល់ខ្លួន។

១៤. ធ្វើឱ្យប្រជាពលរដ្ឋកាន់តែងាយស្រួលក្នុងការទទួលបានសេវាអ៊ីនធឺណិត ដើម្បីធ្វើឱ្យប្រាកដថាប្រជាពលរដ្ឋកម្ពុជាទាំងអស់ អាចទទួលបានព័ត៌មានតាមអ៊ីនធឺណិត។ ការងារនេះអាចធ្វើបានតាម រយៈ៖

- ការធានានូវសិទ្ធិទទួលបានសេវាអ៊ីនធឺណិតប្រើប្រាស់ស្មើៗគ្នានៅក្នុង ក្រុមជនងាយរងគ្រោះរួមទាំងស្ត្រី ជនពិការ និង ជនជាតិដើម ភាគ តិច។

- *ការលើកទឹកចិត្តដល់វិស័យទូរគមនាគមន៍ ក្នុងការផ្តល់ជម្រើស ដែលមានតម្លៃទាបទាំងក្នុងទីក្រុង និងតំបន់ជនបទ តាមរយៈ ការកាត់បន្ថយពន្ធ ការឧបត្ថម្ភធន ឬគម្រោង ស្រដៀងគ្នានេះ ។*
- *ការពង្រីកសេវាទូរសព្ទនៅតាម តំបន់ជនបទ អមដោយឥណទាន ឬការឧបត្ថម្ភធនដល់ប្រជាពលរដ្ឋដែលមិនមានលទ្ធភាពទិញសេវាអ៊ីនធឺណិត ឬឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន។*
- *ការបង្កើតមណ្ឌលអ៊ីនធឺណិតសហគមន៍ ជាកន្លែងដែលសមាជិកសហគមន៍អាចប្រើប្រាស់អ៊ីនធឺណិត និងកុំព្យូទ័រដោយ ឥតគិតថ្លៃឬទទួលបានក្នុងតម្លៃទាប។*

*១៩.បង្កើនការអប់រំអក្ខរកម្មឌីជីថល ទាំងនៅតាម ស្ថាប័នអប់រំផ្លូវការ ដូចជាសាលារៀន និងសាកលវិទ្យាល័យ ក៏ដូចជានៅតាមស្ថាប័នអប់រំក្រៅ ផ្លូវការ។ គោលបំណង គឺដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជាអាចបែងចែករវាងប្រភពព័ត៌មានល្អនិងប្រភពព័ត៌មាន មិនល្អព្រមទាំង អាចវាយតម្លៃព័ត៌មានដែលពួកគេទទួលបាន៕*

# II. សេចក្ដីផ្ដើម

សម្រាប់ឆ្នាំទីបួននៃការកត់ត្រារបាយការណ៍នេះ យើងបានកត់សម្គាល់ពីការថយចុះនៃករណីយាយីទៅលើអ្នកសារព័ត៌មាន។

ប៉ុន្តែសេរីភាពសារព័ត៌មាន គឺនៅតែមានកម្រិតទាបបំផុតចាប់តាំងពីប្រទេសកម្ពុជាបានងើបចេញពីសង្គ្រាម នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ដែលភាគច្រើនដោយសារតែការបិទ ឬ បន្សាបឥទ្ធិពលទៅលើស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ការគំរាមកំហែងលើអ្នកសារព័ត៌មាន និងការបោះពុម្ពផ្សាយ ដែលជំទាស់នឹងអាជ្ញាធរ។ ខេមបូចា សង្ឃឹមថា រដ្ឋាភិបាលថ្មី និងអ្នកដឹកនាំជំនាន់ថ្មី នឹងចាត់វិធានការជាក់ស្តែង ដើម្បីការពារអ្នកសារព័ត៌មាន និងផ្លាស់ប្តូរនិន្នាការនេះ ដូចមាននៅក្នុងអនុសាសន៍ដែលបានដាក់ជូនក្នុងរបាយការណ៍នេះស្រាប់។

គួរកត់សម្គាល់ថាប្រទេសកម្ពុជាបានធ្លាក់ពីចំណាត់ថ្នាក់ពី ១៤២ មក១៤៧ ក្នុងចំណោមប្រទេសចំនួន ១៨០ នៅលើសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកក្នុងឆ្នាំ២០២៣។

អ្នកសារព័ត៌មានត្រូវទទួលរងការយាយី ការបំភិតបំភ័យ ការរើសអើង ការគំរាមកំហែងដោយផ្លូវច្បាប់ និងការឃុំខ្លួនដោយគ្រាន់តែសួរសំណួរ ឬជួបបញ្ហា ដែលមិនពាក់ព័ន្ធនឹងខ្លួនប៉ុណ្ណោះ។ ហើយអ្នកប្រព្រឹត្តការយាយីនេះ គឺស្ទើរតែមិនត្រូវបានយកមកឱ្យទទួលខុសត្រូវ។

មានការព្រួយបារម្ភកាន់តែខ្លាំងឡើងថា ការមិនអត់ឱនរបស់រដ្ឋាភិបាល ចំពោះមតិជំទាស់នឹងឈានទៅដល់ការពង្រីកការឃ្លាំមើលតាមអនឡាញ។ ការកើនឡើងនៃការប្រើប្រាស់ទូរសព្ទចល័តបានផ្តល់ឱ្យប្រជាជនកម្ពុជាភាគច្រើន អាចចូលទៅដល់ពិភពនៃព័ត៌មាន។ រដ្ឋាភិបាលនិយាយថា ច្រកទ្វារអ៊ីនធឺណិតជាតិ ជាឧបករណ៍សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែអ្នករិះគន់និយាយថា វាស្រដៀងនឹងប្រព័ន្ធឃ្លាំមើល “Great Firewall” របស់ប្រទេសចិន ដែលជាវិធីសាស្ត្រនៃការពិនិត្យចាប់កំហុសតាមអនឡាញដ៏ធំ។ ខេមបូចានឹងចូលរួមជាមួយសង្គមស៊ីវិលក្នុងការឃ្លាំមើលចំពោះការវិវឌ្ឍនេះ។

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាចែងថា ពលរដ្ឋត្រូវបានធានានូវ “សេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពនៃការបោះពុម្ពផ្សាយ និងសេរីភាពក្នុងការជួបជុំគ្នា”។ ខេមបូចាជឿជាក់ថាការការពារសិទ្ធិទាំងនេះមានសារសំខាន់ណាស់ក្នុងការជំរុញឱ្យមានសក្តានុពលពេញលេញរបស់ប្រទេសជាកន្លែងមួយដែលប្រជាពលរដ្ឋអាចគិត និយាយ និងបញ្ចេញមតិដោយមិនមានការភ័យខ្លាច។



# III. វិធីសាស្ត្រ

## ១. វិធីសាស្ត្រ និងការប្រមូលទិន្នន័យ

របាយការណ៍នេះប្រើវិធីសាស្ត្រប្រមូលទិន្នន័យបែបគុណវិស័យ។ ទិន្នន័យស្តីពីករណីយាយី លើអ្នកសារព័ត៌មាន ត្រូវបានចងក្រងដោយប្រមូលព័ត៌មានអំពីករណី ដែលត្រូវបានរាយការណ៍ដោយស្ថាប័នព័ត៌មានផ្សេងៗ ការបង្ហោះសារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងសេចក្តីប្រកាសព័ត៌មាន ជាសាធារណៈរបស់តុលាការ។ ករណីទាំងនេះត្រូវបានផ្ទៀងផ្ទាត់តាមរយៈការពិនិត្យមើលឯកសារ ដែលមានស្រាប់ ការឃ្លាំមើលដំណើរការកាត់ក្តី និងបទបទសម្ភាសជាមួយមេធាវី អ្នកសារព័ត៌មាន និងសមាជិកគ្រួសាររបស់ពួកគេ។ ចំពោះករណីពាក់ព័ន្ធដែលអ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ខេមបូចាចាត់ទុកករណីទាំងនេះថា ជាការយាយី ប្រសិនបើមានម្នាក់ ឬច្រើននាក់ក្នុងចំណោមអ្នកសារព័ត៌មាន ដែលពាក់ព័ន្ធបដិសេធការចោទប្រកាន់ ឬបទចោទនោះ។ ចំពោះករណីដែលអ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទជំរិតទារប្រាក់ ខេមបូចាបានចាត់ទុកករណីទាំងនេះថា ជាការយាយី បន្ទាប់ពីយើងបានធ្វើការស៊ើបអង្កេត ហើយរកឃើញថា មានការគំរាមកំហែង ឬការប៉ុនប៉ងបំភិតបំភ័យ ដើម្បីធ្វើឱ្យសេរីភាពសារព័ត៌មានចុះខ្សោយ។

ក្នុងនាមជាសមាជិកនៃសម្ព័ន្ធស្ថាប័នសារព័ត៌មានក្នុងតំបន់ ដែលបានចាប់ផ្តើមដំណើរការកាលពីខែធ្នូ ឆ្នាំ២០២២ ដើម្បីរួមគ្នាឃ្លាំមើលការវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (ភាគច្រើនកម្ពុជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ទីម័រឡេស្តេ និងប្រទេសថៃ) វិធីសាស្តឃ្លាំមើលរបស់យើងត្រូវបានកែសម្រួល នៅដើមឆ្នាំ២០២៣ ដើម្បីឲ្យស៊ីចង្វាក់គ្នាជាមួយនឹងសូចនាករក្នុងតំបន់ដែលតាមដានបញ្ហាសុវត្ថិភាពរបស់អ្នកសារព័ត៌មានដោយផ្អែកលើទិដ្ឋភាពសំខាន់បីគឺ៖ សុវត្ថិភាពផ្លូវច្បាប់ សុវត្ថិភាពឌីជីថល និងសុវត្ថិភាពផ្នែករាងកាយ។ យើងក៏កត់ត្រានូវសកម្មភាពនានា ដែលអាចបង្កគ្រោះថ្នាក់ បំភិតបំភ័យ រារាំង ឬបំបិទមាត់អ្នកសារព័ត៌មាន ដោយសារតួនាទីសារព័ត៌មានរបស់ពួកគេ ដោយគ្មានហេតុផលផ្លូវច្បាប់ ឬហេតុផលស្របច្បាប់ ឬរារាំងស្ថាប័នសារព័ត៌មាន ឬអ្នកសារព័ត៌មានមិនឱ្យបំពេញវិជ្ជាជីវៈសារព័ត៌មានរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងដោយឯករាជ្យ ព្រមទាំងសកម្មភាពណាមួយ ដែលអាចមានផលប៉ះពាល់អវិជ្ជមានលើសេរីភាពសារព័ត៌មាន ដែលគួរតែត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍។ ដោយសារការបារម្ភអំពីសន្តិសុខ និងសុវត្ថិភាព ឈ្មោះរបស់អ្នកសារព័ត៌មាន ដែលរងផលប៉ះពាល់ទាំងនោះ និងឈ្មោះប្រភពផ្សេងទៀតមិនត្រូវបានបញ្ចូលក្នុងរបាយការណ៍នេះទេ។

## ២. វិសាលភាព និងដែនកំណត់

របាយការណ៍នេះមានដែនកំណត់ និងគម្លាតខ្វះ។ របាយការណ៍នេះមិនរាប់បញ្ចូលគ្រប់ករណីយាយីលើអ្នកសារព័ត៌មានទាំងអស់ក្នុងឆ្នាំ២០២៣នោះទេ ដោយបញ្ចូលតែករណីដែលត្រូវបានរាយការណ៍ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ហើយដែលត្រូវបានរកឃើញតាមរយៈការស្រាវជ្រាវរបស់ខេមបូចាប៉ុណ្ណោះ។ វាអាចថាមានករណីថ្មីជាច្រើនទៀតមិនត្រូវបានរាយការណ៍ ដោយសារអ្នកសារព័ត៌មានជារឿយៗប្រឈមនឹងការយាយីនៅតាមបណ្តាខេត្តទីដែលករណីទាំងនោះទំនងជាត្រូវបានបន្ត បិទបាំងដោយសារធនធានសម្រាប់ការឃ្លាំមើល និងជំនួយផ្នែកច្បាប់នៅមានកម្រិត។ បញ្ហាប្រឈមមួយទៀត គឺកង្វះទំនាក់ទំនងជាមួយអ្នកសារព័ត៌មានដែលរងផលប៉ះពាល់ឬសមាជិកគ្រួសាររបស់ពួកគេ។

### ៣. ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ពីគោលបំណងនៃការឃ្លាំមើលនេះ ពាក្យគន្លឹះមួយចំនួនដែលប្រើក្នុងរបាយការណ៍នេះត្រូវបានកំណត់ដូចខាងក្រោម៖

"អ្នកសារព័ត៌មាន" គឺសំដៅដល់បុគ្គលិកព័ត៌មានដូចជាអ្នកសារព័ត៌មាន អ្នកសារព័ត៌មានសេរី អ្នកថតរូបសារព័ត៌មាន បុគ្គលិកគាំទ្រ និងអ្នកសម្របសម្រួល អ្នកកាន់បណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬកាន់កាតសម្គាល់ខ្លួនចេញដោយស្ថាប័នព័ត៌មានរបស់ពួកគេ អ្នកដែលសកម្មក្នុងបណ្ដាញសារព័ត៌មានសហគមន៍ និងអ្នកសារព័ត៌មានពលរដ្ឋ។ ពាក្យ"អ្នកសារព័ត៌មាន" នេះមិនរាប់បញ្ចូលអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈនោះទេ។

ការយាយីតាមផ្លូវច្បាប់ គឺសំដៅដល់វិធានការផ្លូវច្បាប់ ឬតុលាការ ការគំរាមកំហែងអ្នកសារព័ត៌មាន រួមទាំងពាក្យបណ្ដឹង ការចោទប្រកាន់ ការឃុំខ្លួនក្នុងពន្ធនាគារ (ការឃុំខ្លួនបណ្ដោះអាសន្នមុនពេលជំនុំជម្រះលើបទចោទជាក់លាក់ ឬការឃុំខ្លួនក្នុងពន្ធនាគារបន្ទាប់ពីការផ្ដន្ទាទោស) ការឃាត់ខ្លួន (ឃាត់ខ្លួនដើម្បីសាកសួរពីរបីម៉ោង ឬពេញមួយយប់ ប៉ុន្តែមិនត្រូវបានចោទប្រកាន់ ឬឃុំខ្លួនក្នុងពន្ធនាគារ) ការព្យួរ ការលុបអាជ្ញាបណ្ណព័ត៌មាន (ការប្រើប្រាស់អំណាចនីតិប្រតិបត្តិ ដើម្បីព្យួរ លុបចោលអាជ្ញាបណ្ណរបស់ស្ថាប័នព័ត៌មានជាក់លាក់មួយដោយគ្មានការកាត់ក្ដីត្រឹមត្រូវ) ការសួរចម្លើយ ការកោះហៅមកសាកសួរ និងការចាប់ខ្លួន (ដែលអាច ឬមិនអាចឈានដល់ការចោទប្រកាន់ជាផ្លូវការ ប៉ុន្តែយ៉ាងហោចណាស់ពាក់ព័ន្ធនឹងការត្រូវអាជ្ញាធរឃាត់ខ្លួនបណ្ដោះអាសន្នដែរ) និងសកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងការប្រើវិធានការផ្លូវច្បាប់ ដើម្បីបំបិទមាត់អ្នកសារព័ត៌មាន និងស្ថាប័នព័ត៌មាន។

ការយាយីលើរាងកាយ គឺសំដៅដល់ករណីវាយដំលើរាងកាយ ការបំផ្លិចបំផ្លាញសម្ភារ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន / ទ្រព្យសម្បត្តិផ្សេងទៀតរបស់ស្ថាប័នព័ត៌មាន ការឃាត់ខ្លួនដោយមិនឆ្លងកាត់នីតិវិធីច្បាប់ ការបៀតបៀនផ្លូវភេទ ការបំភិតបំភ័យលើរាងកាយ និងករណីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកាយវិការ ឬមានបំណងបង្កគ្រោះថ្នាក់ដល់រាងកាយ។

ការយាយីតាមប្រព័ន្ធឌីជីថល គឺសំដៅដល់ករណីនៃការធ្វើបាបតាមប្រព័ន្ធអ៊ីនធឺណិត ការត្រួល ការបំភិតបំភ័យ តាមប្រព័ន្ធអ៊ីនធឺណិត ការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការបិទប្រព័ន្ធអ៊ីនធឺណិត ការលួចចូលក្នុងប្រព័ន្ធកុំព្យូទ័រខុសច្បាប់ ការវាយប្រហារបែប DDos ការបង្ហាញព័ត៌មានឯកជនរបស់អ្នកសារព័ត៌មាន និងការផ្សាយព័ត៌មានមិនពិត ការបង្ខូចកេរ្តិ៍ឈ្មោះ។

ការរឹតត្បិត/ការរើសអើង គឺសំដៅដល់ករណីដែលក្នុងនោះ មន្ត្រី ឬស្ថាប័នបានផ្ដោតគោលដៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ឬរាំងមិនឱ្យចូលយកព័ត៌មានចំពោះអ្នកសារព័ត៌មាន ដែលគេមើលឃើញថា រិះគន់រដ្ឋាភិបាល។ ចំណុចនេះក៏សំដៅដល់ករណី ដែលអាជ្ញាធរបានចេញសេចក្ដីព្រមានមិនផ្លូវការ ឬក៏បញ្ជាឱ្យអ្នកសារព័ត៌មានចាកចេញពីកន្លែងមួយក្នុងបំណងបិទបាំងព័ត៌មានមិនឱ្យចុះផ្សាយ ឬរាំងអ្នកសារព័ត៌មានមិនឱ្យចូលយកព័ត៌មាន។



# IV. ការរកឃើញសំខាន់ៗ

## ១. និន្នាការនៃករណីការយាយីលើអ្នកសារព័ត៌មានពីមួយឆ្នាំទៅ មួយឆ្នាំ

*នៅក្នុងឆ្នាំ២០២៣ អ្នកសារព័ត៌មានបន្តប្រឈមនឹងការយាយីនៅពេលបំពេញការងារ។ ឆ្នាំនេះ ការរាយការណ៍ព័ត៌មានអំពីប្រធានបទចម្រូងចម្រាស ដូចជាការកាប់បំផ្លាញព្រៃឈើ ការបំពុលទឹក និងវិវាទដីធ្លីត្រូវបានភ្ជាប់ជាញឹកញាប់បំផុតទៅនឹងករណីយាយី។*

*ខេមបូចា បានកត់ត្រាករណីយាយីចំនួន៣២ ទៅលើអ្នកសារព័ត៌មានយ៉ាងហោចណាស់ ៥៩នាក់ក្នុងឆ្នាំនេះ។ ប្រភេទនៃការយាយី ដែលជួបប្រទះញឹកញាប់បំផុត គឺការគំរាមកំហែងផ្នែកផ្លូវច្បាប់ ហើយក្នុងនោះ ខេមបូចាបានកត់ត្រារហូតដល់១៥ករណី រួមមានចំណាត់ការផ្លូវច្បាប់ ការដកអាជ្ញាបណ្ណ ការចាប់ខ្លួន ឬដាក់ពន្ធនាគារ។*

*ខេមបូចា ក៏បានកត់ត្រាករណីយាយីផ្នែករាងកាយចំនួន៣ករណី ដូចជាការគំរាមកំហែងប្រើអំពើហិង្សា និងការវាយប្រហារទៅលើឧបករណ៍ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ក៏មាន៩ករណីផ្សេងទៀតនៃការរើសអើងប្រឆាំងនឹងអ្នកសារព័ត៌មាន និង ៥ករណីជាការយាយីតាមអនឡាញដែរ ដូចជាការគំរាម ឬបន្ទុះបង្អាប់តាមអនឡាញ។*

*បើធៀបនឹងឆ្នាំ២០២២ ខេមបូចា បានកត់ត្រាករណីយាយីថយចុះ ៨,៦% ប៉ុន្តែបានសង្កេតឃើញពីការកើនឡើងនៃចំនួនអ្នកសារព័ត៌មានដែលរងការយាយីរហូតដល់ ៩, ៣% ។*

## ករណីការយាយីលើអ្នកសារព័ត៌មានដែលបានកត់ត្រាតាមឆ្នាំនីមួយ។

*ក្នុងរយៈពេលបួនឆ្នាំ (ពីឆ្នាំ២០២០ ដល់ ២០២៣) ខេមបូចាបានកត់ត្រាករណីយាយីលើអ្នកសារព័ត៌មានចំនួន ១៥១ករណី ក្នុងនោះចំនួនអ្នកសារព័ត៌មាននិងអ្នកធ្វើការក្នុងវិស័យសារព័ត៌មានដែលរងផលប៉ះពាល់មានចំនួនយ៉ាងហោចណាស់ ២៨១នាក់ (២១នាក់ជាសារព័ត៌មានស្ត្រី)។*

***តារាងទី១ ៖ ចំនួននៃករណីយាយីលើអ្នកសារព័ត៌មានដែលកត់ត្រាតាមឆ្នាំនីមួយ។***

| ឆ្នាំ | ចំនួនករណី | ចំនួនអ្នកសារព័ត៌មានរងផលប៉ះពាល់ | ចំនួនអ្នកសារព័ត៌មានរងផលប៉ះពាល់ជាស្ត្រី |
|---|---|---|---|
| ២០២០ | ៣៥ | ៧២ | ៣ |
| ២០២១ | ៤៩ | ៩៦ | ៤ |
| ២០២២ | ៣៥ | ៥៤ | ៨ |
| ២០២៣ | ៣៥ | ៥៩ | ៦ |

## ២. ទីតាំងនៃករណីយាយី

***តារាងទី២ ៖ តារាងទីតាំងនៃការយាយីតាមខេត្ត/ក្រុង***

| ខេត្ត/ក្រុង | ចំនួនករណី |
|---|---|
| ភ្នំពេញ | ១២ |
| កណ្តាល | ៦ |
| កំពង់ឆ្នាំង | ១ |
| ព្រះវិហារ | ២ |
| កំពង់ធំ | ១ |
| មណ្ឌលគិរី | ១ |
| បាត់ដំបង | ៣ |
| ក្រចេះ | ២ |
| ពោធិ៍សាត់ | ១ |
| កំពង់ចាម | ១ |
| ស្ទឹងត្រែង | ២ |
| **សរុប** | **៣២** |

## ៣. ប្រភេទនៃករណីយាយី

*តារាងខាងក្រោមនឹងបែងចែកករណីយាយីទាំង៣២ទៅតាមប្រភេទធំៗបី និងប្រភេទផ្សេងទៀត៖*

***តារាងទី៣ ៖ ករណីយាយីដែលបានកត់ត្រាក្នុងឆ្នាំ២០២៣ តាមប្រភេទនីមួយៗ***

| ទិដ្ឋភាពសុវត្ថិភាព | ចំនួនករណី |
|---|---|
| សុវត្ថិភាពផ្នែកច្បាប់ | ១៥ |
| សុវត្ថិភាពផ្នែកឌីជីថល | ៥ |
| សុវត្ថិភាពផ្នែករាងកាយ | ៣ |
| ការរិតត្បិតផ្សេងៗទៀត | ៩ |
| **សរុប** | **៣២** |

## ក. ការយាយីផ្នែកច្បាប់

យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន៣៤នាក់មកពីស្ថាប័នព័ត៌មានអនឡាញចំនួន១៧ផ្សេងគ្នា ប្រឈមនឹងការចោទប្រកាន់ផ្លូវច្បាប់ដែលគ្មានភស្តុតាងច្បាស់លាស់ក្នុងឆ្នាំ២០២៣ រួមទាំងការកោះហៅទៅតុលាការ ការលុបចោលអាជ្ញាបណ្ណព័ត៌មាន ការប្រឈមនឹងការគំរាមកំហែងផ្លូវច្បាប់ ឬការឃុំខ្លួនក្នុងពន្ធនាគារ។ ករណីទាំងនេះកើតឡើងនៅខេត្តបន្ទាយមានជ័យ ស្ទឹងត្រែង ព្រះវិហារ បាត់ដំបង កំពង់ធំ ពោធិ៍សាត់ កណ្តាល ក្រចេះ កំពង់ឆ្នាំង និងរាជធានីភ្នំពេញ។ យ៉ាងហោចណាស់មានអ្នកសារព័ត៌មានអនឡាញចំនួន៥នាក់ត្រូវបានគេប្តឹងចោទប្រកាន់ឬឃុំខ្លួនក្នុងពន្ធនាគារ។ ចាងហ្វាងសារព័ត៌មានអនឡាញម្នាក់ត្រូវបានឃុំខ្លួនរយៈពេល១០ថ្ងៃពីបទចូលប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ។ អ្នកសារព័ត៌មានអនឡាញម្នាក់មកពីស្ថាប័នព័ត៌មាន ASEAN Daily News ត្រូវបានឃុំខ្លួនបណ្តោះអាសន្នរយៈពេល២០ថ្ងៃមុនពេលតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ប៉ុន្តែទោសនេះត្រូវបានព្យួរ។ ចាងហ្វាងសារព័ត៌មានខ្មែរជាយដែនត្រូវបានឃុំខ្លួនរយៈពេល៣ខែ។ លោកត្រូវបានចោទប្រកាន់ពីបទញុះញង់ និងក្លែងឯកសារ។ ចាងហ្វាងសារព័ត៌មាន DN Peace News នៅខេត្តស្ទឹងត្រែង ត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ។

**តារាងទី៤ ៖ ប្រភេទយាយីតាមផ្លូវច្បាប់**

| ប្រភេទករណី | ចំនួនករណី | ចំនួនស្ថាប័ន |
|---|---|---|
| ដកអាជ្ញាបណ្ណ | ៣ | ៦ |
| ការដាក់ពន្ធនាគារ | ៤ | ៤ |
| ការគំរាមផ្សេងៗទៀតតាមផ្លូវច្បាប់ | ៨ | ៧ |
| **សរុប** | **១៥** | **១៧** |

## ១. ចាងហ្វាងសារព័ត៌មានអនឡាញ ជាប់ពន្ធនាគារពីបទចោទថាបានទន្ទ្រានដីព្រៃរបស់រដ្ឋ

*ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ ខេត្តស្ទឹងត្រែង*



កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ ចាងហ្វាងសារព័ត៌មានអនឡាញ DN Peace News នៅក្នុងខេត្តស្ទឹងត្រែង ត្រូវបានកម្លាំងអាវុធហត្ថចាប់ខ្លួន ដោយចោទប្រកាន់ពីបទទន្ទ្រានដីព្រៃរបស់រដ្ឋដើម្បីកាន់កាប់ ដែលបានប្រព្រឹត្តកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥។

កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ តុលាការខេត្តស្ទឹងត្រែង បានកាត់ទោសលោកឱ្យជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ ពីបទចោទថាបានទន្ទ្រានដីរដ្ឋនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។ តាមដីកាចាប់ខ្លួនចេញថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ សាលក្រមនៃសំណុំរឿងនេះត្រូវបានសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំតម្កល់ចាត់ទុកជាបានការនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។

ប្រពន្ធរបស់លោកបាននិយាយថា នៅថ្ងៃដែលប្តីអ្នកស្រីត្រូវបានចាប់ខ្លួន ប្តីអ្នកស្រីបានទទួលទូរសព្ទពីមន្ត្រីកងរាជអាវុធហត្ថខេត្តម្នាក់ដោយអញ្ជើញឱ្យប្តីអ្នកស្រីចូលរួមក្នុងពិធីជប់លាងឡើងឋានន្តរស័ក្តិរបស់មន្ត្រីរូបនោះនៅសណ្ឋាគារ សុខ សម្បត្តិ នៅទីរួមខេត្តស្ទឹងត្រែង ។ ប៉ុន្តែផ្ទុយទៅវិញ ប្តីអ្នកស្រីត្រូវបាននាំទៅកាន់ទីបញ្ជាការកងរាជអាវុធហត្ថខេត្ត ហើយត្រូវបញ្ជូនទៅពន្ធនាគារភ្លាមៗតែម្តង។

ទាំងករិយារបស់ចាងហ្វាង DN Peace News និងចាងហ្វាងរងនៃសារព័ត៌មានDN Peace News បាននិយាយថាអ្នកសារព័ត៌មានរូបនេះធ្លាប់បានឈូសឆាយដីព្រៃកាលពីឆ្នាំ២០១៥ មុនពេលគាត់ចូលធ្វើការជាអ្នកសារព័ត៌មានអនឡាញ ប៉ុន្តែក្រោយមកលោកបានប្រគល់ដីនោះឱ្យរដ្ឋវិញនៅឆ្នាំដដែល។

លោកបានថ្លែងថា អ្នកសារព័ត៌មានរូបនេះថ្មីៗនេះបានរាយការណ៍ព័ត៌មានអំពីការ កាប់ឈើខុសច្បាប់ ជាច្រើនករណីក្នុងខេត្តស្ទឹងត្រែង។

លោកបានឱ្យដឹងថា មុនពេលត្រូវបានចាប់ខ្លួន ចាងហ្វាងរបស់គាត់បានប្រាប់គាត់ថា កាលពីខែមេសា ឆ្នាំ២០២៣ ចៅក្រមស៊ើបសួរតុលាការខេត្តស្ទឹងត្រែងបានប្រាប់ឱ្យគាត់បង់ប្រាក់៥០លានរៀល (ប្រមាណ ១២០០០ដុល្លារ) ជាថ្នូរនឹងការមិនចាប់ខ្លួន។ លោកជឿថាការចោទប្រកាន់មកលើចាងហ្វាងរូបនេះជារូបភាពនៃការគំរាមកំហែង។ លោកបន្តថា ៖«ការងារអ្នកសារព័ត៌មានតែងតែប៉ះពាល់ដល់អាជ្ញាធរ និងអ្នកដែលប្រព្រឹត្តខុស ហើយខ្ញុំជឿថាករណីនេះជាការបំភិតបំភ័យជាជាងការអនុវត្តច្បាប់»។ គាត់បាននិយាយទៀតថា ថ្មីៗនេះសារព័ត៌មានDN Peace News បានចុះផ្សាយករណីកាប់បំផ្លាញព្រៃឈើ[១] នៅក្នុងខេត្ត។

អ្នកសម្របសម្រួលអង្គការសិទ្ធិមនុស្សអាដហុកប្រចាំខេត្ត ស្ទឹងត្រែង ដែលបានស៊ើបអង្កេតលើករណីនេះបានប្រាប់ខេមបូចាថាអ្នកសារព័ត៌មាន បានប្រឈមនឹងបណ្តឹងជាច្រើនករណី បន្ទាប់ពីលោកបានរាយការណ៍ពីបញ្ហារសើបនៅក្នុងខេត្ត[២]។

---

[១] http://tinyurl.com/2j3h7zde

[២] ខេមបូចាធ្វើការសម្ភាសន៍ជាមួយគ្រួសារអ្នកសារព័ត៌មាន ក្រុមការងារ និងមន្ត្រីអាដហុក

## ២. ចាងហ្វាងសារព័ត៌មាន អនឡាញត្រូវបានចាប់ឃុំខ្លួនពីបទលួចចូលទៅក្នុងប្រព័ន្ធទិន្នន័យ

*ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ ភ្នំពេញ*



អគារសាលាយុត្តិធម៌កម្ពុជាដែលមានសាលាឧទ្ធរ និងសាលាតំបូង
រូបថតដោយលោក ព្រីង សំរាង/ខេមបូចា

កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ ចាងហ្វាងទូរទស្សន៍អនឡាញ CNM ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារក្រោមបទចោទប្រកាន់ថាបានលួចចូលដោយខុសច្បាប់ទៅក្នុងប្រព័ន្ធប្រព្រឹត្តកម្មស្វ័យប្រវត្តិនៃទិន្នន័យ ។ ប៉ុន្តែលោកត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃទី ១៤ ខែធ្នូ ក្រោយពីត្រូវបានឃុំឃាំងនៅពន្ធនាគារព្រៃសរ រយៈពេល១០ថ្ងៃ។

លោកត្រូវបានដោះលែងឱ្យនៅក្រៅឃុំបន្ទាប់ពីក្រសួងព័ត៌មានបានចាត់តាំងមេធាវីពីររូបឱ្យការពារក្តីឱ្យលោកកាលពីថ្ងៃទី១២ ខែធ្នូដែលបានស្នើសុំឱ្យលោកបាននៅក្រៅឃុំ។

លោកត្រូវបាននគរបាលចាប់ខ្លួនកាលពីវេលាម៉ោងប្រមាណ ២និង៣០នាទី រសៀលថ្ងៃទី៤ ធ្នូ នៅក្បែរហាងកាហ្វេមួយក្នុងរាជធានីភ្នំពេញ ។ លោកបានធ្វើដំណើរទៅទីនោះដើម្បីជួបតំណាងម្នាក់នៃក្រុមហ៊ុនមួយដែលមិនបញ្ជាក់ឈ្មោះដើម្បីផ្ទៀងផ្ទាត់ឯកសារ ដែលត្រូវបានអះអាងថា មានប្រភពមកពីក្រុមហ៊ុនពាក់ព័ន្ធនឹងអំពើពុករលួយ។ នេះបើតាមប្អូនប្រុសម្នាក់របស់លោក ដែលបានប្រាប់មកខេមបូចា នៅថ្ងៃទី៦ ខែធ្នូ គឺពីរថ្ងៃក្រោយលោកត្រូវបានចាប់ខ្លួន។

ប្អូនប្រុសលោកបាននិយាយថា បន្ទាប់ពីបងប្រុសរបស់ខ្លួន ទទួលបានឯកសារហើយ គាត់ក៏បានទាក់ទងទៅក្រុមហ៊ុនដើម្បីផ្ទៀងផ្ទាត់ ប៉ុន្តែខាងក្រុមហ៊ុនបានបដិសេធនិយាយតាមទូរស័ព្ទ។

លោកបន្តថា បីថ្ងៃក្រោយមក ក្រុមហ៊ុនបានទូរស័ព្ទទៅបងប្រុសរបស់លោកឱ្យមកជួបគ្នាផ្ទាល់នៅហាងកាហ្វេមួយក្នុងសង្កាត់បឹងកេងកង។ ពេលមកដល់ក្បែរហាងកាហ្វេភ្លាម ស្រាប់តែត្រូវបានចាប់ខ្លួនដោយគ្មានការពន្យល់ឡើយ។

មុនពេលជួបគ្នា អ្នកសារព័ត៌មានរូបនោះ បានថតសំឡេងនៃការសន្ទនារវាងខ្លួនគាត់ និងបុរសម្នាក់ ដែលត្រូវបានអះអាងថា ជាតំណាងក្រុមហ៊ុនដើម្បីជួបគ្នានៅហាងកាហ្វេមួយ។ ក្នុងការសន្ទនាសារជាសំឡេងដែលមានរយៈពេល៤នាទី លោកបាននិយាយថា លោកកំពុងធ្វើដំណើរទៅជួបបុរសម្នាក់ ដែលគាត់អះអាងថាជានាយកក្រុមហ៊ុន លី ឈួង ដើម្បីផ្ទៀងផ្ទាត់ប្រភពឯកសារ ដែលលោកបានទទួល។ ក្នុងសំឡេងនោះលោកបានអះអាងថា លោកគ្មានចេតនាទៅជំរិតទារប្រាក់ពីក្រុមហ៊ុននោះទេ។ សំឡេងនោះត្រូវបានគេចែករំលែកនៅលើបណ្តាញសង្គមប៉ុន្មានថ្ងៃបន្ទាប់ពីលោក ត្រូវបានចាប់ខ្លួន ប៉ុន្តែក្រោយមកវាត្រូវបានលុបចោលវិញ។

ក្នុងពេលស៊ើបសួរ អ្នកនាំពាក្យតុលាការតំបូងរាជធានីភ្នំពេញលោក ឫង សុផល បានរៀបរាប់ដោយដឹងថា ព្រះរាជអាជ្ញាបានបញ្ចប់ការស៊ើបអង្កេតពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣។ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ តុលាការបានចេញដីកាឃុំខ្លួនបណ្តោះអាសន្ន[៣]។ ហើយករណីនេះគឺមិនទាន់បានទម្លាក់ការចោទនៅឡើយទេ។

[៣] http://tinyurl.com/4ht8jkht

## ៣. អ្នកសារព័ត៌មានរងការគំរាមកំហែងវិធានការច្បាប់ពីអភិបាលស្រុក ចំពោះការរាយការណ៍ព័ត៌មានពីសំណង់ខុសច្បាប់




រូប screenshot ពីសារព័ត៌មានកោះសន្តិភាពដែលផ្សាយករណីការសាងសង់ខុសច្បាប់

*ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខេត្តបាត់ដំបង*

កាលពីថ្ងៃទី៨ ខែវិច្ឆិកា អ្នកយកព័ត៌មានកោះសន្តិភាព ត្រូវបានអភិបាលស្រុកឯកភ្នំ ខេត្តបាត់ដំបង គំរាមចាត់វិធានការច្បាប់បន្ទាប់ពីលោកបានរាយការណ៍ព័ត៌មានពីសំណង់ដែលអះអាងថា បានសង់បំពានចូលស្ទឹងសង្កែ។

ព័ត៌មាននោះបានរិះគន់ការសម្រេចរបស់អភិបាលស្រុកក្នុងការអនុញ្ញាតឱ្យមានការសាងសង់សំណង់ដោយចាក់ដីចូលទៅផ្នែកខ្លះនៃមាត់ស្ទឹង។

លោកត្រូវបានអាជ្ញាធរស្រុកប្រាប់ថា លោកអភិបាល ស្រុកកំពុងស្វែងរកភស្តុតាង ដើម្បីប្ដឹងលោក ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត។ លោកបាននិយាយថាបន្ទាប់ពីរាយការណ៍ព័ត៌មានរួចមានអ្នកទូរសព្ទមកលោកដោយផ្ដល់ប្រាក់ជាថ្នូរនឹងការដកអត្ថបទចេញ ប៉ុន្តែលោកបានបដិសេធ។

សេចក្ដីបំភ្លឺរបស់អាជ្ញាធរស្រុក ដែលបានបង្ហោះលើទំព័រហ្វេសប៊ុកបានបដិសេធរបាយការណ៍នេះ ដោយអះអាងថាជាព័ត៌មានក្លែងក្លាយ។៦

---

៦ http://tinyurl.com/2c485ek3

## ៤. អ្នកសារព័ត៌មានអនឡាញម្នាក់ប្រចាំខេត្តកំពង់ធំត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារ២ឆ្នាំ

*ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ភ្នំពេញ*

កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ តុលាការខេត្តកំពង់ធំបានកាត់ទោស អ្នកសារព័ត៌មានអនឡាញ ដែលធ្លាប់បម្រើការនៅ TNM News ឱ្យជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ពីបទជំរិតទារប្រាក់។ ទោះយ៉ាងណាក្តី តុលាការបានសម្រេចដោះលែងលោកឱ្យនៅក្រៅឃុំ។

អ្នកសារព័ត៌មាន ដែលបច្ចុប្បន្នធ្វើការឱ្យសារព័ត៌មានអនឡាញមួយទៀតគឺ ASEAN Daily News បាននិយាយថា ការកាត់ទោសនេះ គឺគ្មានមូលដ្ឋាន និងអយុត្តិធម៌ ព្រោះលោកមិនបានប្រព្រឹត្តបទល្មើសទាំងនោះទេ។

លោកបានថ្លែងថា៖ «ពាក្យបណ្តឹងត្រូវបានសរសេរតាមការយល់ឃើញរបស់ពួកគេ ហើយមិនមានភស្តុតាងជាក់លាក់នោះទេ។ ខ្ញុំមានភស្តុតាង និងតឹកតាង ប៉ុន្តែគេមិនទទួលយកទេ។ ខ្ញុំមិនយល់ថាហេតុអ្វីទេ»។

លោកត្រូវបានកងរាជអាវុធហត្ថខេត្តកំពង់ធំចាប់ខ្លួនម្តងកាលពីថ្ងៃទី១០ ខែឧសភា ហើយបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ ពីបទជំរិតទារប្រាក់។ លោកត្រូវបានដោះលែងវិញនៅថ្ងៃទី១ ខែមិថុនាឆ្នាំ ២០២៣ ។

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុន ចាងហ្វាង TNM News បានប្រាប់ខេមបូចាថា អ្នកយកព័ត៌មានរបស់លោកទើបតែចាប់ផ្តើមធ្វើការឱ្យអង្គភាពនេះក្នុងឆ្នាំ២០២១ ប៉ុន្តែការចោទប្រកាន់នេះធ្វើឡើងតាំងពីឆ្នាំ២០២០ មកម្ល៉េះ។

លោកបាននិយាយថា ការចោទប្រកាន់កើតចេញពីការរាយការណ៍ព័ត៌មានជាបន្តបន្ទាប់ ដែលលោកបានសរសេរអំពីការកាប់ឈើខុសច្បាប់នៅខេត្តកំពង់ធំ។

អ្នកសារព័ត៌មានរូបនេះ ត្រូវបានមនុស្សពីរនាក់ឈ្មោះ ស៊ុន វិចិត្រ និងម្នាក់ទៀតឈ្មោះ ហេង នី ដែលត្រូវបានអះអាងថា ជាឈ្មួញរកស៊ីឈើពីរនាក់នៅខេត្តកំពង់ធំប្តឹងពីបទជំរិតទារប្រាក់។ លោកត្រូវបានចោទប្រកាន់តាមមាត្រា ៣៦៣ និង ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

អ្នកសារព័ត៌មានរូបនេះ និយាយថា ពាក្យបណ្តឹង គឺផ្អែកលើវិក្កយបត្រផ្ទេរប្រាក់ចំនួន ៤លើក ដែលដើមបណ្តឹងបានផ្ញើមកឱ្យលោកដើម្បីធ្វើជាភស្តុតាងថា ជាការជំរិតទារប្រាក់។ គាត់បន្តថាលុយនោះគឺគេអោយគាត់សម្រាប់ថ្លៃសាំង ហើយគាត់ក៏មិនបានសុំដែរ។

បច្ចុប្បន្នអ្នកសារព័ត៌មានរូបនេះ បាននឹងប្តឹងឧទ្ធរណ៍[៩] ដើម្បីរកយុត្តិធម៌៕

---

[៩] ខេមបូចា សម្ភាសន៍ជាមួយអ្នកសារព័ត៌មានរងគ្រោះ

# ៩. ប្រព័ន្ធផ្សព្វផ្សាយអនឡាញចំនួនពីរ រងការគំរាមកំហែងដោយចំណាត់ការផ្លូវច្បាប់

## ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ខេត្តពោធិ៍សាត់



មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ បានព្រមានចាត់វិធានការផ្លូវច្បាប់ចំពោះអង្គភាពសារព័ត៌មានអនឡាញចំនួនពីរក្នុងខេត្ត គឺអង្គភាពសារព័ត៌មាន UMA TV និង សារព័ត៌មានស្ទឹករទ្ធ។

កាលពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ មន្ទីរបរិស្ថានខេត្តពោធិ៍សាត់បានចេញលិខិតបដិសេធលើសារព័ត៌មានទាំងពីរនេះ បានចុះផ្សាយករណីប្រជាពលរដ្ឋមានជម្លោះដីធ្លីក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។

អត្ថបទដែលចុះផ្សាយមានចំណងជើងថា៖«មន្ត្រីមន្ទីរបរិស្ថាន និងនគរបាលស្រុក ចាប់ខ្លួនអនីតិជនយកទៅសួរចម្លើយ នៅតុលាការដោយគ្មានដីការ និងមូលហេតុច្បាស់លាស់»។ ប៉ុន្តែរបាយការណ៍នេះត្រូវបានបដិសេធដោយមន្ទីរបរិស្ថាន និងអាជ្ញាធរតាមរយៈការចេញលិខិតច្រានចោល ចុះនៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ ដដែលនោះ។

មន្ទីរបរិស្ថានបានរាយការណ៍ករណីនេះទៅក្រសួងព័ត៌មាន ដើម្បីបង្ខំឱ្យអង្គភាពសារព័ត៌មានទាំងពីរនោះលុបចោលនូវអត្ថបទដែលរិះគន់នោះចេញ។ មន្ទីរបានគំរាមទាមទារឱ្យអង្គភាពសារព័ត៌មានទាំងពីរ បង់ប្រាក់មួយអង្គភាព ចំនួន១០០លានរៀល បើមិនព្រមលុបរបាយការណ៍នោះចេញទេ ។ មន្ទីរបានចោទថា អង្គភាពសារព័ត៌មានទាំងពីរ បានផ្សព្វផ្សាយព័ត៌មានមិនពិត និងញុះញង់អ្នកដទៃឱ្យកាប់រានដីព្រៃ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានអញ្ជើញ និពន្ធនាយករងអង្គភាពសារព័ត៌មាន UMA TV និង ចាងហ្វាងសារព័ត៌មានស្ទឹករទ្ធ ដើម្បីប្រជុំពិភាក្សាពីការអនុវត្តក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន។ ប៉ុន្តែនៅពេលជួបប្រជុំ តំណាងពីក្រសួងព័ត៌មាន បានតម្រូវឱ្យស្ថាប័នសារព័ត៌មានទាំងពីរលុបរបាយការណ៍នោះចេញទៅតាមការស្នើពីមន្ទីរបរិស្ថានខេត្ត។

បន្ទាប់ពីជួបជាមួយតំណាងក្រសួងសារព័ត៌មាន សារព័ត៌មានស្ទឹករទ្ធបានយល់ព្រមលុបអត្ថបទចេញ ព្រោះមានការភ័យខ្លាចរឿងដកអាជ្ញាបណ្ណ។ ចំណែក UMA TV បានបដិសេធមិនព្រមលុបអត្ថបទចេញតាមការទាមទាររបស់ក្រសួងព័ត៌មានដោយអះអាងថា របាយការណ៍ខ្លួនត្រឹមត្រូវ និងជាព័ត៌មានពិត។[៦]

---

[៦] ខេមបូចា សម្ភាសន៍ជាមួយអ្នកសារព័ត៌មានរងគ្រោះ

## ៦. អ្នកសារព័ត៌មានអនឡាញរងបណ្ដឹង និងត្រូវចោទពីបទផ្សាយព័ត៌មានមិនពិត

### *ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០២៣ ខេត្តព្រះវិហារ*

*កាលពីខែតុលា អ្នកសារព័ត៌មានអនឡាញរបស់* IPN Watch *ប្រចាំខេត្តព្រះវិហារ ត្រូវបានលោកស្រី សេង ឌីឡា ដែលត្រូវបានអះអាងថា ជាឈ្មួញឈើ និងលោកព្រាប ធឿត ជាមន្ត្រីយោធា ខេត្តព្រះវិហារ ប្ដឹងពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍។*

*ពួកគេបានទាមទារឱ្យអ្នកសារព័ត៌មានរូបនេះ បង់ប្រាក់ចំនួន ៨,០០០ ដុល្លារជាថ្នូរនឹងការទម្លាក់ពាក្យបណ្ដឹង ។ តុលាការខេត្តព្រះវិហារ បានចេញដីកាចំនួនពីរ និងបង្គាប់ឱ្យសមត្ថកិច្ចនាំខ្លួនអ្នកសារព័ត៌មានទៅតុលាការ។ ដីកាទីមួយចេញនៅថ្ងៃទី១០ ខែតុលា ហើយដីកាទី២ ចេញនៅថ្ងៃទី៦ ខែវិច្ឆិកា។*

*លោកបានប្រាប់ខេមបូចាថា លោកមិនបានប្រព្រឹត្តដូចការចោទប្រកាន់តាមពាក្យបណ្ដឹងនោះទេ។ នៅក្នុងវីដេអូមួយដែលត្រូវបានបង្ហោះនៅលើទំព័រហ្វេសប៊ុក* IPN Watch *លោក បានសម្ភាសគ្រួសារមួយដែលបានអះអាងថា ពួកគេត្រូវបានមន្ត្រីយោធាខេត្តព្រះវិហារបង្ខំឱ្យបង់ប្រាក់ដើម្បីអាចដឹកឈើបាននៅតំបន់នោះ។*[៧]

*ក្នុងវីដេអូមួយទៀត លោកបានរាយការណ៍ថា ឈ្មោះ សេង ឌីឡា ជាឈ្មួញរកស៊ីឈើ ដ៏លេចធ្លោក្នុងខេត្ត។ ចាងហ្វាង* IPN Watch *បាននិយាយថា ស្ថាប័នរបស់លោកឱ្យតម្លៃលើវិជ្ជាជីវៈ ហើយអត្ថបទទាំងអស់ត្រូវបានត្រួតពិនិត្យជាមុន មុននឹងផ្សព្វផ្សាយ។ លោកបានបដិសេធថា សហការីរបស់លោកមិនបានជំរិតទារប្រាក់នោះទេ។*[៨]

*ទោះបីយ៉ាងនេះក្ដីអ្នកសារព័ត៌មានរូបនេះ បានប្រាប់ខេមបូចាថា ដើមបណ្ដឹងបានសម្រេចដកពាក្យបណ្ដឹងវិញ ហើយលោកបានបដិសេធក្នុងការផ្ដល់ព័ត៌មានអំពីមូលហេតុនៃការដកពាក្យបណ្ដឹងនេះ*[៩]*។*

---

[៧] http://tinyurl.com/3r5sapaf

[៨] http://tinyurl.com/3bx95cbd

[៩] *ខេមបូចា សម្ភាសន៍ជាមួយអ្នកសារព័ត៌មានរងគ្រោះ*

## ៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គំរាមចាត់វិធានការផ្លូវច្បាប់ទៅលើខេមបូចា

*ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០២៣ រាជធានីភ្នំពេញ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ញើលិខិតមួយច្បាប់ទៅកាន់និពន្ធនាយកខេមបូចា។ នៅក្នុងលិខិតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចោទ CamboJA News ថាបានរំលោភបំពានក្រមសីលធម៌អ្នកសារព័ត៌មាន ដោយសរសេរគ្មានកស្តុតាងសំអាង និងតាមការស្មាននៅក្នុងអត្ថបទដែលទើបចេញផ្សាយថ្មីៗនេះ។

លិខិតនេះ[១០]ត្រូវបានសរសេរជាការឆ្លើយតបទៅនឹងអត្ថបទមួយដែល ខេមបូចា បានចុះផ្សាយកាលពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០២៣។ អត្ថបទដែលមានចំណងជើងថា គ្រួសារអ្នករិះគន់រដ្ឋាភិបាលដែលត្រូវគេវាយដំដោយហិង្សា ស្វែងរកយុត្តិធម៌គឺ និយាយពីការវាយដំទៅលើអ្នករិះគន់គោលនយោបាយរដ្ឋាភិបាល និងព្រឹត្តិការណ៍ក្រោយការវាយដំ។

លិខិតនោះបានស្នើឱ្យក្រុមសរសេរព័ត៌មានរបស់ខេមបូចា លុបចេញពីអត្ថបទនូវឈ្មោះរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោកឌិត ទីណា ក៏ដូចជាការដកចេញ ការអះអាងគ្មានសមហេតុផល និងការប៉ាន់ស្មាន។ ក្រសួងអះអាងថា ការសរសេរទាំងនេះអាចប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រី ហើយថា អត្ថបទនេះត្រូវបានសរសេរ ដោយមានចេតនាដើម្បីបង្ខូចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងន័យអវិជ្ជមាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គំរាមចាត់វិធានការផ្លូវច្បាប់ទៅលើខេមបូចា ប្រសិនបើសំណើនេះត្រូវបានបដិសេធ ឬប្រសិនបើ ខេមបូចាធ្វើទង្វើដោយ ចេតនាព្យាបាទ និងបង្ខូចកេរ្តិ៍ឈ្មោះ ម្តងទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមានថា ខេមបូចា អាចទទួលបានលទ្ធផលដូចគ្នានឹងវីអូឌី ដែរ។

បន្ទាប់ពីបានពិភាក្សាជាមួយមេធាវី និងក្រុមសរសេរព័ត៌មានរួចមក ខេមបូចាបានសម្រេចចិត្តដកឈ្មោះ ឌិត ទីណា ចេញពីអត្ថបទ ក៏ដូចជាបានកែឈ្មោះប្រកព និងឈ្មោះការីនិពន្ធ ដើម្បីជៀសវាងចំណាត់ការផ្លូវច្បាប់ ដែលនាំឱ្យមានការលុបអាជ្ញាបណ្ណ។[១១]

---

[១០] លិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[១១] http://tinyurl.com/4te58pk7

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
Ministry of Agriculture, Forestry and Fisheries

## Letter to the Editor of CambojaNews

The Ministry of Agriculture, Forestry and Fisheries (MAFF) wishes to express its concerns regarding a recent article published by CambojaNews titled "Family of Violently Beaten Government Critic Seeks Justice dated: 14th September 2023". Specifically, MAFF notes that:

1. The article is credited to an author named Khuon Narim, while it was Jack Brook who contacted the MAFF spokesperson and presented himself as a CambojaNews's journalist. Jack Brook's name is no where to be found in the article, not even as a co-author. Why is Jack Brook not credited to this article?

2. The article depicted Ny Nak as a credible critic of Government policies without examining the substances of his posts which are mostly baseless claims/accusations against Government officials followed by his online sale advertisement.

3. The article speculates that the attack on Ny Nak was politically motivated solely based on his recent baseless posts criticizing Government officials and institutions, and speculations from so-called rights groups. However, there is no evidence to support this claim. A significant portion of the article is dedicated to create connections between Ny Nak's criticism on social media and the assault, raising a question why CambojaNews Jack Brook and Khuon Narim ignored any other possibilities.

4. The article directly inserts the minister's name in the story, even though the minister has never been mentioned by name in any of Ny Nak's recent Facebook posts.

5. Despite receiving comments and explanations from both MAFF and Government spokespersons, Jack Brook failed to substantially include them in the article; instead, he reached out to busy MAFF minister for comment - when everything has been said by the spokespersons - only to highlight in the article that the minister "could not be reached for comment". This is another attempt to link minister's name to the incident.

6. The article quotes Adhoc NGO's employee and includes speculative and defamatory comments with misspelled names: "Soeng Senkarun" and "Senkaruan". MAFF is considering taking legal action against the author of the defamatory comments if found out to be his/hers.

Following notes above, MAFF believes that the article contains unsubstantiated claims and allegations, which raises questions about the professionalism and intentions of CambojaNews especially its authors either Jack Brook or Khuon Narim. MAFF has consistently upheld press freedom and individual rights of expression but maintains a strong stance against media outlets that fail to adhere to professional ethics by disseminating false information or intentionally misleading public opinion based on individuals false claims and speculations.

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

លិខិតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្ញើរមកខេមបូចា

## ៨. អង្គភាពផ្សព្វផ្សាយចំនួនពីរត្រូវបានបង្ខំឱ្យលុបចោលអត្ថបទដែលចោទមន្ត្រីយោធាម្នាក់ថាបានរំលោភដីបឹងសាធារណៈ

### ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០២៣ ខេត្តក្រចេះ

អ្នកសារព័ត៌មានអនឡាញ ពីរនាក់មកពីអង្គភាពព័ត៌មានអនឡាញ RSE-News និង Newnetwork ប្រចាំខេត្តរតនគិរី ត្រូវបានអាជ្ញាធរខេត្តក្រចេះ ប្តឹងពីបទញុះញង់ និងបរិហារកេរ្តិ៍ រឿងនេះបានកើតឡើង បន្ទាប់ពីអ្នកសារព័ត៌មានបានរាយការណ៍ព័ត៌មានម្តងហើយម្តងទៀតអំពីការចាក់ដីលុបផ្នែកខ្លះនៃបឹងសាធារណៈក្នុងស្រុកស្នួល ខេត្តក្រចេះ។

នាយកសារព័ត៌មានរាជសីហ៍ឥសាន និង នាយកសារព័ត៌មានNewnetwork បានបញ្ជាក់ថាពួកគេបានទទួលលិខិតកោះហៅពីមេប៉ុស្តិ៍នគរបាលឃុំ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣។ លិខិតនេះត្រូវបានចេញដោយតុលាការខេត្តក្រចេះ និងមានដីកាកោះឱ្យចូលខ្លួនទៅតុលាការនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣។

ទាំងសារព័ត៌មាន RSE News និង Newnetwork បានរាយការណ៍ព័ត៌មានម្តងហើយម្តងទៀតថា លោក យន់ សុវណ្ណ ដែលគេស្គាល់ថាជាមន្ត្រីយោធាម្នាក់នៅស្រុកស្នួល បានបំពុលបឹងសាធារណៈដោយចាក់ដីលុបដើម្បីអភិវឌ្ឍរមណីយដ្ឋាន និងក្លិបខេធីវី (KTV) ។ បឹងនេះត្រូវបានគេដឹងថា កសាងឡើងក្នុងរបបប៉ុលពត ហើយគេច្រើនតែប្រើប្រាស់ស្រះទឹកនេះ ដើម្បីបម្រើផលប្រយោជន៍ដល់ជនជាតិដើមភាគតិចនៅតំបន់នេះ។

នាយកសារព័ត៌មានទាំងពីរ បាននិយាយថាលោកបានរាយការណ៍អំពីករណីចាក់ដីលុបបឹងនេះ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ដោយបានសម្ភាសអ្នកពាក់ព័ន្ធ។ លោកថា ក្រោយចេញផ្សាយព័ត៌មាន ស្រាប់តែលោកអភិបាលខេត្តបានណែនាំឱ្យមន្ទីរធនធានទឹក និងឧតុនិយមខេត្តក្រចេះ ស៊ើបអង្កេតករណីនេះ ប៉ុន្តែនៅតែមិនអាចដោះស្រាយបានទេ។

នាយកសារព័ត៌មាន RSE Newsបាននិយាយថា លោកបន្តរាយការណ៍ព័ត៌មានអំពីករណីនេះរហូតដល់ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២៣។ ពីរសប្តាហ៍ក្រោយមក លោកបានទទួលដីកាកោះហៅពីតុលាការខេត្តក្រចេះឱ្យចូលខ្លួនទៅតុលាការនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២៣។

លោកបានឱ្យដឹងថា លោកយ៉ាន់ សុវណ្ណបានស្នើឱ្យខ្លួនដកអត្ថបទចេញ បើមិនដូច្នេះទេត្រូវប្រឈមនឹងវិធានការផ្លូវច្បាប់។ លោកបានបន្តថា ពាក្យបណ្តឹងត្រូវបានដកចេញពីតុលាការបន្ទាប់ពីពួកគេបានយល់ព្រមដកអត្ថបទនោះចេញ។[១២]

[១២] ខេមបូចា សម្ភាសន៍ជាមួយអ្នកសារព័ត៌មានរងគ្រោះ

## ៩. ភ្នាក់ងារសារព័ត៌មានកោះសន្តិភាពប្រចាំខេត្តបាត់ដំបង ប្រឈមនឹងការយាយី ខណៈរាយការណ៍ពីការបំពុលទឹកស្ទឹងសង្កែ

### ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ខេត្តបាត់ដំបង

ភ្នាក់ងារសារព័ត៌មានរបស់កាសែតកោះសន្តិភាព ប្រចាំខេត្តបាត់ដំបងទទួលរងការយាយីពីសំណាក់អាជ្ញាធរខេត្តបាត់ដំបង ដែលគំរាមប្ដឹងគាត់ បន្ទាប់ពីគាត់បានរាយការណ៍ព័ត៌មានម្ដងហើយម្ដងទៀតទាក់ទងនឹងរោងចក្រចិននៅស្ទឹងសង្កែ ដែលបណ្ដាលបង្កឱ្យមានការបំពុលទឹកក្នុងតំបន់ជុំវិញនោះ។

អ្នកសារព័ត៌មានរូបនេះ បាននិយាយថា កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ មន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងបានទូរសព្ទមកប្រាប់លោកថា អភិបាលខេត្តបាត់ដំបង គឺលោក សុខ លូ បានបញ្ជាឱ្យសមត្ថកិច្ចស៊ើបអង្កេតសាវតារបស់លោក។ ពួកគេបាននិយាយថា គេធ្វើបែបនេះដើម្បីរៀបចំដាក់ពាក្យបណ្ដឹងញុះញង់ទាក់ទងនឹងការរាយរបាយការណ៍ព័ត៌មានរបស់គាត់អំពីការបំពុលស្ទឹងសង្កែដោយរោងចក្រចិន។ មន្ត្រីនគរបាលបាននិយាយថា វាប៉ះពាល់ដល់សមត្ថកិច្ច។

លោកបានរាយការណ៍ព័ត៌មានជាបន្តបន្ទាប់ ទាំងបង្ហោះនៅលើគេហទំព័រព័ត៌មានកោះសន្តិភាព ទាំងនៅលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនរបស់លោក ដោយរិះគន់អាជ្ញាធរថាមិនបានដោះស្រាយការបំពុលទឹកស្ទឹង។

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ក្រសួងបរិស្ថានបានបង្ហាញភស្តុតាងថារោងចក្រចិនឈ្មោះ Phoenix Industry Co,Ltd ដែលមានទីតាំងនៅក្នុងភូមិផ្អាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ពិតជាបានបង្កការបំពុលទឹកនៅក្នុងស្ទឹងសង្កែមែន។[១៣]

បន្ទាប់ពីប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍អំពីបញ្ហានេះ ពួកគេបានបង្ហាញពីការបាត់បង់ជីវៈចម្រុះនៃទឹកស្ទឹង ក៏ដូចជាការពិតដែលវាបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនជាច្រើន។ ក្រសួងបានផាកពិន័យរោងចក្រជាទឹកប្រាក់ចំនួន ៤០ម៉ឺនដុល្លារ និងបញ្ជាឱ្យរោងចក្រនេះរុះរើចេញយ៉ាងតិច ១០ គីឡូម៉ែត្រពីមាត់ស្ទឹងសង្កែ។[១៤]

---

[១៣] http://tinyurl.com/34v7mejm

[១៤] http://tinyurl.com/5ejdenbt

## ១០. អ្នកនាំពាក្យក្រសួងមហាផ្ទៃ ព្រមានអ្នកយកព័ត៌មានខេមបូចា ទាក់ទងនឹងការរាយការណ៍ព័ត៌មានពីគណបក្សភ្លើងទៀន

### ថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០២៣ ភ្នំពេញ

អ្នកយកព័ត៌មានខេមបូចា បានរងការគំរាមដោយពាក្យសំដីពីអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ ក្នុងបទសម្ភាសន៍តាមទូរសព្ទកាលពីថ្ងៃទី ២៩ ឧសភា។ លោក សុភ័គ បានព្រមានអ្នកយកព័ត៌មានថា លោកអាចជាប់គុក ដោយសារសួរសំណួរអំពីគណបក្សភ្លើងទៀន ។

លោក សុភ័គ និយាយថា «[សួរ] គ្មានន័យអញ្ចឹង អ្នកសារព័ត៌មានចង់ចូលគុក?»

នេះមិនមែនជាលើកទីមួយទេដែលអ្នកសារព័ត៌មានខេមបូចារងការព្រមាន ឬការគំរាមពីមន្ត្រីក្រសួងមហាផ្ទៃរូបនេះ។ ក្នុងខែឧសភាដដែល លោក ណារឹម រងការព្រមានបីដងពីលោក សុភ័គ ពេលកំពុងរាយការណ៍ព័ត៌មានអំពីបក្សប្រឆាំងគណបក្សភ្លើងទៀន។

កាលពីថ្ងៃទី១២ ឧសភា អ្នកយកព័ត៌មានខេមបូចា បានហៅទូរសព្ទទៅលោក សុភ័គ ដោយសួរថា ហេតុអ្វីបានជាក្រសួងមហាផ្ទៃមិនផ្តល់លិខិតច្បាប់ដើមចុះបញ្ជីគណបក្សភ្លើងទៀន ប៉ុន្តែបែរជាចេញលិខិតបញ្ជាក់ទៅវិញ។

លោក សុភ័គ ក៏ឆ្លើយថា «តើលោកឯងនៅជាមួយបក្សភ្លើងទៀន? តើខេមបូចាកាន់ជើងគណបក្សភ្លើងទៀន? លោកឯងត្រូវសួរក្នុងនាមអ្នកសារព័ត៌មាន គឺមិនមែនក្នុងនាមជាអ្នកនាំពាក្យរបស់បក្សភ្លើងទៀនទេ។»

លោកនិយាយបន្តថា «សូមធ្វើជាអ្នកសារព័ត៌មានអាជីព ហើយកុំធ្វើជាអ្នកសារព័ត៌មានស៊ីឈ្នួលបម្រើបរទេស។ តើនរណាឱ្យលុយខេមបូចា?»

កាលពីថ្ងៃទី៩ ខែឧសភា បន្ទាប់ពីមានកិច្ចប្រជុំរវាងក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំគណបក្សភ្លើងទៀន លោក ណារឹម ហៅទូរសព្ទទៅលោក សុភ័គ ដើម្បីសាកសួរអំពីលទ្ធផលនៃកិច្ចប្រជុំនោះ។[១៩]

ទោះជាយ៉ាងនេះក្តី លោក សុភ័គ បានចោទសួរលោកអ្នកសារព័ត៌មាន អំពីប្រភពមូលនិធិ ដែលខេមបូចាទទួលបានទៅវិញ។

លោក សុភ័គ បាននិយាយថា «តើលោកឯងបានប្រាក់ខែពីអ្នកណា? លោកឯងត្រូវតែដឹងពីប្រភពមូលនិធិ។ ខ្ញុំចង់សួរថា តើអ្នកណាគាំទ្រខេមបូចា? តើខេមបូចា ទទួលបានមូលនិធិពីណា ដើម្បីធ្វើការងារនោះ?»

លោក សុភ័គ បានបន្តថា «ខ្ញុំនឹងមិនផ្តល់ព័ត៌មានទេ លោកឯងក៏មិនដឹងថាលោកឯងជាអ្នកណាដែរ។ ខ្ញុំក៏មិនដឹងថា ខេមបូចាមកពីណាដែរ អញ្ចឹងតើឱ្យខ្ញុំផ្តល់ព័ត៌មានដល់លោកឯងយ៉ាងម៉េចទៅ? ក្នុងនាមជាអ្នកសារព័ត៌មាន លោកឯងត្រូវតែបង្ហាញអត្តសញ្ញាណខ្លួនឯង» ។

---

[១៩] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

## ១១. ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ៣អង្គភាព បន្ទាប់ពីរាយការណ៍ពីមន្ត្រីជាន់ខ្ពស់ម្នាក់ដែលមានជាប់ពាក់ព័ន្ធនឹងការបន្លំយកដីធ្លី។

*ថ្ងៃទី ១៦ មីនា ឆ្នាំ ២០២៣ ភ្នំពេញ*

*ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណរបស់ប្រព័ន្ធផ្សព្វផ្សាយ៣អង្គភាពកាលពីខែមីនា បន្ទាប់ពីអង្គភាពទាំងនេះបានចេញផ្សាយព័ត៌មានលាតត្រដាងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ម្នាក់ដែលជាប់ពាក់ព័ន្ធនឹងការលួចបន្លំយកដីធ្លី។ ក្រសួងបញ្ជាក់ថា អង្គភាពព័ត៌មានអនឡាញជាភាសាខ្មែរ គឺសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន រស្មីកំពង់ចាម និងដំណឹងក្នុងស្រុក បានប្រព្រឹត្តកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ និងមិនព្រមអនុវត្តតាមការណែនាំរបស់ក្រសួងជាអាណាព្យាបាល។*

*ប្រធាន និងជាចាងហ្វាងរបស់សហព័ន្ធអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន បានសម្តែងការខកចិត្តដែលក្រសួងព័ត៌មានបានដកអាជ្ញាបណ្ណអង្គភាពសារព័ត៌មានរបស់លោក ដោយគ្មានការពន្យល់ច្បាស់លាស់ទាល់តែសោះ។*

*លោកបានប្រាប់ ខេមបូចាថា“យើងសោកស្តាយចំពោះបញ្ហានេះ។ សូមបង្ហាញបញ្ហាឱ្យច្បាស់មកថា យើងបានធ្វើកំហុសអ្វី។*

*លោកបាននិយាយថា ក្រសួងព័ត៌មានបានកោះហៅគាត់មកប្រជុំកាលពីខែកុម្ភៈ ហើយបានស្នើឱ្យគាត់ដកអត្ថបទដែលចោទថាមន្ត្រីរដ្ឋាភិបាលបានក្លែងបន្លំឯកសារយកដីធ្លី និងករណីមួយទៀតពាក់ព័ន្ធនឹងការជំរិតទារប្រាក់ពីគ្រួសារក្រីក្រ។*

*របាយការណ៍មួយដែលបានចុះផ្សាយក្នុងអង្គភាពសារព័ត៌មានទាំងបី បានចោទថា សមាជិកសភាជាន់ខ្ពស់នៃគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច គឺលោក ស ចំរ៉ុង អតីតអភិបាលរងខេត្តបន្ទាយមានជ័យ បានក្លែងបន្លំឯកសារ ដើម្បីទទួលបានដីជាង ៦០ ហិកតា នៅខេត្តបន្ទាយមានជ័យ។*

*លោក បាននិយាយថា លោក សរ ចំរ៉ុង បានប្តឹងទៅក្រសួងព័ត៌មានអំពីការចុះផ្សាយនេះ។*

*លោក ចំរ៉ុង ជាប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃរដ្ឋសភា។ កាលពីខែកុម្ភៈ ឆ្នាំ ២០២០ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានដឹកនាំគណៈប្រតិភូទៅគោរពវិញ្ញាណក្ខន្ធក្នុងពិធីបុណ្យសពម្តាយរបស់ ចំរ៉ុង។*

*ខេមបូចា មិនអាចទាក់ទងលោក ចំរ៉ុង ដើម្បីសុំការបំភ្លឺបានទេក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍។*

*ចាងហ្វាងរូបនោះនិយាយថា ក្រសួងព័ត៌មានបានអះអាងថា អត្ថបទនេះបានធ្វើឱ្យខូចកិត្តិយសមន្ត្រីរដ្ឋសភា។*

*លោកបានបន្តថា “ខ្ញុំបានឆ្លើយថា ខ្ញុំមិនអាចលុបព័ត៌មាននោះចេញបានទេ ព្រោះវាជាព័ត៌មានពិត ជាពិសេស ជាការកុហកចំពោះអតីតនាយករដ្ឋមន្ត្រីលោក ហ៊ុន សែន”។*

*អត្ថបទមួយទៀតចុះផ្សាយក្នុងអង្គភាពសារព័ត៌មានទាំងបីបានរាយការណ៍ថា ព្រះរាជអាជ្ញារងខេត្តតាកែវម្នាក់បានរឹបអូសទ្រព្យសម្បត្តិពីអ្នកភូមិបីគ្រួសារដែលបានទិញពីខេត្តរតនគិរី ហើយទាមទារឱ្យអ្នកភូមិបង់ប្រាក់ឱ្យព្រះរាជអាជ្ញារូបនោះដើម្បីបានទ្រព្យនោះមកវិញ។*

*ចាងហ្វាងដំណឹងក្នុងស្រុក បានចុះផ្សាយអត្ថបទដូចគ្នានេះ រួមមានទាំងវីដេអូ ដែលមានអ្នកចូលមើលជាង ១៦៩,០០០ ដងនៅលើហ្វេសប៊ុក។ លោកនិយាយថា ក្រសួងព័ត៌មានបានស្នើឱ្យលោកដកអត្ថបទចេញ តែលោកបដិសេធ។*

លោកបន្តថា៖«យើងបានចុះផ្សាយព័ត៌មានពិតរបស់អ្នកភូមិ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃ»។

អ្នកនាំពាក្យក្រសួងព័ត៌មានបានបដិសេធថា ក្រសួងមិនបានស្នើឱ្យអ្នកសារព័ត៌មានដកអត្ថបទចេញនោះទេ។ លោកបានមានប្រសាសន៍ថា អង្គភាពសារព័ត៌មានបានផ្សាយ "ព័ត៌មានមិនពិត" ហើយបានចោទមន្ត្រីថាបានអនុវត្តតាមការបញ្ជាពីភាគីខាងក្រៅ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។

បន្ទាប់ពីលុបអាជ្ញាបណ្ណសារព័ត៌មានដំណឹងក្នុងស្រុក បានបង្ហោះសារ លាអ្នកតាមដានព័ត៌មានតាមទំព័រហ្វេសប៊ុករបស់ខ្លួន។

ដំណឹងក្នុងស្រុកបានសរសេរថា«សូមលាបងប្អូនអាជីពអ្នកសារព័ត៌មានទូទាំងព្រះរាជាណាចក្រកម្ពុជាដែលកំពុងស្រឡាញ់វិស័យសារព័ត៌មាន សូមឱ្យមានសុខភាពល្អ នឹងជួយបន្តការផ្សព្វផ្សាយព័ត៌មានពិតជូនសង្គមជាតិ ដើម្បីមាតុភូមិ"។[១៦]

## ១២. អតីតនាយករដ្ឋមន្ត្រីលោក ហ៊ុន សែន បិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យVOD

### ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ ភ្នំពេញ

អតីតនាយករដ្ឋមន្ត្រី លោកហ៊ុន សែនបានប្រកាសថា រដ្ឋាភិបាលបានលុបចោលអាជ្ញាបណ្ណផ្សាយព័ត៌មាន VOD តាមហ្វេសប៊ុកកាលពីខែកុម្ភៈ បន្ទាប់ពីលោកបានទាមទារការសុំទោសចំពោះអត្ថបទដែលលោកអះអាងថាមិនត្រឹមត្រូវ។

អតីតនាយរដ្ឋមន្ត្រីបានសរសេរនៅលើទំព័រហ្វេសប៊ុករបស់លោកថា "ខ្ញុំបានសម្រេចចិត្តបញ្ចប់បញ្ហានេះដោយឱ្យក្រសួងព័ត៌មានលុបចោលអាជ្ញាបណ្ណ VOD ចាប់ពីពេលនេះទៅ និងត្រូវបញ្ចប់ការផ្សាយត្រឹមម៉ោង ១០ ព្រឹក ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣ជាកំហិត។ យើងបិទការផ្សាយគ្រប់ទម្រង់"។

ពីរថ្ងៃមុនដកអាជ្ញាបណ្ណ លោក ហ៊ុន សែន បានបញ្ជាឱ្យសារព័ត៌មាន VOD សុំទោស និងដកចេញនូវអត្ថបទជាភាសាខ្មែរ ដែលបានចុះផ្សាយកាលពីថ្ងៃទី៩ ខែកុម្ភៈ។ អត្ថបទបានរាយការណ៍ថា លោក ហ៊ុន ម៉ាណែត បានចុះហត្ថលេខាជំនួសឪពុកលើការផ្តល់ជំនួយចំនួន ១០ ម៉ឺនដុល្លារដល់ប្រទេសតួកគីដែលរងគ្រោះដោយការរញ្ជួយដី។

លោកផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលត្រូវបានដកស្រង់សំដីនៅក្នុងអត្ថបទជាភាសាខ្មែរថា "វាមិនខុសទេដែលលោកហ៊ុន ម៉ាណែត ដើរតួនាទីជំនួសឪពុកក្នុងការផ្តល់ជំនួយដល់ប្រទេសតួកគីនោះ"។

ប៉ុន្តែលោកហ៊ុន ម៉ាណែត បានបដិសេធរឿងនេះ ដោយលោកបានបង្ហោះសារតាមបណ្តាញសង្គមជាបន្តបន្ទាប់ថា លោកមិនបានចុះហត្ថលេខាលើឯកសារនោះទេ។ លោកហ៊ុន ម៉ាណែត បានទាមទារឱ្យមានការកែតម្រូវអត្ថបទជាបន្ទាន់ ហើយក៏ឱ្យវីអូឌី ផ្តល់ភស្តុតាងនៃការចុះហត្ថលេខាលើឯកសារផ្តល់ជំនួយនេះដែរ។

កាលពីថ្ងៃទី១១ ខែកុម្ភៈ លោកហ៊ុន សែនបានបង្ហោះសារនៅលើទំព័រហ្វេសប៊ុករបស់លោកដោយទាមទារឱ្យ VOD ចេញលិខិតសុំទោសជាសាធារណៈចំពោះរដ្ឋាភិបាល និងកូនប្រុសរបស់លោកក្នុងរយៈពេល៧២ម៉ោង បើមិនដូច្នេះទេ

---

[១៦] https://bit.ly/40nhlpl

VODប្រឈមមុខនឹងការលុបចោលអាជ្ញាបណ្ណសារព័ត៌មាន។ ប៉ុន្តែក្រោយមកលោកបានបន្ថយរយៈពេលនៃឱសានវាទមកនៅត្រឹមម៉ោង ១០ ព្រឹកថ្ងៃទី ១៣ ខែកុម្ភៈ។

បុគ្គលិកមកពីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ជាអង្គការមិនមែនរដ្ឋាភិបាលគ្រប់គ្រងលើការផ្សព្វផ្សាយព័ត៌-មាន VOD បានជួបជាមួយក្រសួងព័ត៌មាននៅព្រឹកថ្ងៃអាទិត្យទី១២ កុម្ភៈ ប៉ុន្តែស្ថានការណ៍មិនអាចបានដោះស្រាយទេ។

បន្ទាប់ពីការប្រានចោលពីលោកហ៊ុន ម៉ាណែត សារព័ត៌មាន VOD ជាភាសារខ្មែរ បានចុះផ្សាយអត្ថបទបន្តមួយដោយបញ្ជាក់ថា លោកហ៊ុន ម៉ាណែត បានបដិសេធថាមិនបានចុះហត្ថលេខាលើឯកសារនេះទេ ហើយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏បានផ្ញើលិខិតមួយច្បាប់ទៅលោកហ៊ុន សែន ព្រឹកថ្ងៃអាទិត្យទី១២ ដោយបញ្ជាក់ថាខ្លួនមានការសោកស្ដាយចំពោះ“ការភ័ន្តច្រឡំ” ដែលបណ្ដាលមកពីអត្ថបទនោះ។

នៅម៉ោង៧យប់ ថ្ងៃដដែល លោកហ៊ុន សែន បានបង្ហោះសារតាមហ្វេសប៊ុករបស់លោក ដោយបញ្ជាឱ្យក្រសួងព័ត៌មានលុបចោលអាជ្ញាបណ្ណ VOD។ លោកមានប្រសាសន៍ថា លោកមិនពេញចិត្តនឹងការឆ្លើយតបរបស់ VOD ចំពោះឱសានវាទរបស់លោក ដោយលោកកត់សម្គាល់ថា សារព័ត៌មាននេះបានបដិសេធការសុំទោស ហើយមិនព្រមប្រើប្រាស់ពាក្យដែលលោកចង់បាន។

រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានបង្ហោះសារនៅលើទំព័រហ្វេសប៊ុករបស់លោកថា គេហទំព័រប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតគួរតែយករឿងនេះជាមេរៀន។

លោកបានថ្លែងថា៖ «វាជាមេរៀនមួយសម្រាប់ស្ថាប័នសារព័ត៌មានផ្សេងទៀត។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយដែលមិនព្រមផ្សព្វការបំភ្លឺ [ពួកគេ] ប្រឈមនឹងការលុបចោលអាជ្ញាបណ្ណរបស់ពួកគេ»។

ក្រុមអ្នកអត្ថាធិប្បាយសង្គមបានសម្ដែងការសោកស្ដាយតាមបណ្ដាញសង្គមចំពោះការបាត់បង់ VOD ហើយបានកត់សម្គាល់ថាពេលវេលានៃការបិទនេះ គឺកើតឡើងមុនការបោះឆ្នោតជាតិ នៅខែកក្កដា និងភ្លាមៗបន្ទាប់ពីមេដឹកនាំជាន់ខ្ពស់មកពីគណបក្សភ្លើងទៀនប្រឈមមុខនឹងបណ្ដឹង ការចាប់ខ្លួន និងការបំភិតបំភ័យ។

អ្នកយកព័ត៌មានជាន់ខ្ពស់VOD បាននិយាយថា លោកមានការខកចិត្តជាខ្លាំង ហើយសង្ឃឹមថាដំណោះស្រាយនៅតែអាចមាន។

លោកនិយាយថា៖ «ធម្មតាតួនាទីរបស់អ្នកសារព័ត៌មាន ពេលគេឮព័ត៌មានអ្វី គេរាយការណ៍ជាសាធារណៈ។ យើងមិនមានចេតនាអាក្រក់ចំពោះអ្នកណាម្នាក់ទេ។ វាគ្រាន់តែជាការផ្ដល់ព័ត៌មានដល់សាធារណជនប៉ុណ្ណោះ»។[១៧]

---

[១៧] http://tinyurl.com/4a5u7jn3

## ១៣. អ្នកសារព័ត៌មានអនឡាញត្រូវបានចាប់ខ្លួនបន្ទាប់ពីថតរូបការរត់ពន្ធបារី

### ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០២៣ ៣ ខេត្តកណ្តាល

អ្នកសារព័ត៌មានអនឡាញ Sangkom Pachabon ត្រូវបាននគរបាលមួយក្រុមចាប់ខ្លួនកាលពីថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០២៣ បន្ទាប់ពីគាត់បានរាយការណ៍ព័ត៌មានអំពីការរត់ពន្ធបារីនៅក្នុងខេត្តកណ្តាល។

តាមអ្នកយកព័ត៌មានវ័យ៣០ឆ្នាំរូបនេះ គាត់បានឃើញបុរសរត់ពន្ធបារីឆ្លងកាត់ព្រំដែនកម្ពុជាវៀតណាមតាមច្រកព្រំដែនភូមសំណរដោយចៃដន្យ ពេលគាត់ទៅលេងសាច់ញាតិនៅទីនោះ។

លោកបានប្រាប់ ខេមបូចា តាមរយៈបទសម្ភាសន៍តាមទូរស័ព្ទថា លោកបានថតរូបភាពសកម្មភាពរត់ពន្ធនេះ ហើយបានទៅប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ភូមសំណរ ដើម្បីរាយការណ៍ករណីនេះ ប៉ុន្តែនគរបាលបានបង្វែរគាត់ឱ្យទៅរាយការណ៍ទៅមេរបស់ពួកគេវិញ។ លោក បាននិយាយថា គាត់មិនបានធ្វើតាមការណែនាំទេ ហើយក៏បានចាកចេញពីប៉ុស្តិ៍នគរបាល។

នៅពេលត្រឡប់មកពីប៉ុស្តិ៍នគរបាល គាត់បាននិយាយថា នគរបាលជាង១០នាក់បានជិះម៉ូតូតាមគាត់ ហើយបញ្ជាឱ្យឈប់។ លោក ត្រូវបានគេនាំទៅប៉ុស្តិ៍នគរបាល ហើយត្រូវបានចោទថា ចុះយកព័ត៌មានដោយគ្មានលិខិតបេសកកម្ម និងមិនបានផ្តល់ដំណឹងដល់នគរបាល មុនពេលបំពេញការងារជាសារព័ត៌មាន។

អ្នកសារព័ត៌មានរូបនោះ បានប្រាប់ខេមបូចាថាគាត់ត្រូវបង្ខំចិត្តទទួលស្គាល់ជាលាយលក្ខណ៍អក្សរថាគាត់ខុស ហើយបានលុបរូបភាពដែលគាត់បានថតជាថ្នូរនឹងការដោះលែង។[១៨]

## ១៤. អ្នកសារព័ត៌មានពលរដ្ឋម្នាក់ត្រូវបានចាប់ខ្លួន និងបង្ខំឱ្យលុបរូបថត

### ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ខេត្តកំពង់ឆ្នាំង

អ្នកសារព័ត៌មានពលរដ្ឋ ដែលជាសកម្មជនដីធ្លីនៃសហគមន៍ឡពាង ត្រូវបានចាប់ខ្លួន នៅពេលគាត់កំពុងថតរូបសមាជិកសហគមន៍ឡពាង ប្រមាណ៩០នាក់ ដែលប្រមូលផ្តុំគ្នាតវ៉ានៅមុខតុលាការខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។

លោកនិយាយថា គាត់ត្រូវបាននគរបាលខេត្តចំនួន៤នាក់ រុញចូលក្នុងឡាន តាមបញ្ជារបស់ព្រះរាជអាជ្ញា ដោយចោទគាត់ថា បានថតរូបដោយគ្មានការអនុញ្ញាត ហើយក៏បញ្ជូនលោកទៅស្នងការដ្ឋាននគរបាលខេត្ត ហើយគេបញ្ជាឱ្យគាត់លុបរូបថតទាំងអស់ចោល។

លោកបាននិយាយថា នគរបាលបានរឹបអូសទូរសព្ទចំនួន ៣ គ្រឿង គឺមួយគ្រឿងពីគាត់ និងពីរគ្រឿងទៀតពីអ្នកតវ៉ា។

លោកត្រូវបានដោះលែងប្រហែលពីរម៉ោងក្រោយមក បន្ទាប់ពីគាត់បានលុបរូបថតចេញពីទូរសព្ទរបស់គាត់។[១៩]

---

[១៨] https://bit.ly/3RulMva

[១៩] https://bit.ly/3H4cwZT

## ១៩. អាជ្ញាបណ្ណគេហទំព័រត្រូវបានដកហូតបន្ទាប់ពី ការបំពានក្រមសីលធម៌យ៉ាងធ្ងន់ធ្ងរ

*ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ភ្នំពេញ*

ក្រសួងព័ត៌មាន បានដកហូតអាជ្ញាបណ្ណរបស់គេហទំព័រព័ត៌មាន Khmer Cover TV (KCTV) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ បន្ទាប់ពីរកឃើញថា អង្គភាពសារព័ត៌មានបានប្រព្រឹត្តកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ។

យោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងព័ត៌មានចុះហត្ថលេខាដោយរដ្ឋមន្ត្រី អង្គភាពសារព័ត៌មាន KCTV បានប្រព្រឹត្តកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ ហើយបានបដិសេធពីរដងមិនអនុវត្តតាមការណែនាំរបស់ក្រសួងដែលផ្ទុយនឹងកិច្ចសន្យាអាជីវកម្ម ដែលសាមីខ្លួនបានតម្កល់ទុកនៅក្រសួងព័ត៌មាន។ ទោះជាយ៉ាងណាសេចក្តីថ្លែងការណ៍មិនបានលើកឡើងពីករណីជាក់លាក់ណាមួយអំពីការប្រព្រឹត្តកំហុសខាងក្រមសីលធម៌នោះឡើយ។

អង្គភាពព័ត៌មានអនឡាញនេះ គឺស្ថិតក្នុងចំណោមអង្គភាពសារព័ត៌មានបី ដែលត្រូវក្រសួងព័ត៌មានធ្លាប់លុបចោលអាជ្ញាបណ្ណកាលពីនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ដោយសារការផ្សាយព័ត៌មានដែលបំពានក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្ម។ ក្រសួងបានកែសម្រួលសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ដែលអនុញ្ញាតឱ្យអង្គភាពសារព័ត៌មានទាំងបីអាចដំណើរការឡើងវិញបាន។

កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ អង្គភាពសារព័ត៌មាន KCTV បានចុះផ្សាយអត្ថបទ និងវីដេអូឃ្លីបមួយ ដែលបង្ហាញពីកម្មករក្រុមហ៊ុន ឡេង ណាវ៉ាត្រា គ្រុប បូមខ្សាច់ចាក់លុបបឹង ដើម្បីសាងសង់ផ្លូវបេតុង ចូលទៅកាន់គម្រោងអភិវឌ្ឍន៍របស់ឧកញ៉ា នៅស្រុកល្វាឯម ខេត្តកណ្តាល។ ការបូមខ្សាច់ចាក់លុបតំបន់ដីសើមនៅជុំវិញរាជធានីភ្នំពេញបានរងការរិះគន់ជាយូរមកថា បានបង្កឱ្យមានទឹកជំនន់កាន់តែអាក្រក់ទៅៗនៅក្នុងរាជធានី។

ក្រុមហ៊ុនហ្គាឡាក់ស៊ីរបស់លោកណាវ៉ាត្រាបានផ្ញើលិខិតទាមទារឱ្យ អង្គភាពសារព័ត៌មាន KCTV ដកឃ្លីបវីដេអូ និងអត្ថបទចេញ ហើយអះអាងថា អង្គភាពសារព័ត៌មានបានបរិហារកេរ្តិ៍។[២០]

KCTV បានបដិសេធមិនដកអត្ថបទព័ត៌មាន និងវីដេអូចេញពីទំព័រហ្វេសប៊ុករបស់ខ្លួនទេ។ ចាងហ្វាងបានប្រាប់ខេមបូចាថា អត្ថបទ និងវីដេអូនេះជារឿងពិត ហើយ KCTV មានសិទ្ធិផ្សាយព័ត៌មាន។ លោកនិយាយថា លោកមិនបានជំរិតទារប្រាក់ ឬបង្ខូចឈ្មោះលោក ឡេង ណាវ៉ាត្រាទេ។៕

---

២០ http://tinyurl.com/nhkyudu3

**ខ. ការយាយីផ្នែកឌីជីថល**

*នៅមុនការបោះឆ្នោតជាតិឆ្នាំ២០២៣ ក៏ដូចជារយៈពេលប៉ុន្មានខែមុនការបោះឆ្នោតជាតិឆ្នាំ២០១៨ ដែរ ការបិទ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអនឡាញមានការកើនឡើង។ ការចាប់ពិរុទ្ធមុនការបោះឆ្នោតនេះធ្វើឱ្យខូចលទ្ធិប្រជាធិបតេយ្យដែលទើបលូតលាស់របស់កម្ពុជា។*

*អតីតអ្នកសារព័ត៌មាន VOD ម្នាក់ ដែលជាស្ត្រី និងបានសរសេរអត្ថបទមួយដែលធ្វើឱ្យលោក ហ៊ុន ម៉ាណែត និងលោក ហ៊ុន សែន ផុះកំហឹងនោះចាប់ផ្តើមប្រឈមនឹងការប្រមាថបែបរើសអើង និងការបៀតបៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ខណៈប្រធានក្រុមអ្នកឆ្លើយឆ្លងព័ត៌មាន ឌឹ ខេមបូឌា ដេលី ទទួលរងការគំរាមសម្លាប់ពីលោក ផៃង វណ្ណៈ ជាអ្នកអត្ថាធិប្បាយព័ត៌មានតាមបណ្តាញសង្គមដែលគាំទ្ររដ្ឋាភិបាល។*

## ១. រដ្ឋាភិបាលបង្កើនការពិនិត្យខ្ទឹមសារលើគេហទំព័រព័ត៌មានរិះគន់ មុនការបោះឆ្នោតជាតិមកដល់

*ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ រាជធានីភ្នំពេញ*

ក្រសួងព័ត៌មានបាន បញ្ជាឱ្យ និយតករទូរគមនាគមន៍កម្ពុជា (TRC) បិទគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យចំនួនពីរ និងគេហទំព័រ ទិន្នន័យសាធារណៈ មុនពេលបោះឆ្នោតជាតិក្នុងខែកក្កដា។

បទបញ្ជានេះ បញ្ជាក់ថា ការពិនិត្យចាប់កំហុសគឺដោយសារតែការផ្សាយព័ត៌មានដែលរិះគន់រដ្ឋាភិបាល ដោយអះអាងថា ប្រព័ន្ធផ្សព្វផ្សាយ និងទិន្នន័យផ្សព្វផ្សាយព័ត៌មានដែល «ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកិត្យានុភាពរបស់រដ្ឋាភិបាល»។

ការបិទគេហទំព័រទាំងនេះបានរឹតត្បិតការចូលប្រើគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមដែលពាក់ព័ន្ធជាមួយ ខេមបូឌា ដេលី និងវិទ្យុអាស៊ីសេរី និងគេហទំព័រកំណត់ត្រា ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ដែលមាន ប្រតិបត្តិការជាមួយVOD មុនពេលបិទ។[២២]

## ២. អ្នកឆ្លើយឆ្លងព័ត៌មាន ខេមបូឌា ដេលី រងការគំរាមសម្លាប់ បន្ទាប់ពីរិះគន់អតីតនាយករដ្ឋមន្ត្រី លោក ហ៊ុន សែន

*កាលពីថ្ងៃទី១៩ ខែមិថុនា ភ្នំពេញ*

កាលពីថ្ងៃទី១៩ ខែមិថុនា ប្រធានផ្នែកប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរ ឌឹ ខេមបូឌា ដេលីបានអះអាងថា លោកបានទទួលការគំរាមសម្លាប់ពីលោក ផៃង វណ្ណៈ ដែលជាអ្នកលេងបណ្តាញសង្គមគាំទ្ររដ្ឋាភិបាល បន្ទាប់ពីលោករិះគន់អតីតនាយករដ្ឋមន្ត្រីលោកហ៊ុន សែន និងក្រុមគ្រួសារ ក្នុងកម្មវិធីពិភាក្សាគំនិតព័ត៌មាន។

---

[២២] http://tinyurl.com/c6tsdnc5

លោកបានបង្ហោះចែករំលែកសារសំឡេងពីលោក វណ្ណៈថា គាត់នឹងកាប់ក្បាលលោកនឹងពូថៅ ប្រសិនបើលោកចូលស្រុកខ្មែរ។ អ្នកសារព័ត៌មាន ដែលរស់នៅក្រៅប្រទេសក៏បានចោទប្រកាន់លោក វណ្ណៈថាបានគំរាមកំហែងគ្រួសាររបស់គាត់ រួមទាំងឪពុកម្តាយរបស់គាត់ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ហើយលោកបញ្ជាក់ថាភ្នាក់ងារគណបក្សប្រជាជនកម្ពុជានៅសហអាម៉េរិកអាចនឹងធ្វើបាបរូបលោកបាន។

លោក បាននិយាយថា បន្ទាប់ពីខ្ញុំបានទទួលការគំរាមកំហែងទាំងនេះ កាលពីថ្ងៃពុធនៅម៉ោងប្រហែល១រសៀល មានមនុស្សចម្លែកម្នាក់បានមកគោះទ្វាររបស់យើងខ្លាំងៗ ប៉ុន្តែយើងមិនហ៊ានបើកទេ។ លោកបាននិយាយថា ឪពុកម្តាយក្មេករបស់ខ្ញុំ និងកូនប្រុសអាយុប្រាំបីឆ្នាំរបស់ខ្ញុំភ័យខ្លាចខ្លាំងណាស់។ នៅម៉ោង៤រសៀលថ្ងៃដដែល ខ្ញុំបានឃើញរថយន្តពណ៌ខ្មៅចម្លែកមួយដែលមើលទៅដូចជារថយន្តស៊ើបការណ៍បានឈប់ ហើយចតនៅមុខផ្ទះខ្ញុំ ហើយមានមនុស្សអង្គុយនៅក្នុងរថយន្តអស់ជាច្រើនម៉ោង។[២៣]

កាលពីថ្ងៃទី ២២ ខែមិថុនា នៅក្នុងការផ្សាយផ្ទាល់តាមហ្វេសប៊ុកមួយទៀត លោក ផែង វណ្ណៈបាននិយាយថា លោកនឹងមិនស្ទាក់ស្ទើរក្នុងការបំផ្លាញអ្នកណាដែលបំផ្លាញសន្តិភាព និងស្ថិរភាពនៅកម្ពុជានោះទេ។[២៤]

## ៣. អតីតនាយករដ្ឋមន្ត្រីលោកហ៊ុន សែន វាយប្រហារអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី

### ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣ ភ្នំពេញ

នៅថ្ងៃទី៤ ខែមិថុនា អតីតនាយករដ្ឋមន្ត្រី លោកហ៊ុន សែន បានរិះគន់វិទ្យុអាស៊ីសេរី ខ្មែរ (RFA) ដោយហៅអ្នកយកព័ត៌មានម្នាក់ថាជាមនុស្សភ្លើ។ លោកហ៊ុន សែនព្រមានថា បើវិទ្យុអាស៊ីសេរីខ្មែរ ចង់បើកការិយាល័យនៅភ្នំពេញឡើងវិញ ចាំបាច់ត្រូវដកអ្នកយកព័ត៌មានដែលលោកហៅថាមនុស្សភ្លើចេញ។

លោកហ៊ុន សែន បាននិយាយក្នុងពេលជួបជាមួយកម្មកររោងចក្រស្បែកជើង រ៉ឹង ស្តារ នៅក្នុងខេត្តកំពង់ស្ពឺ។

ទោះបីជាអតីតនាយករដ្ឋមន្ត្រីមិនបាននិយាយចំឈ្មោះអ្នកយកព័ត៌មានក៏ដោយ ក៏លោកទំនងជាសំដៅទៅលើអ្នកគ្រប់គ្រងវិទ្យុអាស៊ីសេរីខ្មែរដែរ។

កាលពីឆ្នាំ២០១៧ វិទ្យុអាស៊ីសេរីខ្មែរបានបិទការិយាល័យរបស់ខ្លួននៅភ្នំពេញ បន្ទាប់ពីបុគ្គលិករបស់ខ្លួនពីរនាក់ត្រូវបានចាប់ខ្លួនពីបទចារកម្ម។ នៅពេលនោះ វិទ្យុអាស៊ីសេរីបានលើកឡើងថា មិនអាចបន្តប្រតិបត្តិការនៅកម្ពុជាបានទេ។

អ្នកគ្រប់គ្រងវិទ្យុអាស៊ីសេរីខ្មែររូបនេះគឺធ្វើការពីការិយាល័យដែលមានទីតាំងនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី។[២៥]

---

២៣ http://tinyurl.com/bdeybb5u

២៤ http://tinyurl.com/36hmurzj

២៥ https://pressocm.gov.kh/archives/82631 and http://tinyurl.com/bdcw96h3

### ៨.អតីតអ្នកសារព័ត៌មាន វីអូឌី រងការយាយីពីរដ្ឋមន្ត្រីក្រសួងព័ត៌មានទាក់ទងការរាយការណ៍ព័ត៌មានកីឡាស៊ីហ្គេម

*ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៣ ភ្នំពេញ*

លោករដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជា លោកខៀវ កាញារីទ្ធ បានប្រតិកម្មតបទៅនឹងការរាយការណ៍ព័ត៌មានរបស់សារព័ត៌មាន Nikkei Asia ស្តីពីការប្រកួតកីឡាស៊ីហ្គេម ដោយអះអាងថា វាមិនមែនជាការពិតនោះទេ។

អត្ថបទព័ត៌មានដែលមានចំណងជើងថា ស៊ីហ្គេមនៅកម្ពុជា៖ កម្មករ និងអត្តពលិក ហៅការកសាងពហុកីឡដ្ឋានមានភាពរញ៉េរញ៉ៃ" បានផ្សាយកាលពីថ្ងៃទី ៤ ខែឧសភា។ វាបានពិពណ៌នាអំពីបញ្ហាប្រឈមដែលកម្ពុជាកំពុងធ្វើជាម្ចាស់ផ្ទះស៊ីហ្គេម រួមមានការកកស្ទះចរាចរណ៍ ជីវភាពក្រីក្រតោកយ៉ាករបស់កម្មករ និងកង្វះការរៀបចំសម្រាប់ព្រឹត្តិការណ៍មួយចំនួន។

នៅក្នុងការបង្ហោះតាម បណ្តាញហ្វេសប៊ុក កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៣ លោក កាញារីទ្ធ បានហៅការរាយកាណ៍ព័ត៌មាននេះថា «បន្ទាបបន្ថោក» ហើយបានចោទប្រកាន់អ្នកសរសេរអត្ថបទ ថាជាអ្នកសារព័ត៌មានថោកទាប ដែលបម្រើផលប្រយោជន៍បរទេស។[៦៦]

លោក ខៀវ កាញារីទ្ធ បានសរសេរថា "យើងទទួលស្គាល់ថា កម្ពុជាមិនមែនជាស្ថានសួគ៌ទេ តែការប្រឹងប្រែង របស់ប្រទេសកម្ពុជាទាំងមូល បានត្រឹមចេញជារូបថត ៣ សន្លឹក និងអត្ថបទបន្ទាបបន្ថោកគ្រប់បែបយ៉ាងពីអ្នកសារព័ត៌មានរូបនេះ និងបក្សពួក នៅលើទំព័រកាសែតអន្តរជាតិមួយទៅវិញ" ។

អ្នកសារព័ត៌មានរូបនេះធ្លាប់ធ្វើជាអ្នកសារព័ត៌មានអោយវីអូឌី ភ្នំពេញបុស្តិ៍ និងឌឹខេមបូឌាដេលី។

ស៊ីហ្គេមជាព្រឹត្តិការណ៍កីឡាដ៏សំខាន់មួយដែលប្រារព្ធឡើងរៀងរាល់ពីរឆ្នាំម្តងក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស៊ីហ្គេមឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១៦ ខែឧសភា។[៦៧]

## ៩. ក្រោយការបិទវីអូឌី មានការបង្កជម្លោះរករឿងចំពោះអ្នកសារព័ត៌មាន

*ថ្ងៃទី១១ កុម្ភៈ ឆ្នាំ ២០២៣ ភ្នំពេញ*

បន្ទាប់ពីការបិទវីអូឌី ដែលបញ្ជាដោយរដ្ឋាភិបាល អង្គភាពសារព័ត៌មាននេះក៏ក្លាយជាកម្មវត្ថុនៃរូបភាពវាយប្រហារមិនសមរម្យតាមប្រព័ន្ធបណ្តាញសង្គម ហើយអ្នកយកព័ត៌មានរបស់អង្គភាពនេះប្រឈមនឹងការវាយប្រហារផ្ទាល់ខ្លួនតាមអ៊ីនធឺណិត និងតាមប្រព័ន្ធផ្សព្វផ្សាយដែលគាំទ្ររដ្ឋាភិបាល។

ស្ត្រីអ្នកយកព័ត៌មានវីអូឌី ដែលសរសេរអត្ថបទនោះធ្វើឱ្យលោក ហ៊ុន ម៉ាណែត និង ហ៊ុន សែន ខឹងសម្បារ ហើយក៏ចាប់ផ្តើម

---

[៦៦] រូបscreenshot ពីហ្វេសបុករដ្ឋមន្ត្រីក្រសួងព័ត៌មាន

[៦៧] http://tinyurl.com/29ht7524

រងនូវការជេរប្រមាថឥតសំចៃ និងការបៀតបៀនផ្លូវភេទតាមបណ្ដាញសង្គមផងដែរ។

លោក ផែង វណ្ណៈ អ្នកលេងហ្វេសប៊ុកគាំទ្ររដ្ឋាភិបាលមួយរូប និងជាអតីតមន្ត្រីយោធាបានសរសេរជាភាសាខ្មែរនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនថា "ជាក្មេងស្រី តែចរិកព្រៃផ្សៃ ចរិកថោកទាប ដូចនាងអាណាយកធ្វើប្រពន្ធងាប់ហើយ"។

បុគ្គលិកវីអូឌី ផ្សេងទៀតក៏បានរងការវាយប្រហារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងតាមអង្គភាពព័ត៌មានដែលគាំទ្ររដ្ឋាភិបាលផងដែរ។

នៅថ្ងៃដែលអាជ្ញាបណ្ណរបស់វីអូឌី ត្រូវបានលុបចោលនៅថ្ងៃទី១៣ ខែកុម្ភៈ មានអ្នកប្រើប្រាស់ធ្វីតទ័រ ជាច្រើននាក់ ដែលហាក់ដូចជាគណនីក្លែងក្លាយបានចាប់ផ្ដើមបង្ហោះរូបថ្លុក និងសារដែលសរសេរដូចគ្នាបេះបិទ ហើយអបអរសាទរការបិទវីអូឌីជាមួយនឹង hashtag #VODshithead ។

គណនីធ្វីតទ័រ បានចែករំលែករូបថ្លុកដែលចាត់ទុកវីអូឌី ជាឧបករណ៍របស់ភ្នាក់ងារបរទេសដូចជា "ស្ថានទូតបរទេស" និងអង្គការក្រៅរដ្ឋាភិបាល"។

ការវាយប្រហារមកលើអ្នកយកព័ត៌មានវីអូឌី បានធ្វើឡើងដោយអង្គភាពព័ត៌មានដែលគាំទ្ររដ្ឋាភិបាល។

បន្ទាប់ពីមានការចុះផ្សាយរបស់សារព័ត៌មាន BBC ទាក់ទងនឹងអ្នកយកព័ត៌មានវីអូឌីមួយរូប ដែលមានចំណងជើងថា «កម្ពុជា៖ បន្ទប់ព័ត៌មានដែលខ្ញុំធ្វើការត្រូវបំបិទសំឡេង»នោះ កាសែតភ្នំពេញប៉ុស្ដិ៍ ដែលលោកធ្លាប់ធ្វើការជាបុគ្គលិកបានព្យាយាមវាយប្រហារលោក តាមរយៈធ្វើឱ្យបាត់បង់ទំនុកចិត្តមកលើលោក ដោយព្យាយាមបង្ហាញថាលោក មានបញ្ហាខាងផ្លូវចិត្ត។

នៅក្នុងបទវិចារណកថាចុះនៅថ្ងៃទី១៧ ខែកុម្ភៈដែលមានចំណងជើងថា ប៉ុស្តិ៍ "ត្រូវបិទ" និង "បំបិទសំឡេង"? កាសែតភ្នំពេញប៉ុស្ដិ៍បានជំទាស់នឹងសំដីរបស់អ្នកសារព័ត៌មានរូបនោះថា ខ្លួនបាន" ចាកចេញដោយសារតែកាសែតនេះបានផ្លាស់ប្តូរម្ចាស់ទៅជាក្រុមហ៊ុន PR ដែលមានទំនាក់ទំនងជិតស្និទ្ធនឹងរដ្ឋាភិបាលក្នុងឆ្នាំ២០១៨ ។

ប៉ុន្តែវិចារណកថាដែលគ្មានឈ្មោះអ្នកសរសេរនោះក៏បានបញ្ចូលផ្នែកមួយ ដែលនិយាយពី "អំពីបុគលិកលក្ខណៈ របស់លោក" ដែលចាត់ទុកលោកថា "មនុស្សកំសាក" "ប៉ះទង្គិចផ្នែកផ្លូវចិត្ត" ហើយមាន "គុណវិបត្តិបុគ្គលិកលក្ខណៈ។

អ្នកសារព័ត៌មាន និងក្រុមការងារផ្សេងៗបាននិយាយការពារលោក បន្ទាប់ពីអត្ថបទត្រូវបានផ្សាយ ហើយមានទាំងការរិះគន់អតីតក្រុមការងារបែបនេះ។[២៨]

---

[២៨] http://tinyurl.com/43s3rxej

### គ. ការយាយីលើរាងកាយ

នៅឆ្នាំនេះ យើងបានកត់ត្រាករណីហិង្សាលើរាងកាយចំនួនបីករណី។ ចំពោះករណីដ៏តក់ស្លុតបំផុតនោះ គឺអ្នកសារព័ត៌មានម្នាក់ ត្រូវបានក្រុមឈ្មួញរកស៊ីឈើនៅខេត្តកំពង់ចាមវាយធ្វើបាប និងចងដៃចងជើង។ ករណីនេះបង្ហាញពីគ្រោះថ្នាក់ធ្ងន់ធ្ងរដែលអ្នកសារព័ត៌មានប្រឈមនៅពេលធ្វើសេចក្តីរាយការណ៍ព័ត៌មាននៅកម្ពុជា។

## ១. អ្នកសារព័ត៌មានអនឡាញម្នាក់ត្រូវបានចាប់ចង បន្ទាប់ពីរាយការណ៍ព័ត៌មានអំពីការដឹកឈើ

### ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៣ ខេត្តកំពង់ចាម

កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៣ ជាអ្នកសារព័ត៌មានអនឡាញមកពីសារព័ត៌មាន សាន ព្រហ្ម ត្រូវបានចាប់ចងដៃ ជើងនឹងខ្សែ ដោយមនុស្សមួយក្រុមនៅខេត្តកំពង់ចាម ហើយក្រោយមកគាត់ត្រូវបានបញ្ជូនទៅអធិការស្រុកជើងព្រៃដើម្បីសួរចម្លើយ និងបញ្ជូនទៅតុលាការខេត្តដើម្បីសាកសួរបន្ត។

ក្នុងវីដេអូដែលបានបង្ហោះលើហ្វេសប៊ុក អ្នកសារព័ត៌មានអនឡាញរូបនោះ ត្រូវបានគេឃើញដេកលើដីដោយគ្មានអាវ ខណៈដៃ និងជើងគាត់ត្រូវបានចងភ្ជាប់នឹងខ្សែ។ លោកត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុក និងតុលាការដំបូងខេត្តកំពង់ចាម ដើម្បីសាកសួរ។ លោកត្រូវដោះលែងវិញបន្ទាប់ពីលោកយល់ព្រមសម្របសម្រួលជាមួយក្រុមមនុស្សដែលចាប់លោកចង។

មុនពេលរងនូវហិង្សានេះ លោកបានផ្សាយផ្ទាល់វីដេអូតាមបណ្តាញសង្គមនិយាយអំពីការដឹកជញ្ជូនឈើនៅតាមផ្លូវ។

បើយោងតាមរដ្ឋបាលខេត្តកំពង់ចាម លោកត្រូវបានមនុស្សចំនួន៤នាក់ ចាប់ខ្លួននៅភូមិប៉ាណា ឃុំសូទិប ស្រុកជើងព្រៃ បន្ទាប់ពីលោកបានចូលទៅក្នុងទីតាំងឯកជនមួយ ដើម្បីថតរូបឈើ ដោយគ្មានការអនុញ្ញាត។

លោកជាអតីតអ្នកយកព័ត៌មានឱ្យទូរទស្សន៍អនឡាញ CNM ប៉ុន្តែលោកបានប្តូរទៅធ្វើជាអ្នកសារព័ត៌មានឱ្យអង្គភាពសារព័ត៌មាន សាន ព្រហ្មវិញ។ ទោះយ៉ាងណានេះក្តី CNM TV បានបញ្ជាក់ក្នុងលិខិតមួយថ្ងៃក្រោយថ្ងៃកើតហេតុថាលោកត្រូវបានបណ្តេញចេញពី CNM TV។

តាមរដ្ឋបាលខេត្ត អ្នកសារព័ត៌មានរូបនេះ នៅមិនទាន់បានចុះឈ្មោះជាអ្នកសារព័ត៌មានឱ្យអង្គភាពណាមួយនៅឡើយទេ។

ចាងហ្វាងសារព័ត៌មានសាន ព្រហ្ម បានប្រាប់ខេមបូចាថា អ្នកសារព័ត៌មានរូបនេះ ក៏ត្រូវបានបណ្តេញចេញពីអង្គភាពតាំងពីមុនពេលកើតហេតុម្ល៉េះ ប៉ុន្តែអ្នកសារព័ត៌មានដែលរងគ្រោះនេះបានអះអាង វាកើតឡើងក្រោយពេលកើតហេតុ។ លោកថែមទាំងបង្ហាញកាតអ្នកសារព័ត៌មានចេញដោយអង្គភាពសារព័ត៌មានសាន ព្រហ្ម[២៩] ដែលមានសុពលភាពដល់ខែមិថុនា ឆ្នាំ២០២៤។

លោក និយាយថា បច្ចុប្បន្នលោកកំពុងបម្រើការឱ្យអង្គភាពសារព័ត៌មានអនឡាញថ្មីមួយឈ្មោះ ICD TV ហើយកំពុងតែសុំកាតអ្នកសារព័ត៌មានក្រសួងសារព័ត៌មាន។

---

[២៩] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

## ២. អ្នកសារព័ត៌មានអនឡាញ រងការយាយីផ្នែករាងកាយដោយម្ចាស់អាជីវកម្មបូមខ្សាច់

*ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២៣ ខេត្តកណ្តាល*

និពន្ធនាយកសារព័ត៌មាន BTN និយាយថា លោកត្រូវបានម្ចាស់អាជីវកម្មបូមខ្សាច់លោក ឡាយ រ៉ា បានកញ្ឆក់យកបណ្ណសារព័ត៌មានរបស់លោក ខណៈពេលដែលលោកកំពុងរាយការណ៍ព័ត៌មានពីផលប៉ះពាល់នៃការបូមខ្សាច់លុបវាលស្រែ កាលពីថ្ងៃទី ២៦ ខែមករា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

លោកនិយាយថា លោកក៏ត្រូវគេរុញឱ្យធ្លាក់ប្រឡាយទឹក បណ្តាលឱ្យខូចទូរស័ព្ទដៃ។

លោកប្រាប់ខេមបូចាថា ករណីនេះត្រូវបានដោះស្រាយរួចបន្ទាប់ពីលោកយល់ព្រមទទួលយកសំណងពីលោកឡាយ រ៉ា នៅប៉ុស្តិ៍នគរបាល។[៣០]

## ៣. អ្នកសារព័ត៌មានអនឡាញពីរនាក់ត្រូវបានអ្នកលេងល្បែងម្នាក់កញ្ឆក់យកទូរស័ព្ទ

*ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២៣ ភ្នំពេញ*

អ្នកយកព័ត៌មានអនឡាញ និងជាចាងហ្វាងសារព័ត៌មានរស្មីក្រុងតាខ្មៅ បាននិយាយថា លោកត្រូវបានជនមិនស្គាល់មុខជាអ្នកលេងល្បែងជល់មាន់ម្នាក់កញ្ឆក់យកទូរសព្ទដៃទៅបោកចោល កាលពីថ្ងៃទី២៣ ខែមករា ខណៈលោកកំពុងថតសង្វៀនជល់មាន់នៅភ្នំពេញ។

អ្នកយកព័ត៌មានម្នាក់ទៀតពីសារព័ត៌មានភ្នំពេញចិត្ត ដែលទៅទីនោះដែរ បានប្រាប់ ខេមបូចា ថា អ្នកជល់មាន់ក៏បានព្យាយាមកញ្ឆក់យកទូរសព្ទពីលោកដែរ ប៉ុន្តែកញ្ឆក់យកមិនបាន។

ក្រោយកើតហេតុភ្លាមៗអ្នកសារព័ត៌មានទាំងពីរក៏បានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលសង្កាត់ព្រែកប្រាផងដែរ ។[៣១]

---

[៣០] https://bit.ly/3Rgyj5r

[៣១] https://bit.ly/3DbdUZH

### ឃ. ការគំរាមកំហែង/ការរើសអើង

អ្នកសារព័ត៌មាន២២នាក់ រួមទាំងអ្នកសារព័ត៌មានស្ត្រីពីរនាក់ផងបានប្រឈមនឹងការរឹតត្បិត ឬការរើសអើង អំឡុងពេលបំពេញការងាររបស់ពួកគេ។ យ៉ាងហោចណាស់អ្នកសារព័ត៌មាន១០នាក់ ត្រូវបានរឹតត្បិត និងរាំងមិនអោយឱ្យចូលយកព័ត៌មានអំពីការបោះឆ្នោតជាតិ ក្នុង ខែកក្កដា ឆ្នាំ២០២៣។ អ្នកសារព័ត៌មានម្នាក់មកពីវិទ្យុ VOA ដែលគាំទ្រដោយសហរដ្ឋអាម៉េរិកត្រូវបានបណ្តេញចេញពីសន្និសីទកាសែតមួយនៅពេលដែលរដ្ឋសភាកម្ពុជាបោះឆ្នោតជ្រើសរើសលោក ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីបន្ទាប់របស់ប្រទេសកម្ពុជា។ អ្នកសារព័ត៌មានបីនាក់ត្រូវគេបង្ខំចិត្តឱ្យចាកចេញពីសហគមន៍ព្រៃឈើ ខណៈពេលពួកគេធ្វើសេចក្តីរាយការណ៍អំពីការកាប់បំផ្លាញព្រៃឈើនៅខេត្តព្រះវិហារ និងអ្នកសារព័ត៌មានបីនាក់ទៀតត្រូវបានអាជ្ញាធរខេត្តមណ្ឌលគិរីគំរាមកំហែង ខណៈធ្វើសេចក្តីរាយការណ៍ ពីសហគមន៍ជនជាតិដើមភាគតិច។

**តារាងទី២ ៖ តារាងចំនួនករណីយាយីតាមប្រភេទសារព័ត៌មាន**

| ប្រភេទស្ថាប័នសារព័ត៌មាន | ចំនួនស្ថាប័នសារព័ត៌មាន |
|---|---|
| កាសែត | ១ |
| សារព័ត៌មានអនឡាញ | ១៨ |
| គេហទំព័រ | ៣ |
| ទូរទស្សន៍ | ១ |
| វិទ្យុ | ២ |

## ១. អ្នកសារព័ត៌មានត្រូវបានហាមកុំឱ្យរាយការណ៍ព័ត៌មានពីបញ្ហាបរិស្ថានដែលប៉ះពាល់ដល់មុខមាត់អាជ្ញាធរ

*ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខេត្តស្ទឹងត្រែង*

កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ អ្នកយកព័ត៌មានទូរទស្សន៍ហង្សមាសប្រចាំខេត្តស្ទឹងត្រែង ត្រូវបានប្រធានមន្ទីរបរិស្ថានខេត្តប្រាប់កុំឱ្យរាយការណ៍ព័ត៌មានអំពីបញ្ហាបរិស្ថាន ដែលប៉ះពាល់ដល់មុខមាត់អាជ្ញាធរ។

រឿងនេះកើតឡើងបន្ទាប់ពីអ្នកសារព័ត៌មាន បានរាយការណ៍អំពីភាពបរាជ័យរបស់អាជ្ញាធរស្រុក ក្នុងការចាប់ខ្លួនអ្នកកាប់ឈើខុសច្បាប់នៅក្នុងស្រុក បុរីអូរស្វាយ សែនជ័យ។

លោកបានប្រាប់ខេមបូចាថា លោកបានផ្សាយព័ត៌មាននេះនៅលើកម្មវិធីទូរទស្សន៍ហង្សមាស ហើយបានយកមកបង្ហោះលើបណ្តាញសង្គមហ្វេស ប៊ុក ផ្ទាល់ខ្លួនថែមទៀត។ អាជ្ញាធរបានប្រាប់ឱ្យលោកលុបអត្ថបទចេញពីហ្វេសប៊ុករបស់គាត់ តែគាត់បានបដិសេធ។[៣២]

[៣២] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

## ២. អ្នកសារព័ត៌មានអនឡាញនៅខេត្តបាត់ដំបងរងការគំរាមកំហែងពីមន្ត្រីនគរបាលពេលចុះថតរូប

### ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ខេត្តបាត់ដំបង



រូបឡានដឹកលើសទម្ងន់កំពុងជាប់ផុងនៅទីរួមខេត្តបាត់ដំបងក្នុងខែតុលា ឆ្នាំ២០២៣/ រូបភាពផ្ដល់ឱ្យ

កាលពីយប់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ និពន្ធនាយករងរបស់សារព័ត៌មាន PCN ដែលជាប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញក្នុងខេត្តបាត់ដំបង ត្រូវបានបុរសម្នាក់ ដែលគេស្គាល់ថា ជាមន្ត្រីនគរបាលខេត្តបាត់ដំបងបានគំរាមកំហែងដោយពាក្យសំដី។

ហេតុការណ៍នេះបានកើតឡើង ខណៈ កំពុងថតរូប និងវីដេអូនៃរថយន្តដឹកទំនិញលើសទម្ងន់ ដែលបង្កការខូចខាតផ្លូវក្នុងខេត្ត។

លោកបាននិយាយថា នៅវេលាម៉ោងប្រហែល៩ និង ៣០នាទីយប់ មានឡានដឹកទំនិញមួយគ្រឿង ដែលផ្ទុកលើសទម្ងន់បានជាប់ផុង ដែលបណ្ដាលឱ្យខូចផ្លូវនៅក្នុងខេត្តបាត់ដំបង។ បានបន្តថានៅពេលដែលគាត់កំពុងថតរូបឡាន ដែលកំពុងជាប់ផុងម្ចាស់ឡានដឹកលើសទម្ងន់នោះ ដែលគេស្គាល់ថា អ្នកមន្ត្រីនគរបាលខេត្ត ហើយជាឈ្មួញទំនិញផងនោះ បានដើរចេញពីរថយន្តមួយផ្សេងទៀតមកសួរលោកថា «ឯងជានរណាបានមកថតរូបហ្នឹង?»

ទោះបីដឹងថាលោកជាអ្នកសារព័ត៌មានក៏ដោយ ក៏បុរសរូបនោះនៅតែសួរលោកថា «តើឯងមានការអនុញ្ញាតក្នុងការថតរូបដែរទេ?»

អ្នកសារព័ត៌មានរូបនេះ បានឆ្លើយថា លោកថតរូបនៅលើផ្លូវសាធារណៈ ដូច្នេះលោកមានសិទ្ធិក្នុងការថត។

លោកបាននិយាយថាក្រោយថតរូប និងវីដេអូហើយ លោកបានចាកចេញពីកន្លែងនោះ ហើយបានត្រឡប់ទៅផ្ទះវិញ។ ខណៈលោកកំពុងទទួលទានអាហារពេលល្ងាចជាមួយគ្រួសារនៅផ្ទះដែលមិនឆ្ងាយប៉ុន្មានពីកន្លែងកើតហេតុ មន្ត្រីនគរបាលបានតាមលោកមកដល់ផ្ទះ និងបានថតរូបលោកនៅមុខផ្ទះ ហើយមន្ត្រីនគរបាលរូបនោះបាននិយាយថា៖ «ឯងមានកូនច្រើនគ្រាន់បើ» រួចក៏ដើរចេញទៅ។ អ្នកសារព័ត៌មានរូបនេះយល់ថា សម្ដីរបស់មន្ត្រីរូបនោះគឺជាការគំរាមមកលើរូបលោក និងគ្រួសារ។

## ៣. នគរបាលមូលដ្ឋានបានសាកសួរអ្នករៀបចំវគ្គបណ្តុះបណ្តាលអំពីក្រមសីលធម៌អ្នកសារព័ត៌មាន

### ថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ ២០២៣ ខេត្តក្រចេះ

នគរបាលមូលដ្ឋាន ក្នុងខេត្តក្រចេះបានសាកសួរអ្នករៀបចំវគ្គបណ្តុះបណ្តាលស្តីពីក្រមសីលធម៌អ្នកសារព័ត៌មានរបស់ខេមបូចា។ មន្ត្រីនគរបាលពីរនាក់បានស្នើសុំមើលរបៀបវារៈនៃវគ្គបណ្តុះបណ្តាល ថតរូបវគ្គបណ្តុះបណ្តាល និងសុំបញ្ជីឈ្មោះអ្នកចូលរួម។ នគរបាលក៏បានសួររកឈ្មោះគ្រូឧទ្ទេស ចំនួនអ្នកចូលរួម ថាតើសិក្ខាកាមមកពីណា និងវគ្គបណ្តុះបណ្តាលមានគោលបំណងអ្វី។ នគរបាលបាននិយាយថា វាជានីតិវិធីធម្មតាក្នុងខេត្តដែលត្រូវដឹងពីការជួបជុំការប្រជុំនិងសិក្ខាសាលាទាំងអស់ដែលធ្វើឡើងដោយគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា។

ទោះយ៉ាងណាក្តី អ្នករៀបចំកម្មវិធីបានបដិសេធមិនផ្តល់បញ្ជីឈ្មោះអ្នកចូលរួមទេ ប៉ុន្តែបានយល់ព្រមផ្តល់ឱ្យនគរបាលនូវរបៀបវារៈនៃវគ្គបណ្តុះបណ្តាល និងរូបភាពនៃវគ្គបណ្តុះបណ្តាល។ មន្ត្រីនគរបាលម្នាក់ក្នុងសម្លៀកបំពាក់ស៊ីវិល ដែលកំពុងសរសេរកំណត់ត្រាបាននិយាយថា៖ «នេះជាបញ្ជាពីលោកស្នងការនគរបាលខេត្ត»។ នគរបាលបានចាកចេញពីកន្លែងវគ្គបណ្តុះបណ្តាលបន្ទាប់ពីសាកសួររួច។»

ទោះជាយ៉ាងនេះក្តី ដោយសាររបៀបវារៈមាននិយាយឈ្មោះតំណាងមកពីអង្គការយូណេស្កូ ទើបមន្ត្រីនគរបាលត្រឡប់មកវិញម្តងទៀត ដើម្បីសុំជួបតំណាងពីអង្គការយូណេស្កូ។ នគរបាលបានចាកចេញវិញ បន្ទាប់ពីមានការពន្យល់អំពីអវត្តមាននៃតំណាងអង្គការយូណេស្កូ។[៣៣]

## ៤. អ្នកយកព័ត៌មាន VOA ត្រូវគេដេញចេញពីសន្និសីទកាសែតនៅរដ្ឋសភា

### ថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២៣ ភ្នំពេញ

កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ រដ្ឋសភាកម្ពុជាបានធ្វើការ បោះឆ្នោតជ្រើសតាំងលោកហ៊ុន ម៉ាណែត កូនប្រុសរបស់លោកហ៊ុន សែន ដែលចេញពីតំណែង ឱ្យធ្វើជានាយករដ្ឋមន្ត្រីបន្ទាប់របស់ប្រទេសនេះ។

អ្នកយកព័ត៌មានរបស់វីអូអេ(VOA) បានស្ថិតនៅក្នុងបន្ទប់សន្និសីទកាសែត ក្នុងរដ្ឋសភា ដើម្បីចូលយកព័ត៌មាន និងរាយការណ៍ព័ត៌មានអំពីការបោះឆ្នោតជ្រើសតាំង។ លោកបានចូលទៅក្នុងកន្លែងធ្វើសន្និសីទ មុននឹងសន្និសីទកាសែតចាប់ផ្តើម។

នៅម៉ោងប្រហែលម៉ោង ៨:១០ព្រឹក អ្នកសារព័ត៌មានរូបនោះ បាននិយាយថា ក៏ស្រាប់តែមន្ត្រីរដ្ឋសភាបានបណ្តេញលោកចេញពីបន្ទប់សន្និសីទកាសែតនេះ។ ពួកគេមិនបានផ្តល់ហេតុផលទេ សូម្បីតែនៅពេលដែលលោកបានសួរពួកគេថាហេតុអ្វីបានជាពួកគេមិនអនុញ្ញាតឱ្យរូបលោកចូលរួមក្នុងសន្និសីទកាសែត។

លោកត្រូវបានអនុញ្ញាតឱ្យឈរនៅក្នុងបន្ទប់សារព័ត៌មាន ប៉ុន្តែគេមិនអនុញ្ញាតឱ្យលោកចូលទៅកាន់កន្លែងធ្វើសន្និសីទ ដែលកំពុងប្រព្រឹត្តទៅនោះទេ។

---

[៣៣] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

អ្នកយកព័ត៌មាន និងអ្នកថតវីដេអូផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យចូលរួមសន្និសីទ។ លោក ជាអ្នកយកព័ត៌មានតែម្នាក់គត់នៅទីនោះ ដែលមកពីវិទ្យុវីអូអេ (VOA) ដែលគាំទ្រដោយសហរដ្ឋអាម៉េរិក។ លោកគឺជាអ្នកយកព័ត៌មានតែម្នាក់គត់ដែលត្រូវបានបង្ខំឱ្យចាកចេញពីកន្លែងធ្វើសន្និសីទកាសែត។

អ្នកយកព័ត៌មានវីអូអេ និងវីអូឌី ពីមុនត្រូវបានបដិសេធមិនឱ្យចូលរួមក្នុងសន្និសីទកាសែត ដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែវិច្ឆិកា ឆ្នាំ២០២២ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា។

អ្នកនាំពាក្យក្រសួងព័ត៌មាន បាននិយាយថា អ្នកយកព័ត៌មានមកពីអង្គភាពព័ត៌មានទាំងពីរ គ្រាន់តែ«កាត់យកតែពីរបីចំណុចប៉ុណ្ណោះ» ពីសុន្ទរកថាក្នុងសន្និសីទ ដើម្បីផ្សព្វផ្សាយ។[៣៤]

## ៩. អ្នកសារព័ត៌មានត្រូវដាក់កំហិតក្នុងការយកព័ត៌មានក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០២៣

### ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ភ្នំពេញ

ក្នុងអំឡុងពេលបោះឆ្នោត អ្នកសារព័ត៌មានយ៉ាងហោចណាស់១០នាក់បានប្រឈមនឹងការរឹតត្បិតពេលចុះយកព័ត៌មាន។ មន្ត្រីការិយាល័យបោះឆ្នោតបាននិយាយតតាំងនឹងអ្នកសារព័ត៌មាន ជារឿយៗដោយរារាំងពួកគេមិនឱ្យថតរូប និងសម្ភាសនៅខាងក្នុងបរិវេណការិយាល័យបោះឆ្នោត។

អ្នកសារព័ត៌មានខ្លះត្រូវបានអនុញ្ញាតឱ្យបន្តធ្វើការ បន្ទាប់ពីមិនព្រមធ្វើតាម ប៉ុន្តែអ្នកសារព័ត៌មាន ភាគច្រើននៅតែត្រូវបានរារាំងមិនឱ្យចូលទៅក្នុងការិយាល័យបោះឆ្នោតទាំងស្រុង។ ក្នុងករណីខ្លះមន្ត្រីបោះឆ្នោតថែមទាំងថតរូបអ្នកសារព័ត៌មានដើម្បីធ្វើរបាយការណ៍ដែរ។

នៅម៉ោងប្រមាណ៩ព្រឹក ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ប្រធានគណបក្ស ហ្វ៊ុនស៊ិនប៉ិចបានយាងទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតវត្តវាលស្បូវ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ។ អ្នកថតរូប និងអ្នកថតវីដេអូមួយក្រុម ត្រូវបានហាមប្រាមមិនឱ្យចូលក្នុងបន្ទប់បោះឆ្នោត ដើម្បីថតរូបព្រះអង្គ ពេលព្រះអង្គទៅបោះឆ្នោតទេ ទោះបីជាពួកគេកាន់បណ្ណព័ត៌មានដែលចេញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ដោយ។

អ្នកផលិតករវីដេអូរបស់ខេមបូចាបាននិយាយថា នៅវេលាម៉ោង១១ និង ២៥ នាទីព្រឹក លោកក៏ឈរនៅការិយាល័យបោះឆ្នោតវាលស្បូវដែរ។ ពេលកំពុងថតវីដេអូ អង្គរក្សរបស់ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច ព្រះអង្គម្ចាស់ ចក្រាវុធ បានគំរាមយកទូរសព្ទរបស់លោកបោះចោលម្តងហើយម្តងទៀត ដោយចោទលោកថាបានចូលកៀក និងប៉ះព្រះកាយព្រះអង្គម្ចាស់ ខណៈកំពុងថតរូបព្រះអង្គ។

[៣៤] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

[៣៥] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

*លោកបានដកស្រង់សំដីគំរាមរបស់អង្គរក្សនោះថា៖ «ខ្ញុំនឹងបោកទូរសព្ទរបស់លោកចោល ប្រសិនបើលោកថតប៉ះព្រះអង្គ ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធម្ដងទៀត»។*

*ភ្លាមៗនោះ លោកក៏បានបដិសេធថាលោកមិនបានប៉ះព្រះអង្គទេ។ លោកបានឆ្លើយតបវិញថា"ទេ ខ្ញុំមិនបានប៉ះនរណាទេ"។[៣៥]*

## ៦. អ្នកយកព័ត៌មានត្រូវបានចោទសួរដោយមន្ត្រីរៀបចំការបោះឆ្នោត ពេលកំពុងសម្ភាសអនុប្រធានគណបក្សភ្លើងទាន

### *ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខេត្តកណ្ដាល*

*អ្នកសារព័ត៌មានបីនាក់របស់វីអូអេ និង ខេមបូចា ត្រូវបានប្រធានការិយាល័យបោះឆ្នោតមួយក្នុងខេត្តកណ្ដាលសាកសួរ ខណៈពួកគេកំពុងសម្ភាសអនុប្រធានគណបក្សភ្លើងទៀន លោក រ៉ុង ឈុន។*

*អ្នកយកព័ត៌មានស្ត្រីមកពីខេមបូចាបាននិយាយថានាង និងអ្នកយកព័ត៌មានពីរនាក់ទៀតរបស់វីអូអេ បានទៅយកព័ត៌មាននៅការិយាល័យបោះឆ្នោតនៅអនុវិទ្យាល័យតាឡូន ស្រុកស្អាង ខេត្តកណ្ដាល ដែលអនុប្រធានគណបក្សភ្លើងទៀនគឺលោករ៉ុង ឈុន បានទៅបោះឆ្នោត។*

*កញ្ញាបានបន្តថា ពេលកំពុងសម្ភាសស្រាប់តែនគរបាល បានមកសួរប្រធានការិយាល័យបោះឆ្នោតអំពីអ្នកសារព័ត៌មានដែលមានវត្តមាននៅការិយាល័យបោះឆ្នោត។*

*កញ្ញាបានបន្តថា បន្ទាប់មកប្រធានការិយាល័យបោះឆ្នោតបានដើរសំដៅមកអ្នកសារព័ត៌មាន ហើយសួរថាអ្នកសារព័ត៌មានមកពីណា? ក្រោយពីសាកសួររួចប្រធានការិយាល័យបោះឆ្នោតរូបនោះបានថតរូបនាង និងអ្នកសារព័ត៌មានផ្សេងទៀតមកធ្វើរបាយការណ៍។*

*អ្នកយកព័ត៌មានរបស់វីអូអេ បាននិយាយថា លោកក៏បានទៅការិយាល័យបោះឆ្នោតនៅអនុវិទ្យាល័យតាឡូនដែរ។ លោកថាអ្នកយកព័ត៌មានបានសុំការអនុញ្ញាតពីប្រធានការិយាល័យបោះឆ្នោត ដើម្បីថតរូប និងសម្ភាសក្នុងការិយាល័យបោះឆ្នោត។*

*លោកថា ពេលកំពុងសម្ភាស ប្រធានការិយាល័យបោះឆ្នោតក៏បានថតរូបអ្នកយកព័ត៌មានដែរ។[៣៦]*

---

*[៣៦] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ*

## ៧. អ្នកយកព័ត៌មានបីនាក់ពីខេមបូចាត្រូវបានអាជ្ញាធរសួរនាំ ពេលចុះយកព័ត៌មាននៅខេត្តមណ្ឌលគិរី

### ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ខេត្តមណ្ឌលគិរី

នៅម៉ោងប្រហែល១០ព្រឹក អាជ្ញាធរចម្រុះមកពីស្រុកកោះញែក ខេត្តមណ្ឌលគិរី បានសាកសួរអ្នកយកព័ត៌មានខេមបូចា ដែលចុះយកព័ត៌មានអំពីសម្បទានដីសង្គមកិច្ច ដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច។ អាជ្ញាធរគ្រោងកាត់ដីស្រុកកោះញែកចំនួន ៦.០០០ ហិកតានៅភូមិយោលលើ ដែលប៉ះពាល់ដល់ជនជាតិដើមភាគតិចរស់នៅទីនោះ។

អាជ្ញាធរបានសួរអ្នកសារព័ត៌មានថា «ហេតុអ្វីបានជាអ្នកមកទីនេះ? ហេតុអ្វីបានជាអ្នកមកទីនេះចំថ្ងៃដែលអាជ្ញាធរចុះមកដែរ? អ្នកណាប្រាប់? តើអ្នកមកពីស្ថាប័នណា?"

បុរសម្នាក់ត្រូវបានគេស្គាល់ថាជាមន្ត្រីសាលាស្រុកកោះញែកបានដើរសំដៅទៅរកអ្នកសារព័ត៌មាន ហើយបានស្រែកគំហកខ្លាំងៗថា "ម៉េចបានជាជនបរទេសមកនៅក្នុងព្រៃ?" ម៉េចមិនប្រាប់អាជ្ញាធរជាមុន? មន្ត្រីរូបនោះបានបន្តថា"បើមានបញ្ហាតើនរណាជាអ្នកទទួលខុសត្រូវ? "

បន្ទាប់មក អាជ្ញាធរបានថតរូបអ្នកយកព័ត៌មាន។ មន្ត្រីម្នាក់ទៀតបានមកសួរថា “ម៉េចបានជាអ្នក [អ្នកកាសែត] មកទីនេះដោយគ្មានការអញ្ជើញអ៊ីចឹង? ហើយអ្នកណាជាអ្នកផ្តល់ព័ត៌មាន?"

ជនជាតិដើមភាគតិចប្រារព្ធពិធីសាសនារបស់ពួកគេ ដើម្បីបួងសួងកុំឱ្យអាជ្ញាធរដកហូតដីព្រៃសហគមន៍របស់ពួកគេ ហើយអ្នកយកព័ត៌មានរបស់ខេមបូចា បានចុះមកយកព័ត៌មាននេះ។

អាជ្ញាធរបាននិយាយថា«កម្មវិធីនេះសម្រាប់សហគមន៍ និងក្រសួងទេហេតុអ្វីបានជាអ្នកសារព័ត៌មានមកដែរ?»។

អ្នកសារព័ត៌មានបានឆ្លើយថា «ពួកយើងសរសេររឿងនេះ ដោយមិនមានភាពចម្រូងចម្រាស់ទេ គ្រាន់តែនិយាយពីការពិតនៃអ្វីដែលបានកើតឡើងប៉ុណ្ណោះ យើងមកសរសេរបន្ត និងរាយការណ៍ព័ត៌មាន»។[៣៧]

---

[៣៧] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

## ៨. អ្នកថតរូបខេមបូចាវផ្ទុះការយាយីពីសំណាក់អាជ្ញាធរ ពេលកំពុងថតរូបការតវ៉ានៅព្រលានយន្តហោះថ្មី

*ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ ខេត្តកណ្ដាល*

កាលពីថ្ងៃទី ៨ ខែមិថុនា ប្រធានអ្នករូបថតខេមបូចាត្រូវបានអាជ្ញាធរសាកសួរ ហើយថតកាតសារព័ត៌មានរបស់គាត់ ខណៈកំពុងថតអ្នកភូមិតវ៉ារឿងចាក់ដីលុបប្រឡាយក្បែរផ្ទះរបស់ពួកគេក្នុងគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះតម្លៃ ១.៥ពាន់លានដុល្លារក្នុងខេត្តកណ្ដាល។

អ្នកភូមិប្រហែលសាមសិបនាក់មកពីឃុំកណ្ដោក ស្រុកកណ្ដាលស្ទឹង មានចម្ងាយប្រហែល ប្រាំគីឡូម៉ែត្រពីការដ្ឋានអភិវឌ្ឍន៍ព្រលានយន្តហោះ បាននាំគ្នាតវ៉ាប្រឆាំងនឹងការចាក់ដីលុបប្រឡាយក្បែរផ្ទះរបស់ពួកគាត់។ មន្ត្រីអាជ្ញាធរមូលដ្ឋាន និងប៉ូលិសរាប់សិបនាក់ បានដាក់ពង្រាយនៅកន្លែងតវ៉ា។

អ្នកសារព័ត៌មានរូបនោះបាននិយាយថា ខណៈពេលដែលលោកកំពុងថតរូបអ្នកភូមិតវ៉ានោះ មានបុរសម្នាក់ស្លៀកពាក់ស៊ីវិលបានដើរតម្រង់មករកលោក ហើយបានថតរូបលោក និងកាតសារព័ត៌មាន។ ភ្លាមនោះ បុរសនោះក៏បានចាកចេញទៅ ប៉ុន្តែក្រោយមកបានត្រឡប់មកវិញ ហើយបានសុំលោកសំរាំងទៅជួបថ្នាក់លើរបស់ខ្លួន។ លោកសំរាំងបានបដិសេធ ហើយបានចាកចេញពីទីនោះភ្លាមៗដែរ បន្ទាប់ពីអ្នកភូមិប្រាប់លោកឱ្យចាកចេញ ដើម្បីជៀសវាងការចាប់ខ្លួន។

## ៩. អ្នកសារព័ត៌មានបីនាក់បង្ខំចិត្តចាកចេញពីសហគមន៍ព្រៃឈើ ខណៈរាយការណ៍ព័ត៌មានអំពីការកាប់បំផ្លាញព្រៃឈើ

### ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ខេត្តព្រះវិហារ

កាលពីថ្ងៃទី ២១ ខែមេសា អ្នកយកព័ត៌មានបរទេសម្នាក់ មកពីអង្គភាពសារព័ត៌មានម៉ុងហ្គាបៃ និងអ្នកសារព័ត៌មានសេរីពីររូបគឺ សញ្ជាតិអង់គ្លេស និងកម្ពុជា ត្រូវបានមន្ត្រីឧទ្យានុរក្សក្រសួងបរិស្ថានបង្ខំឱ្យចាកចេញពីសហគមន៍ព្រៃឈើព្រះរកាក្នុងខេត្តព្រះវិហារ ខណៈកំពុងរាយការណ៍ព័ត៌មានអំពីការកាប់បំផ្លាញព្រៃឈើ។

អ្នកសារព័ត៌មានទាំងបីនាក់ត្រូវបានគេបណ្ដេញចេញពីព្រៃ និងដោះលែងដោយមិនឃុំខ្លួនទេ។ សារព័ត៌មានមកពីម៉ុងហ្គាបៃបាននិយាយថា "គេប្រាប់យើងថាមិនឱ្យយើងនៅក្នុងព្រៃទេ ព្រោះយើងមិនបានសុំការអនុញ្ញាតពីអាជ្ញាធរ" ។

លោក បានទៅថតវីដេអូការដើរល្បាតព្រៃរបស់សហគមន៍ដែលជាផ្នែកនៃវីដេអូ តាមដានការបំផ្លាញព្រៃឈើ "Chasing Deforestation" របស់ អង្គភាពសារព័ត៌មាន Mongabay ។ លោកជ្រើសរើសសហគមន៍ព្រះរកា ព្រោះវាជាព្រៃដែលមានសុវត្ថិភាពជាងកន្លែងដទៃ ដើម្បីចុះល្បាតកាត់តាមដែនជម្រកសត្វព្រៃព្រៃឡង់ ដែលនៅក្បែរគ្នានោះ។

លោកបាននិយាយថា លោកបានជូនដំណឹងដល់អង្គការសិទ្ធិមនុស្សលីកាដូ អំពីបេសកកម្មរបស់លោកជាមុន។ លោកប្រាប់ខេមបូចាថាអង្គការលីកាដូបាននិយាយជាមួយបណ្ដាញអង្គការសង្គមស៊ីវិល។

ការណ៍នេះនាំឱ្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជានិយាយដោយផ្ទាល់ជាមួយរដ្ឋបាលខេត្តព្រះវិហារ។ រដ្ឋបាលខេត្តបានយល់ព្រមមិនឃុំខ្លួនអ្នកកាសែតទាំងបីនាក់នោះទេ។

លោកបាននិយាយថា៖ «ប្រសិនបើយើងមិនបានជូនដំណឹងដល់អង្គការក្រៅរដ្ឋាភិបាលទេ យើងប្រហែលជាត្រូវប្រឈមមុខនឹងប៉ូលិស ឬតុលាការហើយ»។[៣៨]

[៣៨] ខេមបូចាសម្ភាសជាមួយអ្នកសារព័ត៌មានរងគ្រោះ

# V. ករណីសិក្សា

## ការបិទវីអូឌី ជាការព្រមានដល់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា




អ្នកសារព័ត៌មានកំពុងថតប៉ូលីសនៅមុខការិយាល័យវីអូឌីនៅថ្ងៃស្ថាប័នព័ត៌មានត្រូវបានបិទនៅថ្ងៃ១៣ ខែកុម្ភះ ឆ្នាំ២០២៣
រូបថតដោយលោក ព្រីង សំរាង/ខេមបូចា

កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ រដ្ឋាភិបាលបានសម្រេចបិទវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) បន្ទាប់ពីអតីតនាយករដ្ឋមន្ត្រី លោកហ៊ុន សែន នាពេលនោះទាមទារឱ្យមានការសុំទោស និងដកចេញនូវអត្ថបទដែលសរសេរថាកូនប្រុសរបស់លោក គឺលោក ហ៊ុន ម៉ាណែត បានចុះហត្ថលេខាលើជំនួយទៅប្រទេសតួកគី។

ចំណាត់ការបែបនេះបានបំបិទសំឡេងពលរដ្ឋកម្ពុជា និងកាន់តែបំផ្លាញសេរីភាពសារព័ត៌មានក្នុងប្រទេស។

វីអូឌីមានប្រវត្តិវិជ្ជាជីវៈរបស់ខ្លួនរយៈពេល២០ឆ្នាំហើយ បានបម្រើបេសកកម្មរបស់ខ្លួនក្នុងការស្រាយបំភ្លឺរឿងរ៉ាវសំខាន់ៗរបស់កម្ពុជា និងបញ្ហាបច្ចុប្បន្នដែលជាចំណាប់អារម្មណ៍ជាសាធារណៈ។ អង្គភាពព័ត៌មាននេះ បានចេញផ្សាយអត្ថបទរាប់មិនអស់អំពីព័ត៌មាន នយោបាយ និងសិទ្ធិមនុស្ស។

ក្រុមអង្គការសង្គមស៊ីវិលបានកត់សម្គាល់ថា ការវាយប្រហារជាបន្តបន្ទាប់របស់រដ្ឋាភិបាលទៅលើសារព័ត៌មានសេរី គឺបានបង្កើតវប្បធម៌រីករាលដាលនៃ"ការពិនិត្យចាប់កំហុសខ្លួនឯង" និងការភ័យខ្លាចក្នុងចំណោមអ្នកសារព័ត៌មាន។

អតីតអ្នកយកព័ត៌មានវីអូឌីប្រាប់ខេមបូចា ពីការខកចិត្តរបស់លោកចំពោះការបិទវីអូឌី និងការរឹតត្បិតកាន់តែខ្លាំងទៅលើសេរីភាពនៃការបញ្ចេញមតិ។

“មិនមានការអនុវត្តពេញលេញនូវសេរីភាពសារព័ត៌មានទេ ហើយសេរីភាពមានការរួមតូច ជាពិសេសសម្រាប់អ្នកសារព័ត៌មានឯករាជ្យ។ ចំពោះសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធផ្សព្វផ្សាយសង្គម យើងមិនអាចប្រើសិទ្ធិពលរដ្ឋបានពេញលេញនោះទេ»។

លោកបាននិយាយថា “នៅពេលដែលយើងឃើញបញ្ហាអសកម្ម ឬរឿងមួយទៀតកើតឡើង យើងចង់បញ្ចេញមតិរបស់យើង ប៉ុន្តែយើងមិនអាចទេ ដោយសារពួកគេបានប្រើច្បាប់ប្រឆាំងនឹងយើង ហើយយើងព្រួយបារម្ភអំពីការចោទប្រកាន់។ វាមិនមានសុវត្ថិភាពទេ។"

ថ្ងៃទី ១៤ ខែកុម្ភៈ វីអូឌី បានឈប់ផ្សាយជាផ្លូវការ ហើយអតីតនាយករដ្ឋមន្ត្រីលោកហ៊ុន សែន នាពេលនោះ បានផ្តល់ការងាររដ្ឋាភិបាលដល់អ្នកសារព័ត៌មាន និងបុគ្គលិកវីអូឌី ៥៩ នាក់ ដែលបាត់បង់ការងារដោយសារការបិទ។ បុគ្គលចំនួន ២៥ នាក់ បានដាក់ពាក្យ ប៉ុន្តែបុគ្គលិកជាច្រើនមិនបានដាក់ពាក្យទេ។

លោកបានសម្រេចចិត្តមិនចូលបម្រើការងាររដ្ឋាភិបាលបានសម្តែងការព្រួយបារម្ភចំពោះសន្តិសុខ និងសុវត្ថិភាពរបស់ខ្លួន ដោយបារម្ភថាអាជ្ញាធរកំពុងតាមដានសកម្មភាពរបស់លោក។

លោកថា មនុស្សមួយចំនួនបានព្យាយាមបញ្ចុះបញ្ចូលលោកឱ្យទទួលយកការងាររដ្ឋាភិបាល ប៉ុន្តែលោកបានបដិសេធ

គំនិតនេះ ដោយសារលោកចូលចិត្តរាយការណ៍ព័ត៌មាន និងធ្វើការដោយឯករាជ្យ។

លោកថា «សម្រាប់ខ្លួនខ្ញុំ ខ្ញុំបានរងការគំរាមកំហែងពីអាជ្ញាធរមានសមត្ថកិច្ចដែលស្លៀកពាក់ស៊ីវិល ដើម្បីតាមដានខ្ញុំ ជួនកាល គេឈរនៅមុខផ្ទះខ្ញុំ ហើយសូម្បីតែពេលនេះអាជ្ញាធរទាំងនោះក៏នៅតែតាមដានខ្ញុំដែរ ដូច្នេះវាជាការគំរាមកំហែងដល់អារម្មណ៍ខ្ញុំ។»

លោកបន្តថា៖ «ពិតហើយយើងព្រួយបារម្ភ ប៉ុន្តែដោយសារយើងដឹងថា យើងមិនបានធ្វើអ្វីខុសយើងនឹងបន្តធ្វើការងារប្រចាំថ្ងៃរបស់យើង។»

លោកបានលើកឡើងពីទិន្នន័យកំណត់ត្រា ជាវិបសាយជំនួសវីអូឌី។

អ្នកយកព័ត៌មានម្នាក់ទៀត បានចូលបម្រើការងារជាអ្នករាយការណ៍ព័ត៌មាននៅវីអូឌី ក្នុងឆ្នាំ២០១៤ ហើយបច្ចុប្បន្ន បណ្តុះបណ្តាលអ្នកសារព័ត៌មានពលរដ្ឋ។ លោកបានចែករំលែកការយល់ឃើញដូចគ្នាចំពោះការធ្លាក់ចុះសេរីភាពសារព័ត៌មាន។



លោក អ៊ិត សុធឿត ប្រធានផ្នែកសារព័ត៌មាននៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកំពុងផ្តល់ការសម្ភាសនៅមុខការិយាល័យវីអូឌីនៅថ្ងៃបិទស្ថាប័ន ថ្ងៃ១៣ ខែកុម្ភៈ ឆ្នាំ២០២៣ /រូបថតលោកព្រើង សំរាង/ខេមបូចា

លោកនិយាយថា «វាមានការរឹតត្បិតខ្លាំងណាស់ ព្រោះសព្វថ្ងៃអ្នកណាដែលហ៊ានសរសេរអ្វីដែលរិះគន់មន្ត្រី ឬអ្វីដែលប៉ះពាល់ដល់មន្ត្រី នឹងទទួលការគំរាមកំហែង។ មិនថាឡើយវាប៉ះពាល់ដល់មន្ត្រីថ្នាក់ទាប ប៉ុន្តែបើពួកគេចូលទៅជិតមន្ត្រីថ្នាក់ខ្ពស់ ពួកគេប្រាកដជាត្រូវរងការឃាយី និងទទួលរងការគំរាមកំហែង។»

លោកសង្កេតឃើញថា បន្ទាប់ពីការបិទវីអូឌី ថ្វីត្បិតតែប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសមានចំនួនច្រើនក៏ដោយ ក៏នៅមិនទាន់មានអង្គភាពប្រព័ន្ធផ្សព្វផ្សាយឯករាជ្យគ្រប់គ្រាន់ សម្រាប់រាយការណ៍ព័ត៌មានអំពីបញ្ហាសង្គម និងបញ្ហាទាក់ទងនឹងសិទ្ធិមនុស្សជម្លោះដីធ្លី និងធនធានធម្មជាតិដែរ។

វីអូឌីបានចាប់ផ្តើមចាក់ផ្សាយសាជាថ្មី ពោលគឺតាមអនឡាញតែពីបរទេសប៉ុណ្ណោះ ក្នុងខែតុលា ឆ្នាំ២០២៣។ លោកបាននិយាយថា លោកព្រួយបារម្ភចំពោះសុវត្ថិភាពរបស់លោក នៅពេលដែលមិត្តរបស់លោកដែលជាមន្ត្រីប៉ូលិសបានចាប់ផ្តើមសួរសំណួរអំពីការបើកផ្សាយជាថ្មីរបស់វីអូឌី។

លោកបាននិយាយថា មិត្តរបស់ខ្ញុំបានសួរខ្ញុំម្តងទៀតថា 'តើឯងធ្វើការនៅឯណា? ហើយតើឯងធ្វើការងារអ្វី? ឬ តើឯងបានរាយការណ៍ព័ត៌មានទេ?»

អតីតអ្នកយកព័ត៌មានវីអូឌីម្នាក់ទៀតបានសម្រេចចិត្តភៀសខ្លួនចេញពីប្រទេសកម្ពុជា បន្ទាប់ពីទទួលបានសារគំរាមលោកស្រីថាមិនព្រមទៅធ្វើការឱ្យស្ថាប័នរដ្ឋាភិបាល។

លោកស្រីបានប្រាប់ខេមបូចា តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមពីសហរដ្ឋអាមេរិកថា "ខ្ញុំបានទទួលរងការគំរាមកំហែង និងការរើសអើង ហើយមន្ត្រីបានជំរុញឱ្យខ្ញុំធ្វើការជាមួយរដ្ឋាភិបាល"។

លោកស្រី បានអានសារមួយថា៖ «គេនិយាយក្នុង [សារ]ថាបើខ្ញុំមិនចូលរដ្ឋាភិបាលទេ ខ្ញុំនឹងមានបញ្ហា»។

លោកស្រីបានបន្ថែមថា រដ្ឋាភិបាលនៅតែរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងចាប់ផ្តើមចោទប្រកាន់ នៅពេលអ្នកសារព័ត៌មានឯករាជ្យផ្សព្វផ្សាយព័ត៌មានរបស់ពួកគេ។

ពីរសប្តាហ៍បន្ទាប់ពីការបិទវីអូឌី លោកស្រីបានភៀសខ្លួនទៅប្រទេសថៃ។ អ្នកស្រីបានត្រឡប់មកកម្ពុជាវិញក្នុងខែមេសា ដើម្បីធ្វើការនៅមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។ នៅខែកក្កដា អ្នកស្រីបានលាលែងពីស្ថាប័នសារព័ត៌មាននេះ ហើយបានចាកចេញទៅអឺរ៉ុប។ ឥឡូវនេះ អ្នកស្រីធ្វើការជាអ្នកយកព័ត៌មានរបស់វិទ្យុអាស៊ីសេរី ដែលមានមូលដ្ឋាននៅសហរដ្ឋអាម៉េរិក។

អ្នកសារព័ត៌មានស្ត្រីរូបនោះបាននិយាយថា៖«ពួកគេ[អាជ្ញាធរ]បានសួរឪពុកម្តាយខ្ញុំអំពីខ្ញុំ ហើយខ្ញុំប្រាប់ពួកគេថាកុំបារម្ភ»។

អ្នកសារព័ត៌មានមួយរូបទៀត ដែលលោកជានិពន្ធនាយកវីអូឌី និងផ្សាយពីសហរដ្ឋអាមេរិកបាននិយាយថា សេរីភាពសារព័ត៌មានរបស់កម្ពុជាបន្ទាប់ពីការបិទវីអូឌី«ស្ទើរតែសូន្យហើយក៏ធ្លាក់ចុះទៀត»។

លោកថាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យរដ្ឋាភិបាលមានតម្លាភាព និងអភិបាលកិច្ចល្អ។

ដោយសារសុវត្ថិភាពផ្ទាល់ខ្លួន និងការគំរាមកំហែង លោកបានភៀសខ្លួនទៅប្រទេសថៃប្រហែលមួយខែកន្លះបន្ទាប់ពីការបិទវីអូឌី ហើយក្រោយមកបានត្រឡប់មកធ្វើការជាគ្រូបង្គោលនៅ CCIM ពីរបីខែមុន ពេលចាកចេញទៅសហរដ្ឋអាមេរិក។

បន្ទាប់ពីការបិទវីអូឌី លោកបានជួបឧប្បត្តិហេតុគួរឱ្យព្រួយបារម្ភមួយនៅជិតផ្ទះរបស់លោកក្នុងរាជធានីភ្នំពេញ។ លោកថា មានជនមិនស្គាល់អត្តសញ្ញាណពាក់ម៉ាស់បានថតរូបស្លាកលេខម៉ូតូរបស់លោក។ ក្រោយមក លោកបានទៅស្នាក់នៅស្រុកកំណើតនៅខេត្តកំពង់ចាម។ ក្នុងពេលនោះមានមនុស្សចម្លែកពីរនាក់មកសួរនាំទិញដីលោក។

បន្ទាប់ពីមានឧបទ្ទវហេតុទាំងពីរនេះ ថ្នាក់ដឹកនាំរបស់លោក បានអនុញ្ញាតឱ្យលោកចាកចេញពីប្រទេសកម្ពុជា។ លោកបាននិយាយថា លោកត្រូវបានគេបង្ខិតបង្ខំឱ្យធ្វើការជាគ្រូបង្គោលដោយអយុត្តិធម៌។

លោកថា៖ «យើងដឹងថាអំណាចស្ថិតនៅលើមេដឹកនាំតែពីរបីនាក់ប៉ុណ្ណោះ។» លោកលើកឡើងពីការគ្រប់គ្រងរបស់គណបក្សប្រជាជនដែលកំពុងកាន់អំណាចទៅលើតុលាការ និងស្ថាប័ននីតិបញ្ញត្តិ។

នៅឆ្នាំ២០០៣ វីអូឌីបានចាប់ផ្តើមដំណើរការផ្សាយក្រោមមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)។ អង្គភាពនេះត្រូវបានបង្កើតឡើងដោយអតីតគណបក្សប្រឆាំង គឺលោកកឹម សុខា ហើយបន្ទាប់មកបានបំបែកនៅឆ្នាំ២០០៧ ទៅជាអង្គការក្រៅរដ្ឋាភិបាល គឺមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ដែលគ្រប់គ្រងដោយលោកប៉ា ងួនទៀង។ ពេលនេះ លោកជាចាងហ្វាងវីអូឌីនៅក្រៅប្រទេស។

អ្នកយកព័ត៌មានខេមបូចា បានព្យាយាមទាក់ទងអតីតបុគ្គលិកវីអូឌី ដែលបានដាក់ពាក្យបម្រើការងាររដ្ឋាភិបាល ប៉ុន្តែពួកគេបដិសេធមិនធ្វើអត្ថាធិប្បាយទេ ដោយសារខ្លាចមានការសងសឹក ឬបាត់បង់ការងារ។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានព្យាយាមបង្កើតទិន្នន័យព័ត៌មានចូលប្រើប្រាស់សាធារណៈថ្មីមួយ ដែលមានឈ្មោះថា កំណត់ត្រា។ ទិន្នន័យមានព័ត៌មានអំពីការសម្រេចចិត្តរបស់រដ្ឋាភិបាល និងការវិភាគអំពីជម្លោះដីធ្លីទូទាំងប្រទេស។ វាត្រូវបានបិទក្នុងខែកក្កដា ប៉ុន្តែរហូតមកដល់ពេលនេះ វេទិកានេះនៅតែសកម្ម។

លោកស្រីធន សុគន្ធា នាយិកាប្រតិបត្តិរបស់ CCIMបាននិយាយថា វីអូឌីលែងមានទំនាក់ទំនងជាមួយCCIMទៀតហើយ ចំណែកលោក ប៉ា ងួនទៀង ក៏បានលាលែងពីតួនាទីរបស់លោកនៅអង្គការនេះដែរ។

លោកស្រីបានសង្កេតឃើញថា បញ្ហារសើបមានដូចជាជម្លោះដីធ្លី និងការកាប់បំផ្លាញព្រៃឈើមិនត្រូវបានរាយការណ៍ព័ត៌មានដោយប្រព័ន្ធផ្សព្វផ្សាយផ្សេងទេ។

ដោយការបិទវីអូឌី លោកស្រីបាននិយាយថា "យើងឃើញអ្នកសារព័ត៌មានតិចជាងមុន ដែលហ៊ានផ្សព្វផ្សាយព័ត៌មានអំពីបញ្ហារសើប"។

លោកស្រីថា «យើងក៏ឃើញដែរថា អ្នកដែលចុះផ្សាយបញ្ហារសើបកំពុងទទួលរងការគំរាមកំហែងដោយផ្ទាល់ពីក្រសួងព័ត៌មាន និងក្រសួងពាក់ព័ន្ធដទៃទៀត ដូច្នេះហើយទើបធ្វើឱ្យអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយភ័យខ្លាច។ ពួកគេត្រូវប្រយ័ត្នប្រយែងក្នុងការផ្ទៀងផ្ទាត់ខ្លឹមសារមុនពេលចេញផ្សាយអត្ថបទ។

លោកស្រី សុគន្ធា បានបន្តថា៖ «ខ្ញុំគិតថាចំនួនអ្នកសារព័ត៌មាន [ឯករាជ្យ] នឹងធ្លាក់ចុះនៅពេលអនាគត»។

យ៉ាងណាក៏ដោយ អ្នកនាំពាក្យរដ្ឋាភិបាលលោកប៉ែន បូណា បាននិយាយថាការបិទវីអូឌីមិនប៉ះពាល់ដល់សេរីភាពសារព័ត៌មាននៅកម្ពុជាទេ។

លោកបាននិយាយថា "វាមិនត្រឹមត្រូវទេ ដែលយកអ្នកសារព័ត៌មានរាប់ម៉ឺននាក់មកធ្វើជាចំណាប់ខ្មាំងអ្នកសារព័ត៌មានពីរបីនាក់ [វីអូឌី] ដែលមិនគោរពច្បាប់កម្ពុជានោះ"។

លោក បូណា បាននិយាយថា៖«សូមឱ្យសំឡេងដល់អ្នកសារព័ត៌មានភាគច្រើន។ លោកថា កម្ពុជាមានអង្គភាពប្រព័ន្ធផ្សព្វផ្សាយដែលបានចុះឈ្មោះជាង ២០០០ ហើយក៏មានអ្នកសារព័ត៌មានរាប់ម៉ឺននាក់ធ្វើការដោយសេរីរួមទាំងនៅខេមបូចាដែរ។

លោកបានចោទជាសំណួរថា «ហេតុអ្វីបានជាលើកយកប្រព័ន្ធផ្សព្វផ្សាយតែមួយ ហើយធ្វើការសន្និដ្ឋានអំពីស្ថានភាពសេរីភាពសារព័ត៌មាននៅទូទាំងប្រទេស?

អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ទូច សុឃៈ បានច្រានចោលការចោទប្រកាន់របស់អតីតអ្នកយកព័ត៌មានវីអូឌី ដែលចោទអាជ្ញាធរថាបានឃ្លាំមើលសកម្មភាពរបស់ពួកគេ និងបំពានលើសន្តិសុខរបស់ពួកគេ។

លោកបាននិយាយថា "មិនមានភស្តុតាងណាមួយដែលបង្ហាញថា អាជ្ញាធរបានគំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខរបស់ពួកគេទេ ហើយខ្ញុំគិតថា អាជ្ញាធរបានដឹងយ៉ាងច្បាស់អំពីភារកិច្ច ហើយពួកគេយល់ពីសិទ្ធិ និងសេរីភាពរបស់បុគ្គលម្នាក់ៗ"។

លោកសុឃៈថា «ពួកគេ [អាជ្ញាធរ] មិនអាចធ្វើរឿងបែបនេះបានទេ ប៉ុន្តែខ្ញុំបារម្ភថា [អ្នកយកព័ត៌មានវីអូឌី] ទាំងនោះបានបង្ហាញពីអារម្មណ៍របស់ពួកគេ ហើយធ្វើឱ្យប្រធានបទនេះកាន់តែចម្រូងចម្រាស ដើម្បីមានសំឡេងដើម្បីសម្រេចគោលដៅរបស់ពួកគេក្នុងការសម្រេចបាននូវរបៀបវារៈនយោបាយ»។

លោកជំរុញឱ្យបង្ហាញភ័ស្តុតាងរឹងមាំ និងដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចដែលអាចអនុវត្តនីតិវិធីទៅតាមច្បាប់។ ហើយលោកក៏បានស្នើថាអ្នកសារព័ត៌មានយល់ច្រឡំចំពោះមន្ត្រីអនុវត្តច្បាប់ដែលដើរល្បាតជាធម្មតាថាជាទង្វើយាយីទៅវិញ។

នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោកស្រី ចក់ សុភាព បានហៅការបិទវីអូឌីជាផ្នែកនៃ "ការបង្ក្រាបកាន់តែធំ" ទៅលើសារព័ត៌មានសេរីចាប់តាំងពីឆ្នាំ២០១៧មក ដែលត្រូវបានគេមើលឃើញថា ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរបស់កម្ពុជាភាគច្រើនត្រូវបិទ ឬបំបិទមាត់។

លោកស្រីបាននិយាយតាមរយៈអ៊ីមែលថា "ការដកហូតអាជ្ញាបណ្ណរបស់វីអូឌី មិនត្រឹមតែរាំងសេរីភាពសារព័ត៌មានប៉ុណ្ណោះទេ តែថែមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដែរ"។ លោកស្រី បានបន្ថែមថា វាជាសិទ្ធិសម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប ដើម្បីទទួលបានព័ត៌មានអំពីព្រឹត្តិការណ៍សំខាន់ៗដែលកើតឡើងក្នុងនិងក្រៅប្រទេស។

លោកទេព អស្នារិទ្ធ អ្នកនាំពាក្យក្រសួងព័ត៌មានបាននិយាយថា កាលពីខែធ្នូ ឆ្នាំ២០២៣ ក្រសួងមិនមានការអត្ថាធិប្បាយបន្ថែមទេពាក់ព័ន្ធនឹងការសម្រេចបិទវីអូឌី៕

# VI. ស្ថានភាពទូទៅនៃវិស័យសារព័ត៌មាន

## ១. ស្ថានភាពសារព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត ២០២៣

ក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតជាតិឆ្នាំ២០២៣ អ្នកសារព័ត៌មាននៅតែប្រឈមនឹងការរំខាន និងការយាយីខណៈរដ្ឋាភិបាលបានបញ្ជាឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ឃ្លាំមើលស្ថាប័នផ្សព្វផ្សាយដាក់លាក់មួយចំនួន។

នៅថ្ងៃបោះឆ្នោតជាតិ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ យ៉ាងហោចណាស់អ្នកសារព័ត៌មាន និងអ្នកថតរូបជាអ្នកសារព័ត៌មាន១០នាក់បានរងនូវការរឹតត្បិត។ ក្នុងនោះមានអ្នកសារព័ត៌មាន៣នាក់របស់វីអូអេ និងខេមបូចាត្រូវបានឃ្លាំមើល និងរាំងនៅពេលពួកគេព្យាយាសម្ភាសជាមួយមេដឹកនាំបក្សជំទាស់។ អ្នកសារព័ត៌មានខេមបូចាផ្សេងទៀតត្រូវបានយាយី និងរាំងពេលព្យាយាមថតរូប និងសម្ភាសនៅការិយាល័យបោះឆ្នោត។

អ្នកសារព័ត៌មានជាច្រើនទៀតក៏បានរៀបរាប់ដូចគ្នាដែរពីការប្រឈមនឹងមន្ត្រីនៅការិយាល័យបោះឆ្នោតដោយពួកគេត្រូវបានរាំង មិនឱ្យថតរូប និងធ្វើសេចក្តីរាយការណ៍។ អ្នកសារព័ត៌មានខ្លះអះអាងថា ពួកគេត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីរាយការណ៍ បន្ទាប់ពីពួកគេបានជម្នះនឹងការរាំង ប៉ុន្តែក៏មានអ្នកសារព័ត៌មានផ្សេងទៀតនៅតែមិនត្រូវបានអនុញ្ញាតដែរ។ ក្នុងករណីខ្លះមន្ត្រីបោះឆ្នោតថែមទាំងបានថតរូបពួកគេពេលកំពុងយកព័ត៌មានផងដែរ។

បន្ថែមពីនេះទៀតក្រសួងព័ត៌មានបានបញ្ជាឱ្យ និយតករទូរគមនាគមន៍កម្ពុជា(TRC) បិទគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយចំនួនមុន នឹងអំឡុងពេលបោះឆ្នោត។

បទបញ្ជានេះបញ្ជាក់ពីការរឹតត្បិតដោយសារតែការផ្សាយព័ត៌មានរិះគន់រដ្ឋាភិបាលដោយអះអាងថា ប្រព័ន្ធផ្សព្វផ្សាយ និងទិន្នន័យផ្សព្វផ្សាយព័ត៌មានទាំងនោះ«ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកិត្យានុភាពរបស់រដ្ឋាភិបាល»។

ការបិទគេហទំព័រទាំងនេះបានរឹតត្បិតការចូលប្រើគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមដែលពាក់ព័ន្ធជាមួយខេមបូឌាដេលី និងវិទ្យុអាស៊ីសេរី និងគេហទំព័រកំណត់ត្រា ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។

ព្រឹត្តិការណ៍ដែលកើតឡើងមុន និងក្នុងអំឡុងពេលបោះឆ្នោតមិនត្រឹមតែរឹតត្បិតសេរីភាពសារពត៌មានប៉ុណ្ណោះទេ ប៉ុន្តែរាំងដល់គោលការណ៍លទ្ធិប្រជាធិបតេយ្យផងដែរ។ អាជ្ញាធរនិងភាគីពាក់ព័ន្ធផ្សេងទៀត បានប្រើប្រាស់គ្រប់មធ្យោបាយដើម្បីរាំងអ្នកសារព័ត៌មានក្នុងការធ្វើសេចក្តីរាយការណ៍ដោយឯករាជ្យក្នុងថ្ងៃបោះឆ្នោត។ ទាំងនេះបានបញ្ជាក់ពីសេរីភាពសារពត៌មាន សេរីភាពនៃការបញ្ចេញមតិ និងតួនាទីរបស់សារព័ត៌មានឯករាជ្យគឺចាំបាច់នៅក្នុងប្រទេសកម្ពុជា៕

## ២.ក្រសួងបង្កើតក្រុមការងារប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ

ក្រសួងព័ត៌មាននឹងបង្កើតក្រុមការងាររួម ដោយមានសមាជិកមកពីគ្រប់ក្រសួងស្ថាប័នរបស់រដ្ឋាភិបាលដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ។

សេចក្តីសម្រេចនេះបានធ្វើឡើងក្នុងកិច្ចប្រជុំជាមួយអន្តរក្រសួង និងស្ថាប័នចំនួន៣០ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

ក្រុមការងារនឹងផ្លាស់ប្តូរព័ត៌មាន និងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសមិទ្ធផល និងសកម្មភាពរបស់ក្រសួង ស្ថាប័ន តាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិ និងឯកជន និងប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត ដែលមានបំណងវាយប្រហារលើក្រសួងស្ថាប័នរដ្ឋាភិបាល។

ក្រុមការងារនេះនឹងធ្វើការជាមួយក្រុមការងារផ្ទាល់របស់លោកនាយករដ្ឋមន្ត្រីហ៊ុន ម៉ាណែត ដែលដឹកនាំដោយលោកគួច វេងស្រ៊ុន រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដែលគ្រប់គ្រងទំព័រផ្សព្វផ្សាយបណ្តាញសង្គមរបស់លោក ហ៊ុន ម៉ាណែត។

លោកនេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មានបាននិយាយថា ក្រសួងព័ត៌មានត្រូវតែជាស្ថាប័នទំនាក់ទំនងសាធារណៈរបស់រដ្ឋាភិបាល ហើយដើរតួនាទីជាសំឡេងរបស់រដ្ឋាភិបាល។

តាមរយៈការងារនេះលោករដ្ឋមន្ត្រីបានស្នើដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផ្តល់អត្ថបទ ខ្លឹមសារ រូបភាព និងវីដេអូ ដើម្បីប្រើប្រាស់ជាឧបករណ៍ក្នុងការលើកកម្ពស់ឱ្យបានទូលំទូលាយនូវទំនុកចិត្តរបស់រដ្ឋាភិបាល និងការពិតរបស់រដ្ឋាភិបាល៕

## ៣. កាសែតជាភាសាខ្មែរបានបិទទ្វារ បន្ទាប់ពីដំណើរការអស់រយៈពេលបីទសវត្សរ៍

បន្ទាប់ពីផ្អាកការបោះពុម្ពរយៈពេលបីឆ្នាំរួចមក កាសែតរស្មីកម្ពុជា ដែលជាកាសែតភាសាខ្មែរចំណាស់ជាងគេក្នុងប្រទេស បានបិទគេហទំព័ររបស់ខ្លួនជាផ្លូវការហើយ។

ដំណើរការបោះពុម្ពបានបញ្ចប់នៅចុងឆ្នាំ ២០១៩ បន្ទាប់ពីបោះពុម្ពផ្សាយក្នុងប្រទេសកម្ពុជាអស់រយៈពេលប្រមាណ៣០ឆ្នាំ។ កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ កាសែតរស្មីកម្ពុជា បានប្រកាសបញ្ឈប់បុគ្គលិកជាង៣០នាក់រួមទាំងបុគ្គលិកជាស្ត្រី៥នាក់ផងដែរ។ នៅថ្ងៃបន្ទាប់មកកាសែតនេះបានបិទអនឡាញរបស់ខ្លួនរួមទាំងគេហទំព័រព័ត៌មាន និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ។

លោក ទាវ សារៈមុន្នី និពន្ធនាយកកាសែតរស្មីកម្ពុជា បាននិយាយថា មូលហេតុចម្បងនៃការបិទ គឺទាក់ទងនឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ៕

# VII. ព័ត៌មានបច្ចុប្បន្នភាពសំខាន់ៗ

## ១. លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ចេញអនុសាសន៍សម្រាប់វិស័យសារព័ត៌មាន៖




លោកនាយករដ្ឋមន្ត្រីហ៊ុន ម៉ាណែត (រូបពីហ្វេសប៊ុកលោកនាយករដ្ឋមន្ត្រីហ៊ុន ម៉ាណែត)

កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ ក្នុងសារលិខិតផ្ញើទៅកាន់វេទិកានិពន្ធនាយកលើកទី២០ ក្រោមប្រធានបទ «វិជ្ជាជីវៈ និងក្រមសីលធម៌សារព័ត៌មាន» លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែតបានលើកឡើងពីសារៈសំខាន់ នៃតួនាទីរបស់វិស័យសារព័ត៌មាន និងការងាររបស់អ្នកសារព័ត៌មាន ប៉ុន្តែបានសង្កត់ធ្ងន់ថា វិជ្ជាជីវៈ និងក្រមសីលធម៌អ្នកសារព័ត៌មាននៅមានកម្រិតនៅឡើយ ជាពិសេសក្នុងចំណោមអ្នកសារព័ត៌មានអនឡាញ។ លោក ហ៊ុន ម៉ាណែត បាននិយាយថា ចាំបាច់ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីទទួលបានទំនុកចិត្តពីសាធារណជន។

លោកបន្តថា សមិទ្ធផល និងជោគជ័យរបស់រដ្ឋាភិបាលរហូតមកដល់ពេលនេះ គឺបានមកពីការចូលរួមពីវិស័យសារព័ត៌មាន និងអ្នកសារព័ត៌មាន ដែលធ្វើការជាដៃគូជាមួយរដ្ឋាភិបាល។ លោកបន្តថា រដ្ឋាភិបាលតែងតែលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន ព្រមទាំងលើកទឹកចិត្តឱ្យមានការកសាងសមត្ថភាពបន្ថែមទៀតក្នុងវិស័យសារព័ត៌មាន ក៏ដូចជាការពង្រឹងវិជ្ជាជីវៈ និងក្រមសីលធម៌ផងដែរ។ លោកម៉ាណែតបានបន្តថា ក្នុងអាណត្តិទី៧ របស់រដ្ឋាភិបាល លោកបានសន្យាដើរតាមឪពុករបស់លោក គឺអតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីលើកស្ទួយវិស័យសារព័ត៌មាន ដោយផ្តល់ការលើកលែងពន្ធប៉ាតង់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយអនឡាញប្រភេទធុនតូចទាំងអស់រយៈពេល៥ឆ្នាំ រហូតដល់ឆ្នាំ២០២៨។ រដ្ឋាភិបាលក៏នឹងផ្តល់ការកាត់បន្ថយកម្រៃអាជ្ញាបណ្ណចំនួន ៥០%ផងដែរ។

អនុសាសន៍របស់នាយករដ្ឋមន្ត្រី ដើម្បីដោះស្រាយការបំពានវិជ្ជាជីវៈ និងក្រមសីលធម៌ និងប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ និងការញុះញង់៖

- ចូលរួមថែរក្សាសុខសន្តិភាព ការអភិវឌ្ឍប្រទេសជាតិ និងពង្រឹងលទ្ធិប្រជាធិបតេយ្យផ្អែកលើការអនុវត្តច្បាប់ ក្រមសីលធម៌ វិជ្ជាជីវៈឱ្យបានខ្ជាប់ខ្ជួន និងត្រូវលុបបំបាត់ជនឱកាសនិយម ដែលជ្រកក្រោមស្លាកសារព័ត៌មាន។
- ផ្តល់ព័ត៌មានពិតដល់សាធារណជនជាតិ-អន្តរជាតិ អំពីសភាពការណ៍ពិតនៅកម្ពុជា និងផ្សព្វផ្សាយគោលនយោបាយរបស់រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ និងនាំព័ត៌មានពីប្រជាពលរដ្ឋមកកាន់រដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។
- ធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងអំពីភាពពិតជាក់ស្តែង និងភាពអសកម្មនៅក្នុងសង្គម ដើម្បីរដ្ឋាភិបាល ដោះស្រាយបញ្ហាចំគោលដៅមានប្រសិទ្ធភាព ស្របតាមកម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាល

- ផ្សព្វផ្សាយអប់រំដល់សាធារណជនអំពីវិធានការបង្ការគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ការជួញដូរមនុស្ស គោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការប្រើប្រាស់គ្រឿងញៀន និងរក្សាសុវត្ថិភាពសង្គម។
- បន្តចូលរួមប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ ដែលមានចរិតបំពុលសង្គម អាចធ្វើឱ្យប្រទេសជាតិអស្ថិរភាពនយោបាយ ចលាចល ភាពវឹកវរ និងបាត់បង់សណ្តាប់ធ្នាប់សង្គម។
- ប្រកាន់ខ្ជាប់ក្រមសីលធម៌ វិជ្ជាជីវៈ ផ្សាយព័ត៌មានពិត មានតុល្យភាពគ្រប់ជ្រុងជ្រោយ ចៀសវាងការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យខូចផលប្រយោជន៍ជាតិ និងបាត់បង់ទំនុកចិត្តពីសាធារណជន។
- បណ្តុះបណ្តាលសមត្ថភាពជំនាញរបស់អ្នកសារព័ត៌មានទាំងបច្ចេកទេស និងវិជ្ជាជីវៈដើម្បីលើកកម្ពស់គុណភាពព័ត៌មាន សណ្តាប់ធ្នាប់វិស័យព័ត៌មាន និងកិត្យានុភាពស្ថាប័នសារព័ត៌មាន។

## ២. អ្នកសារព័ត៌មានត្រូវបានដោះលែង បន្ទាប់ពីជាប់ពន្ធនាគារ២ឆ្នាំ

អ្នកសារព័ត៌មានអនឡាញប្រចាំខេត្តបាត់ដំបង ត្រូវបានដោះលែងនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ បន្ទាប់ពីជាប់ពន្ធនាគាររយៈពេល២ឆ្នាំ។

អ្នកសារព័ត៌មានរូបនេះត្រូវបានចាប់ខ្លួន បន្ទាប់ពីរិះគន់ជាសាធារណៈចំពោះការប្រើប្រាស់វ៉ាក់សាំងរបស់រដ្ឋាភិបាល ដែលផលិតដោយប្រទេសចិន។

ការចាប់ខ្លួននេះបាននាំឱ្យចំនួនអ្នកសារព័ត៌មាន ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ ២០២១កើនឡើងដល់៤នាក់ ដោយសារការរាយការណ៍ព័ត៌មានរបស់ពួកគេអំពីការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាត។

អ្នកសារព័ត៌មាន ដែលធ្វើការក្នុងវិស័យនេះជាង៨ឆ្នាំ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ នៅឆ្នាំ២០២១។

លោកបានប្រាប់ខេមបូចា កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣ ថា ការចោទប្រកាន់មកលើរូបលោក គឺជារឿងអយុត្តិធម៌។ លោកថា៖ «គ្មានចំណុចណាមួយដែលត្រូវចោទប្រកាន់ខ្ញុំពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ព្រោះគ្មាននរណាម្នាក់បានធ្វើតាមខ្ញុំនោះទេ។»

លោកនិយាយថា លោកនៅតែបន្តធ្វើការជាអ្នកសារព័ត៌មាន ហើយបន្តរាយការណ៍ព័ត៌មានអំពីបញ្ហាសេីបៗដែលប្រព័ន្ធផ្សព្វផ្សាយដទៃមិនអាចធ្វើបាន។

លោកថា «ខ្ញុំនៅតែធ្វើការជាអ្នកសារព័ត៌មាន។ ឥឡូវខ្ញុំបានដាក់ពាក្យសុំកាតសារព័ត៌មាន ពីក្រសួងព័ត៌មាន ប៉ុន្តែខ្ញុំមិនច្បាស់ថាខ្ញុំនឹងទទួលបានកាតឬអត់នោះទេ។»

លោកបានបម្រើការឱ្យអង្គភាពសារព័ត៌មានជាច្រើន ដូចជាទីភ្នាក់ងារព័ត៌មានប្រចាំខេត្តសៀមរាប និងព័ត៌មានផ្សព្វផ្សាយសង្គមជាតិ។

### ៣. ផលិតករទូរទស្សន៍អនឡាញត្រូវបានដោះលែងបន្ទាប់ពីជាប់ពន្ធនាគារមួយឆ្នាំ

*ផលិតករទូរទស្សន៍TCN ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៦ ឧសភា ឆ្នាំ២០២២ ត្រូវបានដោះលែងវិញបន្ទាប់ពីជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ។*

*លោកប្រាប់ខេមបូចាថា លោកត្រូវបានដោះលែងនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២៣។ លោក បាននិយាយថា ពេលនេះលោកនៅតែធ្វើការឱ្យទូរទស្សន៍ TCN និងកំពុងស្វែងរកការបន្តអាជ្ញាបណ្ណអង្គភាពប្រព័ន្ធផ្សព្វផ្សាយរបស់លោក។*

*លោកត្រូវបាននគរបាលខេត្តកណ្តាលប្តឹង។ លោកបានផ្សាយព័ត៌មានដែលអះអាងថា អាជ្ញាធរខេត្តកណ្តាលបានទទួលសំណូកពីម្ចាស់ល្បែងស៊ីសងខុសច្បាប់ដោយធ្វើមិនដឹងមិនឮ។ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល លោកអាត់ ចាន់តារាបាននិយាយថា អ្នកសារព័ត៌មានរូបនេះត្រូវបានចោទប្រកាន់ពីបទ «ញុះញង់ឱ្យមានការរើសអើង និងបរិហារកេរ្តិ៍ជាសាធារណៈ» តាមមាត្រា ៤៩៤, ៤៩៦, និង ៣០៥ នៃក្រមព្រហ្មទណ្ឌ។ ទីបំផុតលោកត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារមួយឆ្នាំ។*

*មន្ត្រីនគរបាលខេត្តកណ្តាលបាននិយាយថា ការផ្សាយព័ត៌មាននេះបានចោទថា មន្ត្រីនគរបាល និងកងរាជអាវុធហត្ថបានឃុបឃិតគ្នាបើកល្បែងស៊ីសងខុសច្បាប់ កត់ឆ្នោត និងជល់មាន់ នៅក្នុងខេត្តកណ្តាល។*

### ៤. ចាងហ្វាងការផ្សាយត្រូវបានដោះលែងឱ្យនៅក្រៅឃុំ បន្ទាប់ពីត្រូវជាប់ឃុំបណ្តោះអាសន្នរយៈពេលបីខែ

*ចាងហ្វាងសារព័ត៌មានជាយដែន ត្រូវបានដោះលែងពីពន្ធនាគារនៅថ្ងៃទី១០ ខែឧសភា បន្ទាប់ពីត្រូវចាប់ខ្លួននៅថ្ងៃទី១២ ខែកុម្ភៈ ហើយបញ្ជូនទៅពន្ធនាគារពីរថ្ងៃក្រោយមកនៅខេត្តបន្ទាយមានជ័យ។*

*លោកត្រូវបានចោទប្រកាន់ពីរករណី គឺបទញុះញង់ និងក្លែងបន្លំឯកសារ។*

*អ្នកសម្របសម្រួលប្រចាំតំបន់នៃអង្គការសិទ្ធិមនុស្សលីកាដូបានប្រាប់ខេមបូចា ថា អ្នកសារព័ត៌មានរូបនេះ បានចុះផ្សាយព័ត៌មានជាបន្តបន្ទាប់អំពីអំពើពុករលួយនៅក្នុងមន្ទីរសុខាភិបាលខេត្ត និងការិយាល័យពន្ធដារ។*

*អ្នកសារព័ត៌មានរូបនេះត្រូវបានមន្ត្រីមកពីមន្ទីរ និងការិយាល័យនេះប្តឹងពីបទញុះញង់ និងបរិហារកេរ្តិ៍។ លោកក៏ត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារ ដើម្បីទទួលបានបណ្ណកម្មសិទ្ធិនៅក្រុងប៉ោយប៉ែតដែរ។*

## ៥. កម្ពុជាធ្លាក់ចុះសន្ទស្សន៍សេរីភាពសារព័ត៌មានឆ្នាំ២០២៣

*យោងតាមរបាយការណ៍របស់អង្គការ អ្នកសារព័ត៌មានគ្មានព្រំដែន ដែលចេញផ្សាយក្នុងទិវាសេរីភាពសារព័ត៌មានពិភពលោក កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ ចំណាត់ថ្នាក់សេរីភាពសារព័ត៌មានរបស់កម្ពុជា នៅឆ្នាំ២០២៣ ។*

*កម្ពុជាជាប់ចំណាត់ថ្នាក់លេខ១៤៧ ក្នុងចំណោមប្រទេសចំនួន១៨០ ពោលគឺធ្លាក់ចុះពីចំណាត់ថ្នាក់លេខ១៤២ ក្នុងឆ្នាំ ២០២២។*

*ពិន្ទុសរុបរបស់ប្រទេសកម្ពុជាបានធ្លាក់ចុះមួយពិន្ទុពី៤៣ ក្នុងឆ្នាំ ២០២២ មកនៅត្រឹម៤២ ក្នុងឆ្នាំ ២០២៣។ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានកត់សម្គាល់ថា កម្ពុជាមានចំណាត់ថ្នាក់ខ្ពស់ជាងប្រទេសវៀតណាម មីយ៉ាន់ម៉ា និងឡាវ។*

*របាយការណ៍និយាយពីកម្ពុជាថា៖ «ការផ្លាស់ប្តូរតាមបែបប្រជាធិបតេយ្យដែលបានចាប់ផ្តើមនៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ បានធ្វើឱ្យមានសារព័ត៌មានរីកដុះដាល រហូតមកដល់អតីតនាយករដ្ឋមន្ត្រី លោកហ៊ុន សែន ដែលកាន់អំណាចយូរមក ហើយបានបង្កើតការរឹតត្បិតប្រឆាំងនឹងសារព័ត៌មានឯករាជ្យនៅមុនការបោះឆ្នោតឆ្នាំ ២០១៨»។*

*អ្នកសារព័ត៌មានគ្មានព្រំដែនបាននិយាយថា "ស្ថានីយវិទ្យុ និងការសែតត្រូវបំបិទមាត់ បន្ទប់ព័ត៌មានត្រូវបានកម្ទាត់ចោលអ្នកសារព័ត៌មានត្រូវបានផ្តន្ទាទោសដែលធ្វើឱ្យវិស័យសារព័ត៌មានឯករាជ្យត្រូវបំផ្លាញចោល"។ អង្គការនេះបញ្ជាក់ថា យុទ្ធសាស្ត្រស្រដៀងគ្នានេះក៏ត្រូវបានប្រើដែរ មុនការបោះឆ្នោតនៅឆ្នាំ២០២៣។*

*ប្រភព:* https://rsf.org/en/country/cambodia

# VIII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

*ទោះបីរបាយការណ៍នេះនៅមានចន្លោះប្រហោងក៏ដោយ ក៏ករណីដែលរួមបញ្ចូលគ្នានេះបង្ហាញឱ្យឃើញនូវទិដ្ឋភាពគួរឱ្យព្រួយបារម្ភទៅលើស្ថានភាពសារព័ត៌មាននៅកម្ពុជានាពេលបច្ចុប្បន្ននេះ។ អ្នកសារព័ត៌មានបន្តរាយការណ៍ព័ត៌មានអំពីការរំលោភបំពានអំណាចអំពើពុករលួយ អាកប្បកិរិយាមិនសមរម្យជាផ្លូវការ និងភាពអយុត្តិធម៌ ទោះបីជាមានហានិភ័យផ្ទាល់ខ្លួន និងហានិភ័យដល់វិជ្ជាជីវៈរបស់ខ្លួនក៏ដោយ។*

*រដ្ឋាភិបាលថ្មីបាននាំមកនូវសុទិដ្ឋិនិយមខ្លះៗ នៃមធ្យោបាយថ្មីមួយចំពោះសំឡេងរិះគន់ ប៉ុន្តែសញ្ញាដំបូងគឺមិនល្អទេ។ លោក ហ៊ុន ម៉ាណែតបានបញ្ចេញសារដែលមិនស៊ីចង្វាក់គ្នាទៅនឹងការការពារដែលមានចែងក្នុងច្បាប់កម្ពុជា ដោយប្រាប់អ្នកសារព័ត៌មានឱ្យចៀសវាងព័ត៌មានដែលធ្វើឱ្យប្រទេសបាត់មុខមាត់ និងបាត់បង់ការជឿជាក់ពីសាធារណជន។ អ្នកសារព័ត៌មានគួរត្រូវបានការពារក្នុងការរាយការណ៍ព័ត៌មានពិត ហើយទុកឱ្យសាធារណជនជាអ្នកសម្រេច។*

*របាយការណ៍នេះបានបន្ថែមពីលើការរកឃើញរបស់អង្គការផ្សេងទៀត ដែលបានរៀបរាប់ពីស្ថានភាពគួរឱ្យព្រួយបារម្ភនៃប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ននេះ។ ភាពធ្ងន់ធ្ងរនៃបញ្ហា គឺឆ្លុះបញ្ចាំងឱ្យឃើញនូវការធ្លាក់ចុះចំណាត់ថ្នាក់របស់កម្ពុជានៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក។*

*ទោះបីជាយើងបានកត់ត្រាការថយចុះបន្តិចនៃចំនួនករណីបើប្រៀបធៀបទៅនឹងឆ្នាំមុនក៏ដោយ ក៏ស្ថានភាពទាំងមូលនៅតែគួរឱ្យព្រួយបារម្ភដែរ។ នៅឆ្នាំនេះយើងបានឃើញការកើនឡើងនៃករណីយាយីតាមផ្លូវច្បាប់ទៅលើអ្នកសារព័ត៌មាន រួមទាំងការដកអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ និងការគំរាមកំហែងដាក់ពន្ធនាគារជាដើម។ ខណៈរដ្ឋាភិបាលអះអាងថាវិស័យសារព័ត៌មានកំពុងដំណើរការល្អដោយយោងទៅលើចំនួននៃអង្គភាពប្រព័ន្ធផ្សព្វផ្សាយជាក់ស្តែង លំហសម្រាប់អ្នកសារព័ត៌មាន ក្នុងការទាមទារឱ្យមានការទទួលខុសត្រូវពីអ្នកដឹកនាំនយោបាយគឺកំពុងតែធ្លាក់ចុះ។*

*រដ្ឋាភិបាលដែលបានប្តេជ្ញាចិត្តយ៉ាងពិតប្រាកដចំពោះសារព័ត៌មានសេរី គួរតែអនុញ្ញាតឱ្យវិទ្យុសំឡេងប្រជាធិបតេយ្យដំណើរការឡើងវិញ បញ្ឈប់ការគំរាមកំហែងអ្នកសារព័ត៌មានដែលបំពេញការងាររបស់ពួកគេ ហើយដាក់ទណ្ឌកម្ម ឬផ្តន្ទាទោសមន្ត្រី និងបុគ្គលដែលបន្តយាយីអ្នកសារព័ត៌មាន។*

*ការពិនិត្យចាប់កំហុសលើអង្គភាពប្រព័ន្ធផ្សព្វផ្សាយណាមួយ និងការបំភិតបំភ័យអ្នកសារព័ត៌មាននៅថ្ងៃបោះឆ្នោត គឺប៉ះពាល់ដល់គោលការណ៍ប្រជាធិបតេយ្យ ហើយធ្វើឱ្យខូចដល់ការជឿទុកចិត្តរបស់សាធារណជននៅក្នុងទាំងប្រព័ន្ធផ្សព្វផ្សាយ និងការបោះឆ្នោត។*

*ផែនការដាក់ឱ្យប្រើប្រាស់ច្រកទ្វារអ៊ីនធឺណិតជាតិ គឺជាឧបករណ៍ដ៏គ្រោះថ្នាក់ ហើយភាគីពាក់ព័ន្ធត្រូវតែជំរុញរដ្ឋាភិបាលឱ្យជៀសវាងការតាមដានឃ្លាំមើលដ៏ច្រើនលើសលុប ដែលកាន់តែបិទលំហសម្រាប់ការបញ្ចេញមតិដោយសេរី និងសិទ្ធិទទួលបានព័ត៌មាន។*

*អស់រយៈពេល៣ឆ្នាំមកហើយ របាយការណ៍នេះចាត់ទុកជាការរម្លឹកជាបន្ទាន់អំពីការគំរាមកំហែងដែលអ្នកអ្នកសារព័ត៌មានប្រឈមមុខ និងតម្រូវឱ្យមានច្បាប់ គោលនយោបាយ និងវិធានការដែលធានានូវការការពាររបស់ពួកគេ។ ប៉ុន្តែការណ៍នេះនឹងមិនផ្លាស់ប្តូរបានទេ បើគ្មានឆន្ទៈនយោបាយ ដែលតម្រូវឱ្យមានការចូលរួមពីសាធារណៈ។*

*ខេមបូចាសង្ឃឹមថា ក្នុងពេលឆាប់ៗនេះអ្នកសារព័ត៌មាននឹងអាចធ្វើការដោយសេរីនៅក្នុងប្រទេសកម្ពុជា ដោយមិនភ័យខ្លាចពីការសងសឹកឡើយ៕*

## អនុសាសន៍

រដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធគួរលើកកម្ពស់សេរីភាពសារព័ត៌មាន និងគោរពកាតព្វកិច្ចវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដូចជាភាពឯកជនរបស់ប្រភព ក៏ដូចជាបង្ហាញការប្តេជ្ញាចិត្តក្នុងការបញ្ចប់ការយាយីលើអ្នកសារព័ត៌មាន។

១. ឈប់ចោទប្រកាន់បទព្រហ្មទណ្ឌមក លើអ្នកសារព័ត៌មានទាក់ទងនឹងការ ងារសារព័ត៌មានរបស់ ពួកគេ អ្នកសារព័ត៌មាន ពលរដ្ឋ អ្នកការពារសិទ្ធិមនុស្ស និងអ្នកប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម។

២. បញ្ចប់និទណ្ឌភាពដោយធ្វើ ការស៊ើបអង្កេត ផ្តន្ទាទោស និងដោះស្រាយ ករណីហិង្សាលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សជាបន្ទាន់។

៣. ផ្តល់ការគាំទ្រ ការបណ្តុះបណ្តាល និងធនធានពេញទំហឹង ដល់អង្គភាពដែលមានភារកិច្ចស៊ើបអង្កេតឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន រួមទាំងការគាំទ្រលើការស៊ើបអង្កេតបទ ឧក្រិដ្ឋបែបនេះដោយគិតអំពីយេនឌ័រផងដែរ ។

៤. ទម្លាក់ចោលភ្លាមៗនូវ ការចោទប្រកាន់ដែលតុលាការ មិនទាន់សម្រេច ហើយពិនិត្យមើលឡើងវិញនូវការផ្តន្ទាទោសអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សពីបទព្រហ្មទណ្ឌ និងស៊ើបអង្កេតករណីហិង្សាលើពួកគេ។

៥. ពិនិត្យមើលឡើងវិញភ្លាមៗនូវសេចក្តីសម្រេចកន្លងមកដែលបានលុបអាជ្ញាបណ្ណព័ត៌មាន និងកំណែទម្រង់បទបញ្ញត្តិជុំវិញការផ្តល់អាជ្ញាបណ្ណព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដូច្នេះអាជ្ញាបណ្ណព័ត៌មាន អាចត្រូវបានលុបចោលតាមរយៈដីការសម្រេចរបស់តុលាការតែប៉ុណ្ណោះ ។

៦. ក្នុងរយៈពេលពីរឆ្នាំខាងមុខត្រូវបង្កើត និងអនុវត្តកម្មវិធី បណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់ស្តីពីការគោរពសិទ្ធិអ្នកសារព័ត៌មានក្នុងការធ្វើសេចក្តីរាយការណ៍ និងកត់ត្រានៅពេលមានការតវ៉ា និងក្នុងព្រឹត្តិការណ៍សាធារណៈផ្សេងទៀត។

៧. អនុម័តច្បាប់ស្តីពីការផ្សព្វផ្សាយ ដែលបង្កើតអាជ្ញាធរផ្សព្វផ្សាយឯករាជ្យមួយ និងបង្កើតបទបញ្ញត្តិច្បាស់លាស់ និងអព្យាក្រឹតសម្រាប់ផ្តល់ អាជ្ញាប័ណ្ណផ្សព្វផ្សាយស្របតាមស្តង់ដារអន្តរជាតិ។

៨. អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលស្របតាមស្តង់ដារអន្តរជាតិត្រឹមដំណាច់ឆ្នាំ២០២៤។

៩. ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីឱ្យស្របតាមស្តង់ដារសេរីភាពនៃការបញ្ចេញមតិអន្តរជាតិរួមទាំងការលុបចោល ឬកែប្រែបទញុះញង់ (មាត្រា៤៩៤,៤៩៥) និងលុបចោលបទប្រមាថចំពោះអង្គព្រះមហាក្សត្រ (មាត្រា ៤៣៧-ស្ទួន) បទបរិហារកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥) និងបទជេរ ប្រមាថជាសាធារណៈ (មាត្រា៣០៧) ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ បង្កើតបទបញ្ញត្តិច្បាស់លាស់ជុំវិញការទទួលស្គាល់ស្ថាប័នសារព័ត៌មាន និងការចុះបញ្ជី ស្ថាប័នសារព័ត៌មាន និងមិនចាំបាច់តម្រូវឱ្យប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញសុំអាជ្ញាបណ្ណ ។

១០. លុបចោលប្រកាសរបស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលលុបអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយដោយមិនបាច់ឆ្លងកាត់នីតិវិធីតុលាការដែលបា នរំលោភលើគោលការណ៍សេរីភាពសារព័ត៌មាន និង មាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

១១.លុបចោលប្រកាសអន្តរក្រសួងលេខ១៧០ ដែលត្រូវបានប្រើដើម្បីលុបអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយដោយចាំបាច់ មានសេចក្តីសម្រេចរបស់តុលាការក៏ដូចជាផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការបញ្ជាទៅក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ឱ្យបិទគេហទំព័រ និងលុបចោល អនុក្រឹត្យស្តីពីការចុះ បញ្ជីឈ្មោះដែន ការចុះឈ្មោះស៊ីមកាតនិងច្រកទ្វារ អ៊ីនធឺណិតជាតិ។

១២.កំណត់អំណាចរបស់អាជ្ញាធរឱ្យបានច្បាស់លាស់ថា តើនៅពេលណាអាចតាមដាន និងបិទគេហទំព័រអ៊ីនធឺណិតបានដោយគ្មានដីកាបង្គាប់ពីតុលាការ និងកែសម្រួលច្បាប់ស្តីពី ទូរគមនាគមន៍ឱ្យស្របតាមស្តង់ដារអន្តរជាតិ។

១៣.រៀបចំការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ស្តីពីសេចក្តីព្រាងច្បាប់ដែល ប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ ដើម្បីអនុញ្ញាតឱ្យសង្គមស៊ីវិលផ្តល់ធាតុចូល និងធានាឱ្យស្របជាមួយកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរួមទាំងសេចក្តីព្រាងច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សន្តិសុខតាមអ៊ីនធឺណិត និងការការពារទិន្នន័យផ្ទាល់ខ្លួន។

១៤. ធ្វើឱ្យប្រជាពលរដ្ឋកាន់តែងាយស្រួលក្នុងការទទួលបានសេវាអ៊ីនធឺណិត ដើម្បីធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋកម្ពុជាទាំងអស់អាចទទួលបានព័ត៌មានតាមអ៊ីនធឺណិត។ ការងារនេះអាចធ្វើបានតាម រយៈ៖

- ការធានានូវសិទ្ធិទទួល បានសេវាអ៊ីនធឺណិត ប្រើប្រាស់ស្មើៗគ្នានៅក្នុងក្រុមជនងាយរងគ្រោះ រួមទាំងស្ត្រី ជនពិការ និងជនជាតិដើមភាគតិច។
- ការលើកទឹកចិត្តដល់វិស័យទូរគមនាគមន៍ ក្នុងការផ្តល់ជម្រើស ដែលមានតម្លៃទាបទាំងក្នុងទីក្រុង និងតំបន់ជនបទតាមរយៈការកាត់បន្ថយពន្ធការឧបត្ថម្ភធន ឬគម្រោងស្រដៀងគ្នានេះ។
- ការពង្រីកសេវាទូរសព្ទនៅតាម តំបន់ជនបទអមដោយឥណទាន ឬការឧបត្ថម្ភធនដល់ប្រជាពលរដ្ឋដែលមិនមានលទ្ធភាពទិញសេវាអ៊ីនធឺណិត ឬឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន។
- ការបង្កើតមណ្ឌលអ៊ីនធឺណិតសហគមន៍ ជាកន្លែងដែលសមាជិកសហគមន៍អាចប្រើប្រាស់អ៊ីនធឺណិត និងកុំព្យូទ័រដោយឥតគិតថ្លៃឬ ទទួលបានក្នុងតម្លៃទាប។

១៥. បង្កើនការអប់រំអក្ខរកម្មឌីជីថល ទាំងនៅតាមស្ថាប័នអប់រំផ្លូវការ ដូចជាសាលារៀន និងសាកលវិទ្យាល័យ ក៏ដូចជានៅតាមស្ថាប័នអប់រំក្រៅផ្លូវការ។ គោលបំណងគឺដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជាអាចបែងចែករវាងប្រភពព័ត៌មានល្អ និងប្រភពព័ត៌មានមិនល្អព្រមទាំងអាចវាយតម្លៃព័ត៌មានដែលពួកគេទទួលបាន៕

# ទំនាក់ទំនង

+(៨៥៥) ១០ ៨៨២ ៣១១

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

www.camboja.net